

# កម្រងអត្ថបទជ្រើសរើស

# សិក្សាតំបន់អាស៊ីអាគ្នេយ៍

## វគ្គទី ៦

# និយមន័យ នៃជាតិនិយម និងអត្តសញ្ញាណ
# នៅក្នុងសកលលោក និងអាស៊ី៖
# បាឋកថារបស់លោក បេនិឌិកត៍ អាន់ដឺរសុន

DEFINITIONS OF NATIONALISM AND IDENTITY IN THE WORLD AND ASIA:
LECTURES BY BENEDICT ANDERSON

## ប្រវត្តិនៃចលនាវិវត្តន៍គំនិតជាតិនិយមសាកល:

*អត្ថបទនេះដកស្រង់ចេញពី ÷ បាឋកថារបស់លោកសាស្ត្រាចារ្យ បេនិឌិកត៍ អាន់ដឺរសុន នៅម.ខ.ស. នាថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៨*

*រក្សាសិទ្ធិ គ.ស. ២០០៨ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។*

**Historical Development of Universal Nationalism:**
**Illustrated from: Lecture by Professor Benedict Anderson, Center for Khmer Studies, December 19, 2008**
**Copyright © 1967 by Center for Khmer Studies.**

## ជាតិនិយមនៅទ្វីបអាស៊ី:

*អត្ថបទនេះដកស្រង់ចេញពី ÷ បាឋកថារបស់លោកសាស្ត្រាចារ្យ បេនិឌិកត៍ អាន់ដឺរសុន នៅម.ខ.ស. នាថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៨*

*រក្សាសិទ្ធិ គ.ស. ២០០៨ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។*

**Nationalism in Asia:**
**Illustrated from: Lecture by Professor Benedict Anderson, Center for Khmer Studies, December 20, 2008**
**Copyright © 1967 by Center for Khmer Studies.**

## ការទំរកឃើញអាស៊ីអាគ្នេយ៍ពីខាងក្នុង:

*អត្ថបទនេះដកស្រង់ចេញពី ÷ ទស្សនាវដ្តី សិក្សាចក្រ របស់មជ្ឈមណ្ឌលខេមរសិក្សាលេខ៦*

*រក្សាសិទ្ធិ គ.ស. ២០០៨ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។*

**Trying to Locate Southeast Asia from Navel:**
**Illustrated from: Siksacakr Vol 6 of Center for Khmer Studies**
**Copyright © 2008 by Center for Khmer Studies.**

រក្សាសិទ្ធិក្នុងការបកប្រែនិងចេញផ្សាយជាភាសាខ្មែរ © គ.ស. ២០០៩ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។
**Copyright © 2009 Center for Khmer Studies for the Khmer translation.**

**រូបភាពក្របមុខដោយ ◢ Cover picture**

ហ៊ុយប៊ែរ្ត៍ ដេហ្វូស្សេហ្ស៍ (រក្សាសិទ្ធិ) គ.ស. ២០០៩ **Copyright © 2009 Hubert Défossez.**

ការបកប្រែនិងបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមូលនិធិ រ៉ក្គីហ្វេល្ល័រ នៅញូយ៉ក ។
**The publication of this book was supported by the Rockefeller Foundation (New York).**

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-១៥-០ ISBN-13: 978-99950-51-15-0

បោះពុម្ពនៅប្រទេសកម្ពុជាដោយរោងពុម្ព ពន្លឺខ្មែរ ។
**Printed in Cambodia by Ponleu Khmer Printing & Publishing House.**

# សារបណ្ណ

**កថាមុខ** **៥**

Preface **7**

**ប្រវត្តិនៃចលនាវិវត្តន៍គំនិតជាតិនិយមសាកល** **៩**

*បាឋកថារបស់លោកសាស្ត្រាចារ្យ បេនិឌិកត៍ អាន់ដឺរសុន នៅ ម.ខ.ស. នាថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៨*

*សំណួរ – ចម្លើយ ១៨*

**ជាតិនិយមនៅទ្វីបអាស៊ី** **២៥**

*បាឋកថារបស់លោកសាស្ត្រាចារ្យ បេនិឌិកត៍ អាន់ដឺរសុន នៅ ម.ខ.ស. នាថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៨*

*សំណួរ – ចម្លើយ ៣៤*

**ការខំរកឃើញអាស៊ីអាគ្នេយ៍ពីខាងក្នុង ៖** **៤៣**

**តើការសិក្សាអំពីអាស៊ីអាគ្នេយ៍នៅប្រទេសថៃ នៅឯណា ?**

*តើប្រទេសថៃខ្វះចំណេះដឹងអំពីអាស៊ីអាគ្នេយ៍ មែនឬទេ? ៤៥*

*ពួកសត្រូវ និង ពួកកន្ទៀតទាបតូច (ពួកបរិវារ) ៤៧*

*ប្រទេសជិតខាងក្នុងប្រវត្តិសាស្ត្រថៃ ៤៨*

*ចំណេះដឹងបែបចក្រពត្តិនិយមសៀមអំពីអាស៊ីអាគ្នេយ៍ ទៅតាមកាលសម័យ ៥៥*

*ចំណេះដឹងរបស់អ្នកស្រុកអំពីប្រទេសជិតខាង ៥៧*

*សេចក្តីសន្និដ្ឋាន ៥៩*

Historical Development of Universal Nationalism

Lecture by Professor Benedict Anderson, Center for Khmer Studies, December 19, 2008 **63**

Questions and Answers **71**

Nationalism in Asia

Lecture by Professor Benedict Anderson, Center for Khmer Studies, December 20, 2008 **79**

Questions and Answers **87**

# អារម្ភកថា

ចាប់តាំងពីឆ្នាំ ២០០៤ មក មជ្ឈមណ្ឌលខេមរសិក្សាបានដំណើរការកម្មវិធីបណ្តុះបណ្តាលដ៏សំខាន់មួយ ដែលមានឈ្មោះថា « កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ឧត្តមសិក្សា » ជួយគ្រូថ្នាក់ឧត្តមសិក្សាកម្ពុជាវ័យក្មេង ដែលចង់បន្តពង្រីកការសិក្សាស្រាវជ្រាវ និងការបង្រៀនរបស់ពួកគេនៅក្នុងមុខវិជ្ជាសង្គមសាស្រ្តនិងមនុស្សសាស្រ្ត ។ កម្មវិធីនេះទទួលការឧបត្ថម្ភទាំងស្រុងពីមូលនិធិរ៉ុក្គីហ្វេល្ល័រ ។

យើងខ្ញុំមានបើកវគ្គបណ្តុះបណ្តាល និងស្រាវជ្រាវជាបន្តបន្ទាប់ ដឹកនាំដោយសាស្រ្តាចារ្យដែលទទួលការអញ្ជើញមួយរូប ដែលមានកិត្តិនាមល្បី ឲ្យមកជួយបង្រៀន ដោយផ្តោតលើទិដ្ឋភាពសំខាន់ៗ មួយចំនួននៅក្នុងសង្គមកម្ពុជាសម័យទំនើប ។ យើងខ្ញុំបានធ្វើការជាមួយអ្នកតំណាង មកពីសាកលវិទ្យាល័យនៅប្រទេសកម្ពុជា ដើម្បីកំណត់ប្រធានបទសម្រាប់វគ្គនីមួយៗ ក្នុងគោលបំណងទាក់ទាញអ្នកចូលរួម ដែលមានជំនាញផ្សេងៗគ្នា និងសម្រាប់ប្រើទស្សនវិស័យប្រៀបធៀប ដែលក្នុងនោះ យើងខ្ញុំបានយកករណីប្រទេសកម្ពុជាមកសិក្សាជាមួយប្រទេសជិតខាងដទៃទៀត ដូចជាប្រទេសថៃ និងវៀតណាម។ វគ្គសិក្សានីមួយៗ មានសកម្មភាពជាច្រើនដូចជា ការសិក្សានៅក្នុងថ្នាក់សិក្ខាសាលា ការចុះកម្មសិក្សានៅតាមបណ្តាប្រទេសជិតខាង និងការស្រាវជ្រាវរបស់អ្នកចូលរួមម្នាក់ៗ។ សកម្មភាពបន្តទៀតធ្វើឡើងជាទម្រង់សិក្ខាសាលាអន្តរជាតិ ដែលផ្តោតលើមូលបទរបស់វគ្គសិក្សានីមួយៗ ហើយនិងការជ្រើសរើសអត្ថបទសិក្សាជាច្រើន ដោយសាស្រ្តាចារ្យដែលបង្រៀននៅក្នុងវគ្គនីមួយៗ និងត្រូវបកជាភាសាខ្មែរ ដោយអ្នកចូលរួមរៀននៅក្នុងវគ្គនោះ ។ គោលបំណងនៃការងារបកប្រែ គឺដើម្បីបង្កើនចំនួនឯកសារសិក្សាជាភាសាខ្មែរ ដែលកំពុងតែខ្វះខាតនៅក្នុងវិស័យសង្គមសាស្រ្ត និងមនុស្សសាស្រ្ត ដែលជាតម្រូវការរបស់គ្រូបង្រៀននៅតាមសាកលវិទ្យាល័យ និងនិស្សិត ។

វគ្គទី ៦ នេះ ទាក់ទងនឹងប្រវត្តិសាស្រ្តជាតិនិយមសម័យថ្មីនៅអាស៊ីអាគ្នេយ៍ ដែលដឹកនាំការបង្រៀន ដោយលោកសាស្រ្តាចារ្យ ឆានវិត កះសេតស៊ិរិ (ជាញវិទ្យ ក្សេត្រសិរិ) (អតីតសកលវិទ្យាធិការនៃសាកលវិទ្យាល័យធម្មសាស្រ្ត នៅបាងកក ប្រទេសថៃ) និងក៏ជាប្រវត្តិវិទូដែលទទួលការគោរពច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ នៅក្នុងសៀវភៅភាគទី ៦ នេះ មានអត្ថបទចំនួនបី ដែលអត្ថបទចំនួនពីរបានមកពីបាឋកថារបស់លោកសាស្រ្តាចារ្យ បេនិឌិកត៍ អាន់ដឺរសុន ដែលជាអ្នកប្រាជ្ញល្បីល្បាញខាងការសិក្សាអាស៊ីអាគ្នេយ៍ ។ លោកសាស្រ្តាចារ្យ ឆានវិត បានអញ្ជើញលោកសាស្រ្តាចារ្យ អាន់ដឺរសុន មកប្រទេសកម្ពុជា ជាលើកទីពីរ ដើម្បីធ្វើបាឋកថាសាធារណៈ សម្រាប់អ្នកចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលខេមរសិក្សា បន្ទាប់ពីការមកប្រទេសកម្ពុជាលើកដំបូងរបស់លោក នៅក្នុងឆ្នាំ ១៩៦៣ ។ លោកសាស្រ្តាចារ្យ អាន់ដឺរសុន បានផ្តល់បាឋកថាចំនួនពីរ ដែលបាឋកថាទី ១ និយាយពីប្រវត្តិនៃចលនាវិវត្តន៍គំនិតជាតិនិយមសាកល ហើយបាឋកថាទី២ និយាយពីជាតិនិយមនៅអាស៊ី។ បាឋកថាទាំងពីរនេះ បានសង្ខេបគំនិតសំខាន់ៗ មួយចំនួន នៅក្នុងសៀវភៅដ៏ល្បីល្បាញរបស់លោក ដែលមានចំណងជើងថា « សហគមន៍ស្រមើស្រមៃ ៖ ការឆ្លុះបង្ហាញពីប្រវត្តិជាតិនិយម » ។

បាឋកថាទាំងពីរនេះ មានសារៈសំខាន់ខ្លាំងណាស់ និងជួយឲ្យអ្នកចូលរួមកម្ពុជា យកទៅឆ្លុះមើលជាមួយនឹងភាពតានតឹងសង្គម និងនយោបាយ នាពេលថ្មីៗនេះ រវាងប្រទេសកម្ពុជានិងប្រទេសថៃ ដែលមានពាក់ព័ន្ធនឹងរឿងជាតិនិយម និងប្រវត្តិជម្លោះ ទាក់ទងនឹងប្រាសាទព្រះវិហារ និងជម្លោះព្រំដែន។ អត្ថបទមួយផ្សេងទៀត គឺសរសេរឡើងដោយអ្នកនិពន្ធ

ទង់ជ័យ វិនិច្ឆកូល មានចំណងជើងថា « ការខំរកឃើញអាស៊ីអាគ្នេយ៍ពីខាងក្នុង ៖ តើការសិក្សាពីអាស៊ីអាគ្នេយ៍ក្នុងប្រទេសថៃនៅឯណា ? » ។ អត្ថបទនេះធ្លាប់បានបោះពុម្ពនៅក្នុងទស្សនាវដ្ដីសិក្សាចក្ររបស់មជ្ឈមណ្ឌលខេមរសិក្សា ។ អត្ថបទនេះពន្យល់ពីប្រវត្តិសិក្សាមុខវិជ្ជាអាស៊ីអាគ្នេយ៍នៅក្នុងប្រទេសថៃ ដែលបានអភិវឌ្ឍកម្មវិធីសិក្សានេះ ឲ្យមានលក្ខណៈស្ដង់ដារបស្ចិមប្រទេស ។

ដោយព្យាយាមរក្សានូវគោលបំណងគរុកោសល្យ របស់កម្មវិធីបណ្ដុះបណ្ដាលនេះ យើងខ្ញុំសង្ឃឹមថា អត្ថបទបកប្រែទាំងនេះ នឹងបម្រើដល់សាស្ត្រាចារ្យនិងនិស្សិតក្នុងមុខវិជ្ជាប្រវត្តិវិទ្យា, សង្គមវិទ្យា, សេដ្ឋកិច្ច, នរវិទ្យា, វិទ្យាសាស្ត្រនយោបាយ, ទំនាក់ទំនងអន្តរជាតិ និងមុខវិទ្យាដទៃទៀត ។ យើងខ្ញុំក៏សង្ឃឹមផងដែរថា អត្ថបទនេះនឹងជួយជំរុញឲ្យអ្នកអាន ស្រាវជ្រាវបន្ថែម ហើយវិភាគរិះគន់ ដោយប្រើការសិក្សាប្រៀបធៀប និងរៀនសូត្រទៅវិញទៅមក ។

ខ្ញុំសូមបញ្ចប់សេចក្ដី ដោយសូមថ្លែងអំណរគុណ ចំពោះលោកបណ្ឌិត ឆាន់វិត កៈសេតស៊ិរិ ដែលបានចែករំលែកគំនិតប្រាជ្ញា និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោក ឲ្យដល់បញ្ញវន្តវ័យក្មេងកម្ពុជា ចេះសិក្សាវិភាគពីការកកើតរដ្ឋទំនើបនៅក្នុងប្រទេស និងតំបន់ ក្នុងពេលដែលភាពតានតឹងរវាងថៃនិងកម្ពុជា បានកម្រើកជាថ្មី ។ លោកសាស្ត្រាចារ្យ ឆាន់វិត ក៏បានផ្ដួចផ្ដើមគំនិត ឲ្យមានការលើកកម្ពស់ការយោគយល់គ្នា រវាងប្រជាជនថៃ និងប្រជាជនខ្មែរផងដែរ ។ វត្តមានរបស់លោកសាស្ត្រាចារ្យ ឆាន់វិត នៅកម្ពុជា ចំពេលដែលភាពតានតឹងរវាងថៃនិងកម្ពុជា នៅតែបន្ត ពិសេសលើបញ្ហាជម្លោះរឿងប្រាសាទព្រះវិហារ ពិតជាមានអត្ថន័យជ្រាលជ្រៅ ដោយសារតែលោកបានរួមចំណែកមួយផ្នែក នៅក្នុងការធ្វើឲ្យមានការយោគយល់គ្នា រវាងប្រជាជនថៃនិងប្រជាជនកម្ពុជា ។ សូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ ឆាន់វិត ដែលបានជួយឲ្យអ្នកចូលរួមកម្ពុជា មានឱកាសជួបលោកបណ្ឌិត បេនិឌិកត៍ អាន់ដឺរសុន ។ ប្រសិនបើគ្មានការរួមចំណែកដ៏ធំធេងរបស់លោកសាស្ត្រាចារ្យ អាន់ដឺរសុន ក្នុងការកែសម្រួលអត្ថន័យ និងអក្ខរាវិរុទ្ធនោះទេ ស្នាដៃមួយនេះនឹងមិនអាចលេចជារូបរាងបានឡើយ ។

សូមថ្លែងអំណរគុណជាពិសេស ចំពោះក្រុមការងារបកប្រែវ័យក្មេង ពិសេសលោក ថុល ឌីណា និងលោក ទូច សុពុទ្ធី ចំពោះការងារដ៏ស្វាហាប់របស់ពួកគាត់ ។ សូមថ្លែងអំណរគុណផងដែរ ចំពោះលោកសាស្ត្រាចារ្យ វង់ សុធារ៉ា, លោកបណ្ឌិត មីស្ទែល ប្ញទ្ធី អង់តែល្ម, និងកញ្ញា ឆោម គន្ធា ដែលបានចំណាយពេលវេលាដ៏មមាញឹក ជួយពិនិត្យមើលអត្ថបទព្រាងបកប្រែចុងក្រោយ ។ សូមថ្លែងអំណរគុណដល់លោក ម៉ៃខឹល សុល្លីវ៉ាន់ នាយកមជ្ឈមណ្ឌលខេមរ-សិក្សា ដែលបានជួយពិនិត្យ និងកែតម្រូវអត្ថបទជាភាសាអង់គ្លេស ។ ខ្ញុំក៏សូមសម្ដែងការអរគុណ ចំពោះលោក យ៉ែម យឿន ដែលជាអ្នកសម្របសម្រួលការបោះពុម្ពផ្សាយ សម្រាប់ការងារដ៏ល្អ ក្នុងការចាត់ចែងរឿងបោះពុម្ពផ្សាយឲ្យទាន់ពេល ៕

ម៉ែន ឈានរិទ្ធី
នាយកគម្រោង

# PREFACE

Since 2004, the Center for Khmer Studies (CKS) has been conducting the Junior Faculty Training Program (JFTP). As the title of the program suggests, it is aimed at young aspiring Cambodian university faculty who wish to expand their knowledge of research and teaching training in the Humanities and Social Sciences. The program is generously funded by the Rockefeller Foundation.

It is structured around semester long research and training sessions led by suitably qualified scholars and instructors. Each session focuses on a particular aspect of contemporary Cambodian society. The themes and topics are defined in coordination with representatives of Cambodian universities to attract participants from multi-disciplinary backgrounds. The sessions adopt a comparative perspective where Cambodia is studied alongside its neighbors Thailand and Vietnam. The sessions include a combination of taught classes, interactive seminars, field visits to the two nearby countries, and an individual research project followed by an international conference to discuss the theme and issues covered during session. Furthermore, a selection of key reading texts used during the session is chosen by the lead scholar for translation from English into Khmer by the Cambodian participants. The translated texts are then put together and published as a volume to be used as a reader in Cambodian universities. The aim of this exercise is to increase the extremely limited corpus of academic reading materials available in Khmer.

CKS has now produced six of these readers. This sixth volume represents the session: *History of Modern Nationalism in Southeast Asia* led by the distinguished Thai historian Professor Charnvit Kasetsiri from Thammasat University, Bangkok. It consists of three readings. At the invitation of Prof. Charnvit the session participants were honored and privileged to have the eminent Professor Benedict Anderson deliver two lectures: *Historical Development of Universal Nationalism* and *Nationalism in Asia*. Prof. Anderson addressed themes and issues from his hugely influential book: *Imagined Communities, Reflection on the Origins of Nationalism*. This was Prof. Anderson's first visit to Cambodia since 1963. To mark the occasion, and as a tribute to the importance of this work, CKS transcribed and translated the lectures into Khmer and reproduced them here in this reader.

The lectures were particularly poignant for the Cambodian participants as they helped to shed light on recent tensions between Thailand and Cambodia. These tensions are embed-

ded in ideas about nationalism and historical conflict manifested in the dispute between the two countries over the Khmer Preah Vihear temple and related border issues. Another influential article in this volume is Thongchai Vinicharkul's "Trying to locate Southeast Asia from its navel: ocating Southeast Asia: Where is Southeast Asian Studies in Thailand?" This article was originally published in the CKS journal *Siksācakr*. It has been reproduced here in an effort to reach a wider Cambodian audience. The article explains the historical development of Southeast Asia studies in Thailand which attempted to follow the academic standard of Western curriculum.

In keeping with the pedagogical objectives of the JFTP, we sincerely hope that these translated texts will be of use to both professors and students in the fields of History, Sociology, Economics, Anthropology, Political Science, International Relations, and other fields. We also hope that they will encourage readers to critically investigate the relevant issues and themes using a comparative and interdisciplinary approach.

I would like to finish here by extending my utmost appreciation and thanks to Prof. Charnvit Kasetsiri for his contribution to this volume. His professional and personal experiences were invaluable in providing an intellectual framework that enabled the young Cambodian scholars to critically examine processes of nation-state building in the countries of the region. Prof. Charnvit is actively engaged in promoting mutual understanding between Thais and Cambodians. The continuing tension between the two countries thus made his presence in Cambodia all the more meaningful.

Finally, the publication of this volume would not have been possible without the diligence and dedication of the translation and publishing team. Thol Dina and Touch Soputhy took on the bulk of the translation work. Despite their busy work schedules, Prof. Michel Rethy Antelme and Chhom Kunthea, took the time to meticulously review the final version of the text. Yem Yoeun, the CKS Communications and Publishing Coordinator ensured it was published in an accessible and timely manner. Special thanks go to all involved in what was once again a truly collaborative undertaking.

Chean Rithy Men
*Project Director*.

# ប្រវត្តិនៃចលនាវិវត្តន៍គំនិតជាតិនិយមសាកល

បាឋកថារបស់លោកសាស្ត្រាចារ្យ បេនិឌិកត៍ អាន់ដឺរសុន
មជ្ឈមណ្ឌលខេមរសិក្សា ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៨

*ខ្ញុំនឹងធ្វើបទបង្ហាញតាមរបៀបសាមញ្ញ ។ ខ្ញុំសុំឈរនិយាយ ពីព្រោះខ្ញុំអង្គុយស្ទើរតែពេញមួយថ្ងៃទៅហើយ ។ ខ្ញុំដូចជាត្រូវការលំហាត់ប្រាណខ្លះៗ ខ្ញុំរីករាយជាពន់ពេក ដែលបានត្រឡប់មកភ្នំពេញជាថ្មីម្តងទៀត បន្ទាប់ពីវត្តមានលើកដំបូងរបស់ខ្ញុំកាលពីឆ្នាំ ១៩៦១ ដែលកាលពីពេលនោះ ទីក្រុងភ្នំពេញគ្រាន់តែជាទីក្រុងតូចមួយប៉ុណ្ណោះ ។ ខ្ញុំបានជិះរថយន្តក្រុងពីភ្នំពេញទៅសៀមរាប តាំងពីពេលដែលសៀមរាបនៅមិនទាន់មានសណ្ឋាគារនៅឡើយ ។ កាលនោះ សៀមរាបស្រស់ស្អាត និងស្ងប់ស្ងាត់ណាស់ ។ ក្រោយមក ស្ថានភាពនៅក្នុងប្រទេសកម្ពុជា បានប្រែប្រួលទាំងស្រុង ។ ម៉្លោះហើយ ប៉ុន្មានថ្ងៃថ្មីៗនេះ ខ្ញុំប្រឹងសួរលោកគ្រូ ឈាន និងអ្នកផ្សេងទៀត ដើម្បីឲ្យដឹងរឿងច្រើនបន្ថែមទៀត ។*

*ជាបឋម ខ្ញុំសូមរំឭកអ្នកទាំងអស់គ្នាថា បើសិនជាអ្នកមិនយល់អ្វីដែលខ្ញុំនិយាយ សូមកុំស្ទាក់ស្ទើរប្រាប់ខ្ញុំថា ៖ «សូមទោស! កុំលឿនពេក! សូមពន្យល់ខ្ញុំឲ្យបានក្បោះក្បាយផង» ។ ខ្ញុំនិយាយយឺតៗទេ ។*

*ខ្ញុំចង់បង្ហាញអ្នកទាំងអស់គ្នាបន្តិច អំពីប្រវត្តិដ៏ចម្លែកនៃការសិក្សាអំពី «ជាតិនិយម» ថា តើមនុស្សជាតិបានជជែកដេញដោលតាមរបៀបណា លើប្រធានបទមួយ ដែលបានក្លាយទៅជាប្រធានបទដ៏លំបាកនិងស្មុគស្មាញ? តាមពិតទៅ រហូតមកដល់ពេលសព្វថ្ងៃនេះ មិនឃើញមានភាពចុះសម្រុងគ្នាក្នុងចំណោមអ្នកប្រាជ្ញ និងទស្សនវិទូនានាលើប្រធានបទ «តើអ្វីជាជាតិនិយម?» ឲ្យបានច្បាស់លាស់នៅឡើយទេ ។ ដូច្នេះ ប្រសិនបើអ្នកមិនយល់ប្រធានបទនេះទេ អ្នកឯទៀតក៏មិនយល់ដែរ ។*

*យើងនឹងចាប់ផ្តើមជាមួយពាក្យ «ជាតិនិយម» ។ សព្វថ្ងៃនេះ ខ្ញុំគិតថា អ្នកប្រាជ្ញភាគច្រើន មានយោបល់ថា «ជាតិនិយម» គឺជាអ្វីមួយ ដែលកើតនៅក្នុងសម័យទំនើប ប៉ុកំយ៉ាំងហោចណាស់ កើតឡើងក្រោយពាក់កណ្តាលទីពីរនៃចុងគ្រិស្តសតវត្សរ៍ទី ១៨ ដែរ ។ មនុស្សជាច្រើនតែងតែគិតថា បដិវត្តន៍អាមេរិកឆ្នាំ ១៧៧៦ ប្រឆាំងនឹងចក្រភពអង់គ្លេស គឺជាការចាប់កំណើតនៃ «ជាតិនិយម» ។ សញ្ញាណនៃ «ជាតិនិយម» គឺការប្រកាសឯករាជ្យរបស់ដែនអាណានិគមទាំង ១៣ របស់អង់គ្លេសនៅភាគខាងជើងនៃអឌ្ឍគោលខាងលិច ។ គំនិតនេះមិនខុសនោះទេ ប៉ុន្តែវាតម្រូវឲ្យមានការកែសម្រួលបន្តិចថែមទៀត ។ ឧទាហរណ៍ ពាក្យប្រយោគដែលប្រើនៅក្នុងការប្រកាសឯករាជ្យនេះ គួរឲ្យចាប់អារម្មណ៍ណាស់ ។ យើងមិនឃើញគេរំលឹកពីពាក្យ «ប្រជាជនអាមេរិក» ឡើយ ។ វាបង្ហាញឲ្យយើងឃើញច្បាស់ថា មនុស្សដែលគាំទ្របដិវត្តន៍ នៅតែគិតនិងចាត់ទុកខ្លួនឯងថា ជាជន*

អង់គ្លេសនៅឡើយ ។ ពួកគេបានចំណាយពេលប្រហែល ១០ ឆ្នាំ ធ្វើសង្គ្រាមបង្ហូរឈាម ទើបអាចចាប់ផ្តើមគិត និងចាត់ទុកខ្លួនឯងថា ជាជនជាតិអាមេរិក ។ អត្តសញ្ញាណនេះកើតឡើងនៅពេលដែលពួកគេហៅប្រទេសរបស់ពួកគេថា សហរដ្ឋអាមេរិក ដែលកាលពីដំបូង មានន័យថា ជាដែនដីមួយរបស់អង់គ្លេស នៅដាច់ដោយឡែកពីកាណាដា ដែលជាប់ព្រំដែននៅភាគខាងជើង ប៉ុន្តែ នៅតែជង្គ្លេតាមក្រុងឡុងដ្រ៍ ។ ឈ្មោះនេះក៏បានបង្ហាញពីទីតាំង ដែលប្រទេសថ្មីនេះស្ថិតនៅផងដែរ ។

ក្រោមបន្ទាប់ពីព្រឹត្តិការណ៍ខាងលើនេះ ចលនាបះបោរមួយទៀត បានកើតឡើងនៅបណ្តាដែនអាណានិគមរបស់អេស្ប៉ាញនៅអាមេរិកខាងត្បូង ។ មកត្រឹមឆ្នាំ ១៨២៥ ប្រទេសស្ទើរតែទាំងអស់នៅទ្វីបអាមេរិកខាងត្បូង លើកលែងតែប្រេស៊ីលរបស់ព័រទុយហ្កាល់ចេញ បានទទួលជ័យជំនះក្នុងការតស៊ូប្រឆាំងនឹងអេស្ប៉ាញ ។ ពួកគេក៏បានចាត់ទុកខ្លួនឯងថា ជាជនជាតិអាមេរិកផងដែរ គឺជនជាតិនៅអឌ្ឍគោលខាងលិច (គឺមិនមែនប្រជាពលរដ្ឋសហរដ្ឋអាមេរិកទេ) ។ ក្នុងពេលជំណាលគ្នានេះដែរ អ្វីដែលជាព្រឹត្តការណ៍ដ៏សំខាន់ នាំឲ្យមានចលនាជាតិនិយម គឺបដិវត្តន៍បារាំងឆ្នាំ ១៧៨៩ ។ ជាថ្មីម្តងទៀត រឿងដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថា នៅឆ្នាំ ១៧៨៩ និងក្រោយមកទៀត មនុស្សម្នាមិនបានហៅព្រឹត្តិការណ៍នេះថា «បដិវត្តន៍បារាំង»ទេ ។ ពួកគេគ្រាន់តែហៅថា «បដិវត្តន៍» ប៉ុណ្ណោះ ។ អ្នកប្រហែលជានៅចាំថា នៅឆ្នាំ ១៧៩២ ពួកអ្នកបដិវត្តបានសម្រេចចិត្តប្តូរប្រតិទិន ហើយយកឆ្នាំ ១៧៩២ ជាឆ្នាំទី ១ ។ ឆ្នាំទី ១ នេះ មិនមែនជាអ្វីម្យ៉ាងដែលជាកម្មសិទ្ធិរបស់បារាំងនោះទេ ប៉ុន្តែ វាសំដៅទៅលើសករាជថ្មីនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ និងប្រវត្តិសាស្ត្រសកលលោក ។ គេបានអំពាវនាវឲ្យមនុស្សគ្រប់គ្នាចូលរួមបដិវត្តន៍ ។ នៅតំបន់ជាច្រើន មានមនុស្សចូលរួមបដិវត្តន៍នោះយ៉ាងកុះករ ។ ការប្តូរឈ្មោះទៅជាបដិវត្តន៍បារាំងទើបតែមានក្រោយពេលដែលស្តេច ណាប៉ូឡេអុង ឡើងកាន់អំណាច ដែលហៅខ្លួនឯងថា ព្រះចៅអធិរាជ និងក្រោយមក ត្រូវបានបង្ក្រាបដោយសម្ព័ន្ធមិត្តរបស់អង់គ្លេស រាជាណាចក្រព្រូស (អាឡឺម៉ង់) រុស្ស៊ី និងអូទ្រីសតែប៉ុណ្ណោះ ។ ព្រះចៅណាប៉ូឡេអុងត្រូវគេនិរទេសព្រះអង្គទៅក្រៅប្រទេសរហូតដល់សោយព្រះទិវង្គត ។ ឈ្មោះដែលយើងទទួលស្គាល់ គឺជាលទ្ធផលនៃមហាបរាជ័យឆ្នាំ ១៨១៥ ។

នៅក្នុងសតវត្សរ៍ទី ១៩ នោះ ប្រទេសនៅអឺរ៉ុបភាគច្រើន ប្រកាន់យករបបរាជានិយម ។ នៅអាស៊ី របបអធិរាជនិយមមាននៅក្នុងប្រទេសជាច្រើន ដែលមានរាជធានី ដូចជា អ៊ីស្តង់ប៊ូល ប៉េកាំង តូក្យូ (ឈ្មោះបុរាណ÷ អេដុ) ជាដើម ។ មានតែនៅអឌ្ឍគោលខាងលិចទេ ដែលដឹកនាំតាមបែបសាធារណរដ្ឋ និងបែបជាប្រជាជាតិសាមញ្ញ ។ ខ្ញុំគិតថា ចំណុចនេះជួយពន្យល់នូវរឿងដ៏ចម្លែក និងគួរឲ្យចាប់អារម្មណ៍មួយអំពីជាតិនិយម ដែលពេញមួយសតវត្សរ៍ទី ១៩ នៅក្នុងវចនានុក្រមភាគច្រើន មិនមានពាក្យ «ជាតិនិយម» ឡើយ ។ ពាក្យនេះ ទើបតែកើតនៅចុងសតវត្សរ៍ទី ១៩ ប៉ុណ្ណោះ ប៉ុន្តែ បានរីកសាយភាយយ៉ាងរហ័សនៅពេលក្រោយមក ។ ឧទាហរណ៍ នៅទ្វីបអាស៊ី ជនជាតិឥណ្ឌូនេស៊ីហៅពាក្យ Nationalism «ជាតិនិយម» ជាសំនៀងភាសាខ្លួនផ្ទាល់ថា «ណាស្យូណាលីស្មឺ» (nasionalisme) ។ ចំណែកឯប្រជាជនហ្វីលីពីន ហៅពាក្យ «ជាតិនិយម» នៅក្នុងសំនៀងភាសាខ្លួនផ្ទាល់ថា «ណាស្យូណាលីស្មូ» (nasyonalismo) ហើយជនជាតិថៃហៅពាក្យនេះថា «ជាតិនិយម» (ชาตินิยม) អានថា «ឆាតនិយ៉ុម» (ដែលត្រូវគ្នានឹងពាក្យខ្មែរថា «ជាតិនិយម») ។ ពាក្យ «ឆាតនិយ៉ុម» ក្នុងភាសាថៃ ក៏ជាការបង្កើតថ្មីផងដែរ ។ អ្នកនឹងមិនអាចរកឃើញពាក្យនេះនៅក្នុងពង្សាវតារចាស់ៗ ឡើយ ។ ដូច្នេះ ចម្ងល់គឺនៅត្រង់ថា ជាតិនិយមគឺជាអ្វីម្យ៉ាង ដែលមានសារៈសំខាន់បំផុតនៅក្នុងវិស័យនយោបាយ ដែលដំបូង កើតមាននៅ

អាមេរិកខាងជើងនិងខាងត្បូង បន្ទាប់មក មានកាន់តែច្រើននៅអឺរ៉ុប និងក្រោយមកទៀត នៅអាស៊ី ។ ប៉ុន្តែ ហេតុអ្វីបានជាគេចាំទាល់តែមួយសតវត្សរ៍ទៀតសិន ទើបរកពាក្យហៅ ចលនាជាតិនិយម បាន ? នេះគឺជារឿងមួយគួរឲ្យឆ្ងល់ នៅពេលដែលអ្នកដឹងថា ស្ទើរតែគ្មានទស្សនវិទូ និងអ្នកប្រាជ្ញនយោបាយល្បីល្បាញណាម្នាក់ នៅ ស.វ. ទី ១៩ បាននិយាយអ្វីសំខាន់ពីជាតិនិយមនោះ ។

មានមនុស្សតែម្នាក់គត់ ដែលគេចងចាំរហូតដល់ពេលសព្វថ្ងៃ ដោយសារតែបាននិយាយរឿងគួរឲ្យចាប់អារម្មណ៍មួយចំនួនអំពី ជាតិនិយមនោះ គឺទស្សនវិទូនិងភាសាវិទូបារាំងឈ្មោះ រ៉ឺណង់ (Renan) ដែលបាននិពន្ធអត្ថបទខ្លីមួយនៅក្នុងឆ្នាំ ១៨៨១ ក្រោមចំណងជើងថា «តើជាតិជាអ្វី?» ។ គាត់បានព្យាយាមសួរសំណួរនេះក្នុងទម្រង់អរូបីទូទៅមួយ ប៉ុន្តែ ចម្លើយរបស់គាត់មិនសូវជាច្បាស់លាស់ទេ ។ ប៉ុន្តែ គាត់បាននិយាយចំណុចមួយដែលពិតជាមានសារៈសំខាន់ និងមានសច្ចភាពទាក់ទងនឹងលក្ខណៈដើមរបស់ពាក្យ ជាតិនិយម ។ គាត់បាននិយាយថា **« ប្រជាជាតិនីមួយ ៗ ឬក៏ជាតិនីមួយ ៗ ត្រូវតែមានលក្ខណៈដូចគ្នាជាច្រើន ហើយពួកគេក៏ច្បាស់ជាបានភ្លេចរឿងរ៉ាវអស់ជាច្រើនហើយដែរ »** ។ ឃ្លាខាងដើមនៃប្រយោគនេះ វាងាយស្រួលទេ÷ «យើងជាជនជាតិខ្មែរ យើងជាជនជាតិថៃ និងជាជនជាតិអេស្ប៉ាញ មានលក្ខណៈរួមគ្នាច្រើន» ។ ប៉ុន្តែ ឃ្លានៅខាងចុង វាលំបាក ។ ឃ្លានេះមានន័យថា យើងប្រហែលជាមិនអាចក្លាយទៅជាជនជាតិខ្មែរ ឥណ្ឌូនេស៊ី ឬក៏ព័រទុយហ្គាល់នោះទេ ប្រសិនបើយើងមិនអាចបំភ្លេចរឿងជាច្រើនចោលនោះ ។ លោក រ៉ឺណង់ បានផ្ដល់ឧទាហរណ៍ដ៏ល្អមួយ ចំពោះអ្នកអានជនជាតិបារាំងរបស់គាត់ ។ គាត់បានសួរថា «តើពាក្យ "ហ្វ្រង្ស" (France) និង "ហ្វ្រង់ស៊ែស៍" (français) មានប្រភពមកពីណា ? ជាការពិត ពាក្យពីរនេះមានប្រភពមកពីភាសារបស់ជនជាតិហ្វ្រង់ ដែលនិយាយភាសាមួយក្នុងអម្បូរភាសាអាឡឺម៉ង់ និងវាយបានប្រទេសមួយ កាលពី ស.វ. ទី ៨ ដែលក្រោយមក ប្រទេសនោះមានឈ្មោះថា «បារាំងសែស» ។ ព្រះរាជាដ៏ឆ្នើម ព្រះនាម សារឡឺម៉ាញ ក៏បានប្រសូតចេញពីអម្បូរនេះដែរ ។ ប៉ុន្តែ យើងត្រូវតែបំភ្លេចរឿងនេះ» ។ លោក រ៉ឺណង់ បានបន្តទៀតថា «នៅប្រទេសបារាំងសព្វថ្ងៃនេះ ស្ទើរតែគ្មានបារាំងសុទ្ធម្នាក់សោះ» ។

ដូចគ្នានេះដែរ នៅវៀតណាមសព្វថ្ងៃ យើងឃើញថា ជនជាតិវៀតណាម ពិតជាមានមោទនភាពចំពោះប្រទេសរបស់ពួកគេ ដែលពួកគេហៅថា វៀតណាម ។ អ្នកអាចគិតថា ពាក្យ «វៀតណាម» នេះមានអាយុកាលយូរយារណាស់ទៅហើយ ប៉ុន្តែវាមិនពិតនោះទេ ។ ពាក្យនេះត្រូវបានបង្កើតនៅ ស.វ. ទី១៩ ហើយមិនមែនជនជាតិវៀតណាមជាអ្នកបង្កើតនោះទេ ។ ពាក្យនេះ បានបង្កើតដោយអធិរាជជាតិម៉ាន់ជូ នៅប៉េកាំង ពីព្រោះតែទ្រង់មានការធុញទ្រាន់ នៅរាល់ពេលដែលស្ដេចវៀតណាមបញ្ជូនទូតឲ្យនាំសួយសារអាករទៅប៉េកាំង ទ្រង់ (ស្ដេចវៀតណាម) តែងហៅប្រទេសរបស់ព្រះអង្គថា «ដាយណាម» (Đại Nam) ដែលមានន័យថា «រាជាណាចក្រខាងត្បូង» ។ ព្រះចៅអធិរាជម៉ាន់ជូ បានផ្ញើសារតបទៅស្ដេចវៀតណាមវិញថា ឈ្មោះប្រទេសរបស់ទ្រង់គឺ «វៀតណាម» ។ ស្ដេចវៀតណាមមិនហ៊ានតវ៉ាជាមួយការសម្រេចព្រះទ័យរបស់ព្រះចៅអធិរាជម៉ាន់ជូឡើយ ប៉ុន្តែ នៅក្នុងរាជវាំងហ្វេ មិនដែលប្រើពាក្យវៀតណាមម្ដងណាឡើយ ។ ពួកគេបានបង្កើតពាក្យ «ណាមវៀត» ជំនួសវិញ ។ ដើម្បីយល់ពីរឿងដ៏ចម្លែកខាងលើនេះ អ្នកត្រូវចាំថា ពាក្យ វៀត ឬក៏វៀតណាម គឺជាពាក្យបកប្រែពីភាសាចិនថា «យេ» ដែលសព្វថ្ងៃ គឺជាតំបន់មួយនៅក្នុងប្រទេសចិន គ្របដណ្ដប់លើខេត្តក្វាងទុង ខេត្តក្វាងស៊ី និងផ្នែកខ្លះរបស់ខេត្តយូណាន ។ អ្នកក៏ត្រូវចាំផងដែរថា កាលពី ១០០០ ឆ្នាំមុន តំបន់នៅភាគខាងជើងវៀតណាមសព្វថ្ងៃ ស្ថិតក្រោមការគ្រប់គ្រងរបស់ចក្រភពចិន ។ ដូច្នេះ នៅពេលដែលអធិរាជម៉ាន់ជូ ទ្រង់មាន

ព្រះរាជឱង្ការថា «ប្រទេសរបស់ទ្រង់ឈ្មោះវៀតណាម» មានន័យថា «ទ្រង់ជាអ្នកខាងក្រៅ នៅខាងត្បូងយេ ។ ប្រទេសទ្រង់ឯងមិនស្ថិតនៅក្នុងចក្រភពរបស់យើងទេ ។ ប្រទេសរបស់ទ្រង់ គ្រាន់តែជាដែនសាមន្តរាជតូចមួយប៉ុណ្ណោះ» ។ ស្ដេចវៀតណាមមិនចូលចិត្តពាក្យនេះទេ ។ ដូច្នេះ ពួកវៀតណាមបានប្រើបញ្ច្រាស ហើយនិយាយខ្សឹបៗ ថា «ឈ្មោះរបស់យើង គឺ ណាមវៀត ដែលមានន័យថា យើងគឺជាប្រជាជនរបស់តំបន់យេភាគខាងត្បូង ។ យើងធ្លាប់គ្រប់គ្រងក្វាងទុង និងក្វាងស៊ី ហើយប្រហែលជានៅថ្ងៃណាមួយ យើងនឹងអាចទទួលបានដែនដីទាំងនេះមកវិញ» ។ រឿងដែលចម្លែកនោះ គឺថា គ្រប់គ្នាបំភ្លេចព្រះបន្ទូលនៃព្រះអធិរាជម៉ាន់ជូ ។ ១០០ ឆ្នាំក្រោយមក ជនជាតិវៀតណាមពិតជាមានមោទនភាពចំពោះ «វៀតណាម» របស់ពួកគេណាស់ ។

ក្នុងរបៀបដូចគ្នានេះដែរ អ្នកប្រហែលជាដឹងហើយថា ប្រទេសហ្វីលីពីនបានទទួលឈ្មោះយកតាមព្រះនាមរាជបុត្រាច្បងរបស់ស្ដេច ហ្វីលីព ទី ២ ដែលជាក្សត្រអេស្ប៉ាញដ៏អស្ចារ្យ និងជាព្រះមហាក្សត្រចក្រពត្តិនិយមនៅ ស.វ. ទី ១៦ ។ ទ្រង់មានព្រះបន្ទូលថា «កោះដែលទាហានរបស់យើងទើបនឹងកាន់កាប់បាននេះ នឹងត្រូវដាក់ឈ្មោះថា "ហ្វីលីពីណាស" (Filipinas)» ។ ប៉ុន្តែ សព្វថ្ងៃ មិនមានជនជាតិហ្វីលីពីនណាម្នាក់បានគិតដល់រឿងនេះទេ ហើយពួកគេមានមោទនភាពជាខ្លាំង ដែលបានកើតជាជនជាតិហ្វីលីពីន ។ ប្រហែលគ្នានេះដែរ ពាក្យថា «ឥណ្ឌូនេស៊ី» ត្រូវបានបង្កើតដោយអ្នកប្រាជ្ញអាឡឺម៉ង់ កាលពីប្រហែល ១៥០ ឆ្នាំមុននេះ ។ ឥឡូវនេះ គ្មាននរណាចាំឈ្មោះរបស់គាត់ទេ ។ ទើបតែដល់ឆ្នាំ ១៩២០ គិតទៅគឺ ៩០ ឆ្នាំមុន គ្មានមនុស្សណាម្នាក់នៅឥណ្ឌូនេស៊ីហៅខ្លួនឯងថា «ជាជនជាតិឥណ្ឌូនេស៊ី» ឡើយ ។ រីឯសព្វថ្ងៃនេះវិញ ពួកគេហៅខ្លួនឯងថា ជាជនជាតិឥណ្ឌូនេស៊ី និងមិនបានគិតពីប្រភពដើមរបស់ពាក្យឥណ្ឌូនេស៊ីនេះទៀតផង ។ ដូច្នេះ ឧទាហរណ៍ទាំងនេះបង្ហាញឲ្យឃើញថា លោក រ៉ុណង់ និយាយត្រូវ ។ អ្នកមិនអាចក្លាយជាអ្នកជាតិនិយម ដោយមិនបំភ្លេចរឿងជាច្រើននោះទេ ។

ក្នុងពេលជំណាលគ្នានេះដែរ ជាពិសេសនៅអឺរ៉ុប ចក្រភពធំៗ កំពុងទទួលរងសម្ពាធពីពួកជាតិនិយមនៅក្នុងចក្រភពរបស់ពួកគេ ។ ចក្រភពអង់គ្លេសមានបញ្ហាជាមួយពួកអៀរឡង់, ដូចរុស្ស៊ីមានបញ្ហាជាមួយពួកហ្វាំងឡង់, ពួកអ៊ុយក្រែន ពួកហ្សេអ៊ែរហ្ស៊ី ។ល។ រាជាណាចក្រព្រុស្សមានបញ្ហាជាមួយពួកប៉ូឡូញ, ចក្រភពអូទ្រីស-ហុងគ្រីជាមួយពួកឆេក ស្លូវ៉ាគី និងរូម៉ាំង, រាជាណាចក្រអូតូម៉ង់ជាមួយពួកក្រិក ប៊ុលហ្គារ និងអារ៉ាប់ ។ ក្រុមជាតិពន្ធុទាំងអស់ខាងលើ ចង់មានសេរីភាព និងមានប្រទេសជាតិផ្ទាល់ខ្លួន ។ នៅក្នុងស្ថានភាពបែបនេះហើយ ទើបនាំឲ្យលេចចេញគំនិតពាក់កណ្ដាលប្រជាធិបតេយ្យម៉ាកស៊ីសនៅអូទ្រីស ដែលលោក អូតូ បោអឺរ (Otto Bauer) បានបង្កើតឡើង នៅមុនសង្គ្រាមលោកលើកទី ១ ស្ដីពីការសិក្សាទៅលើទ្រឹស្ដី និងការប្រៀបធៀបប្រវត្តិសាស្ត្ររបស់ជាតិ និងជាតិនិយម ។ គាត់ចង់រក្សាទម្រង់ចក្រភពអូទ្រីស-ហុងគ្រី ប៉ុន្តែ ត្រូវធ្វើឲ្យមានប្រជាធិបតេយ្យ និងផ្ដល់ស្វ័យភាពដល់រដ្ឋហុងគ្រី ឆេកូ និងស្លូវ៉ាគី ជាដើម ។ ធ្វើបែបនេះ សហរដ្ឋអូទ្រីស-ហុងគ្រីអាចកើតឡើងដោយសន្តិភាព ដូចជាសហរដ្ឋអាមេរិកនៅទ្វីបអាមេរិកផងដែរ ។ ដូចលោក រ៉ុណង់ ដែរ លោក បោអឺរ បានដឹងយ៉ាងច្បាស់ពីលទ្ធភាពរបស់ជាតិនិយម ក្នុងការទទួលយកប្រវត្តិសាស្ត្រនិទាន និងជំរុញឲ្យមានការស្អប់ជនបរទេស ។ គាត់បារម្ភយ៉ាងខ្លាំងពីការស្អប់ខ្ពើមគ្នារវាងអាឡឺម៉ង់និងបារាំង (ដែលអាចក្លាយជាបុព្វហេតុនៃសង្គ្រាមលោកលើកទី ១) ។ គាត់បានសរសេរចំណុចមួយយ៉ាងល្បីថា ជនជាតិបារាំងនិងជនជាតិអាឡឺម៉ង់សព្វថ្ងៃ មានលក្ខណៈដូចគ្នាច្រើន បើគិតទៅ ជនជាតិបារាំងសព្វថ្ងៃ ដូចជនជាតិអាឡឺម៉ង់ ជាងដូចជនជាតិបារាំងពីដើមជាដូនតារបស់ខ្លួនទៀត រីឯជនជាតិអាឡឺម៉ង់វិញ ក៏ដូចគ្នា ។ គាត់សន្និដ្ឋានថា រឿងដែលសំខាន់បំផុត ដែលអាចជួយប្រជាជាតិ

ទាំងពីរឲ្យរួមរស់ជាមួយគ្នាបាន គឺមិនមែនការបង្កើតអតីតកាលឡើយ ប៉ុន្តែ គឺជាឆន្ទៈរួមសម្រាប់អនាគត ។ ខ្ញុំគិតថា ប្រសិនបើលោក ប៉ោអឺរ នៅរស់ដល់សព្វថ្ងៃ គាត់ប្រហែលជានិយាយថា ខ្មែរ និងថៃ មានលក្ខណៈដូចគ្នាច្រើនជាងជនជាតិថៃនៅសម័យអយុធ្យា ឬក៏ជនជាតិខ្មែរនៅសម័យអង្គរ ។ លោក ប៉ោអឺរ គឺជាអ្នកប្រាជ្ញដំបូងដែលបានភ្ជាប់ជាតិនិយមទៅនឹងអនាគត មិនមែនភ្ជាប់ទៅនឹងអតីតកាល ហើយខ្ញុំគិតថា គាត់គិតត្រឹមត្រូវមែន ។ ជាតិទាមទារឲ្យមានការធ្វើពលិកម្មដើម្បីអនាគត ។ សូមសាកគិតពីរឿងនេះមួយភ្លែតមើល! ។ ឧបមា មានគេនិយាយថា សូមកុំកាប់ដើមឈើទាំងអស់របស់យើង ពីព្រោះតែចង់បានលុយ ។ យើងគួរតែថែរក្សាវាទុកឲ្យកូន និងចៅរបស់យើងប្រើប្រាស់ ប្រកបដោយក្ដីសប្បាយរីករាយ សុខភាព និងធ្វើសិប្បកម្ម ។ យើងគួរតែព្យាយាមរក្សារតនសម្បត្តិសិល្បៈ និងបូជនីយដ្ឋានទាំងអស់របស់យើង មិនមែនសម្រាប់តែខ្លួនយើងនោះទេ ពីព្រោះយើងនឹងស្លាប់នាពេលខាងមុខ ប៉ុន្តែសម្រាប់កូនចៅក្រោយៗ ទៀត ។ យើងគួរតែបង់ពន្ធ ដូច្នេះប្រទេសនេះនឹងអភិវឌ្ឍឈានឡើង សម្រាប់ពលរដ្ឋកម្ពុជាទាំងអស់ក្នុងរយៈពេល ៥០ ឬក៏ ១០០ ឆ្នាំខាងមុខទៀត ។ ប្រសិនបើយើងត្រូវធ្វើសង្គ្រាម គឺយើងប្រយុទ្ធដើម្បីអនាគតប្រទេសរបស់យើង ។ ឧទាហរណ៍នេះជួយពន្យល់ឲ្យយើងដឹងថា តើហេតុអ្វីបានជាគំនិតទាក់ទងនឹងការស្លាប់របស់ជាតិ គឺជាអ្វីម្យ៉ាង ដែលអាក្រក់ ហើយហេតុអ្វីបានជាពាក្យប្រល័យពូជសាសន៍ ការសម្លាប់ជាតិ ទើបតែត្រូវបានគេបង្កើតក្នុងពេលថ្មីៗ នេះ ។ ជាតិមួយមិនអាចស្លាប់បានទេ ហើយយើងទាំងអស់គ្នា មានភារកិច្ចធ្វើយ៉ាងណាកុំឲ្យជាតិរបស់យើងរលាយបាត់ ។

ការគិតបែបនេះ គឺជាគំនិតថ្មី ។ នៅសម័យបុរាណ មនុស្សដឹងថា សន្តតិវង្សស្ដេចអាចនឹងត្រូវបញ្ចប់នៅថ្ងៃណាមួយ ហើយរាជាណាចក្រក៏អាចនឹងរលាយបាត់ផងដែរ ។ ជាការពិតជាក់ស្ដែងណាស់ គឺគ្រាន់តែសៀវភៅរបស់លោកប៉ោអឺរ បោះពុម្ពហើយមួយឆ្នាំឬពីរឆ្នាំប៉ុណ្ណោះ មានរាជាណាចក្រ និងសន្តតិវង្សបុរាណជាច្រើនបានរលាយបាត់បង់ ។ ព្រឹត្តិការណ៍បែបនេះបានកើតឡើងដំបូងនៅចិន ក្នុងឆ្នាំ ១៩១១ បន្ទាប់មក នៅរុស្ស៊ី នៅឆ្នាំ ១៩១៧ ហើយចុងក្រោយ ក្នុងរវាងឆ្នាំ ១៩១៨-១៩ ចក្រភពអូតូម៉ង់នៅមជ្ឈិមបូព៌ា ចក្រភពអូទ្រីស-ហុងគ្រី និងចក្រភពអាឡឺម៉ង់នៅអឺរ៉ុបកណ្ដាល បានដួលរលំជាបន្តបន្ទាប់ ។ ក្រោយពីការដួលរលំទាំងនេះ គេឃើញមានការលេចឡើងនូវរដ្ឋទំនើបឯករាជថ្មីៗ ជាច្រើន មានដូចជា ប្រទេសប៊ុលហ្គារី ប៉ូឡូញ ហ្វាំងឡង់ ឆេកូស្លូវ៉ាគី អារ៉ាប៊ីសាឱីត និងរដ្ឋដទៃទៀត ។

ផលវិបាកដែលកើតមាននោះ គឺថា វាជាពេលដំបូងនៅក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដែលរបបរាជានិយមលែងជារបបទូទៅទៀតហើយ ។ សញ្ញាដ៏ជាក់ច្បាស់នោះ គឺការលេចឡើងនូវ «សម្ព័ន្ធប្រជាជាតិ» ភ្លាម ក្រោយការបញ្ចប់សង្គ្រាមលោកលើកទី ១ ។ ចាប់ពីពេលនោះមក មនុស្សគ្រប់រូបត្រូវបានគេរំពឹងថា ត្រូវតែរស់នៅក្នុង ប្រទេសដ៏ល្អរបស់ខ្លួន បើទោះជាចក្រភពបារាំង អង់គ្លេស ជប៉ុននិងអាមេរិកាំងនៅរស់រាននៅឡើយក៏ដោយ ។ ប៉ុន្តែ វាជាអ្វីម្យ៉ាង ដែលបានប្រែប្រួលយ៉ាងសម្បើម ។ យើងទាំងអស់គ្នាតែងតែគិតថា ប្រទេសរបស់យើងមានលក្ខណៈពិសេសខុសពីគេ ។ ប្រជាជនខ្មែរនិយាយថា មិនមានប្រទេសណា ដូចប្រទេសខ្មែរឡើយ ។ ជនជាតិថៃក៏គិតថា គ្មានប្រទេសណា ដូចប្រទេសថៃឡើយ ហើយជនជាតិព័រទុយហ្គាល់ក៏គិតដូចគ្នានេះដែរ ។ ប៉ុន្តែ ការកកើត «សម្ព័ន្ធប្រជាជាតិ» និងក្រោយមកទៀត មានការបង្កើត «អង្គការសហប្រជាជាតិ» បង្ហាញឲ្យឃើញថា ប្រជាជននានាមានលក្ខណៈដូចគ្នាច្រើន ដែលពួកគេអាចទទួលស្គាល់គ្នាថា ជាសមាជិកមានឋានៈស្មើគ្នា ។ បើប្រៀបធៀបរឿងនេះជាមួយការបង្កើតសាសនាសកលលោករួម ដែលយើងនឹកស្មានមិនដល់ ពីព្រោះ

តែសាសនាទាំងអស់សុទ្ធតែជឿថា ខ្លួនមានតម្លៃជាសកលរៀងៗខ្លួន ។ ដូច្នេះ សាសនាទាំងអស់សុទ្ធតែមានលក្ខណៈសាកលដូចគ្នា មិនដូចករណីជាតិទេ ពីព្រោះជាតិនីមួយៗ មានព្រំដែនដីផ្ទាល់រៀងៗខ្លួន ដែលជាតិដទៃទៀតត្រូវតែគោរព ។ មនុស្សជាច្រើននៅមិនទាន់សម្គាល់ថា ក្រោយសង្គ្រាមលោកលើកទី ២ និងក្រោយការបង្កើតអង្គការសហប្រជាជាតិមក មិនមានប្រជាជាតិណាមួយអាចទទួលបានដែនដីថ្មីតទៅទៀតឡើយ ។ មានប្រទេសថ្មីៗ បានកើតឡើងមែន ប៉ុន្តែ តាមរយៈការបំបែកចេញពីប្រទេសដែលមានពីមុនប៉ុណ្ណោះ ។ ជាឧទាហរណ៍ មានសហភាពរុស្ស៊ី យូហ្គូស្លាវី ឆេកូស្លូវ៉ាគី និងប៉ាគីស្ថាន ។ អ៊ីស្រាអែលបានកាន់កាប់ទឹកដីជាច្រើនរបស់ប៉ាលេស្ទីន ប៉ុន្តែ អង្គការសហប្រជាជាតិបដិសេធមិនទទួលស្គាល់សិទ្ធិរបស់អ៊ីស្រាអែលលើតំបន់នេះទេ ។ ឥណ្ឌូនេស៊ីបានព្យាយាមក្រសោបយកអតីតដែនដីអាណានិគមរបស់ព័រទុយហ្គាល់នៅទីម័រខាងកើត ។ ព្រឹត្តិការណ៍ទាំងនេះបង្ហាញឲ្យយើងឃើញថា ពីមួយពេលទៅមួយពេល ព្រំដែនជាតិកាន់តែក្លាយទៅជារបស់ពិសិដ្ឋ ។ ខ្ញុំអាចផ្តល់ជាឧទាហរណ៍ដ៏គួរឲ្យចង់សើច និងចម្លែកមួយ ។ នៅកំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ សហរដ្ឋអាមេរិកមានបញ្ហាហិរញ្ញវត្ថុជាច្រើន ហើយបារម្ភជាខ្លាំងពីការបាត់បង់អំណាច ទៅឲ្យប្រទេសជប៉ុន ដែលកំពុងតែមានជោគជ័យ ។ អាមេរិកក៏ជំពាក់បំណុលជប៉ុន និងប្រទេសដទៃទៀតយ៉ាងច្រើនផងដែរ ។ មានការពិភាក្សាមួយនៅក្នុងថ្នាក់ ហើយខ្ញុំបាននិយាយលេងសើចជាមួយសិស្ស ។ «នេះគឺជាបញ្ហាងាយស្រួលដោះស្រាយទេ ។ តើអ្នកនៅចាំទេថា តើអាមេរិកធ្វើយ៉ាងម៉េច ទើបបានអាឡាស្កាពីរុស្ស៊ីមក?» ពួកគេឆ្លើយថា «បាទ/ចាស! នៅចាំ ។ យើងទិញវាពីរុស្ស៊ីនៅឆ្នាំ ១៨៦៧ ។ តម្លៃវាពងថោកដែរ» ។ ពេលនោះ ខ្ញុំបានឆ្លើយតបវិញថា «ហេតុអ្វីបានជាអ្នកមិនលក់អាឡាស្កាទៅឲ្យជប៉ុនទៅ? អ្នកនឹងអាចទទួលបានកម្រៃយ៉ាងច្រើន និងអាចដោះបំណុលបានទៀតផង ។» កូនសិស្សមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយថែមទាំងខឹងទៀត ។ ពួកគេបានសួរបកឲ្យខ្ញុំវិញថា «តើយើងអាចលក់ផ្នែកមួយរបស់ប្រទេសយ៉ាងម៉េចបាន?» ។ បើទោះជាពួកគេដឹងថា អាមេរិកបានទិញអាឡាស្កាក៏ដោយ ក៏ពួកគេចង់បំភ្លេចរឿងនេះ ពីព្រោះនៅពេលនេះ អាឡាស្កាបានក្លាយជាទឹកដីពិសិដ្ឋ ដែលមិនអាចលក់ទៅឲ្យនរណាម្នាក់បានឡើយ ។

ទោះជាយ៉ាងណាក៏ដោយ មានភាពមិនប្រក្រតីពីរនៅក្នុងបញ្ជីប្រទេសនៅក្នុងសម្ព័ន្ធប្រជាជាតិ និងអង្គការសហប្រជាជាតិ ។ មានសមាជិកពីរដែលមិនដូចជាប្រជាជាតិធម្មតាសោះ ។ ទី ១ គឺសហរាជាណាចក្រមហាប្រ៊ីតាញ និងអៀរឡង់ខាងជើង[១] (រាជាណាចក្រអង់គ្លេស) ។ តាមរយៈឈ្មោះនៃប្រទេសនេះ អ្នកមិនអាចប្រាប់បានទេថា តើគេហៅឈ្មោះប្រជាជននៃប្រទេសនេះយ៉ាងដូចម្តេចនោះ ។ តើត្រូវហៅរាស្ត្រថា ជនជាតិមហាប្រ៊ីតាញ-អៀរឡង់ខាងជើង (Great Brito-Northern Irish) ឬ? វាមិនអាចទៅរួចនោះទេ ។ សហរាជាណាចក្រនេះ គឺជាសំណល់របស់ចក្រភពតាំងពីបុរាណកាលមកម៉្លេះ ។ ទី ២ គឺសហភាពសូវៀត ។ មានប្រជាជាតិជាច្រើននៅក្នុង

---

**(១)** កំណត់បណ្ណាធិការ ៖ ដែលខ្មែរហៅប្រទេសនេះថា « ប្រទេសអង់គ្លេស » ឬ « រាជាណាចក្រអង់គ្លេស » ជាការហៅមិនសមស្របឡើយ ព្រោះរាជាណាចក្រនេះ ចែកជាជាតិ ៤ ឬ រដ្ឋ ៤ ឬហៅ ប្រទេស ៤ ក៏បានដែរ ពោលគឺ អង់គ្លេស អៀរឡង់ខាងជើង អេកូស្ស និង ហ្គ័ល្ល (ឬហៅ វែលស៍ ក៏បានដែរ) ។ រដ្ឋអៀរឡង់ខាងជើង អេកូស្ស និងហ្គ័ល្ល មានសភាជាតិនិងរដ្ឋាភិបាលផ្ទាល់ខ្លួនរៀងៗខ្លួន ប៉ុន្តែចំណុះឲ្យរាជរដ្ឋាភិបាលនៃសហរាជាណាចក្រ ។ រីឯអង់គ្លេស ពុំមានរដ្ឋាភិបាលផ្ទាល់របស់ខ្លួនទេ គឺមានតែរាជរដ្ឋាភិបាលនៃសហ-រាជាណាចក្រដោយឡែក ។ ប្រជារាស្ត្រទាំងអស់នៅក្នុងសហរាជាណាចក្រ និយាយភាសាអង់គ្លេស ជនជាតិហ្គ័ល្លមានភាសារបស់ជាតិខ្លួន គឺ ភាសាហ្គ័ល្ល ដែលជាភាសាមួយក្នុងអម្បូរភាសាសិលត៍ ។ ចំណែកឯរដ្ឋអេកូស្ស ក្រៅពីភាសាអង់គ្លេស ក៏មានភាសាជាតិចំនួនពីរ គឺ ភាសាស្កុត្ស ក្នុងអម្បូរភាសាជាមួយភាសាអង់គ្លេស និងភាសាហ្គែលិក ជាភាសាក្នុងអម្បូរភាសាសិលត៍ ។

សហភាពនេះ ប៉ុន្តែមិនមែនជាប្រទេសមួយនោះទេ ។ នៅពេលដែលលោក លេនីន លោក ត្រុតស្គី និងលោក ស្តាលីន កាន់កាប់អំណាច និងក្រោយពីសង្គ្រាមស៊ីវិលដ៏បង្ហូរឈាម ដើម្បីបង្កើតសហភាពសូវៀតមក ពួកគេគិតថា រដ្ឋថ្មីនេះមិនមានព្រំដែនច្បាស់លាស់នោះទេ ។ មូលដ្ឋានរបស់រដ្ឋនេះ គឺជាការចាប់ផ្តើមបដិវត្តន៍ពិភពលោក ដែលមនុស្សមកពីគ្រប់ទីកន្លែងនៅក្នុងសកលលោក អាចចូលរួមជាមួយ ។ ពួកគេគិតថា សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត មានការរីកចម្រើនជាងរដ្ឋរុស្ស៊ីបុរាណ ។ ប៉ុន្តែ ប្រហែលជាមានមូលហេតុមួយ ដែលនាំឲ្យសហភាពសូវៀតដួលរលំនោះ ដោយសារតែវាមិនមែនជាជាតិមួយនោះទេ ហើយប្រជាជាតិដែលស្ថិតនៅក្នុងនោះ ចង់បានឯករាជ្យរៀងៗខ្លួន ។

ឥទ្ធិពលសំខាន់បន្ទាប់មកទៀតទៅលើការគិតអំពីជាតិនិយម លេចឡើងនៅកំលុងទសវត្សរ៍ឆ្នាំ ១៩៣០ ជាមួយនឹងការរះឡើងរបស់ពួកហ្វាស៊ីសហ៊ីត្លែរនៅអាល្លឺម៉ង់ និងចក្រភពយោធានិយមនៅជប៉ុន ។ របបទាំងពីរគឺជារបបជាតិនិយម និងប្រកាន់ពូជសាសន៍ ដែលពោរពេញទៅដោយអំពើហិង្សា និងបានចាប់ផ្តើមឈ្លានពានកាន់កាប់ប្រទេសជិតខាង ជាហេតុនាំឲ្យមានសង្គ្រាមលោកលើកទី ២ ។ របបទាំងនេះមិនមានអាយុកាលយូរនោះទេ ។ ក្នុងរយៈពេលកាន់អំណាចជាង ១២ ឆ្នាំ ហ៊ីត្លែរ បានបញ្ជាឲ្យសម្លាប់ជនជាតិជ្វីហ្វ ប៉ូឡូញ អ៊ុយក្រែន ជីបស៊ី (ហ្ស៊ីតង់) រុស្ស៊ី និងជាតិសាសន៍ដទៃទៀតអស់រាប់លាននាក់ ។ នៅពេលជំណាលគ្នានោះដែរ ជប៉ុនក៏ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ជីវិតមនុស្សរាប់លាននាក់នៅចិននិងអាស៊ីអាគ្នេយ៍ដែរ ។ ឥទ្ធិពលពីភាពសាហាវយង់ឃ្នង (នៅអឺរ៉ុប) នេះ បានបញ្ចុះតម្លៃជាតិនិយមឲ្យក្លាយទៅជារឿងអាក្រក់ ដែលមិនធ្លាប់កើតមានពីមុនមក ។ នេះគឺជាមូលហេតុនៃការបង្កើតសហគមន៍អឺរ៉ុប ដែលគេរំពឹងថា ជាតិនិយមគួរតែត្រូវបានទប់ស្កាត់ និងធ្វើឲ្យមានភាពចុះសម្រុងគ្នា នៅក្នុងចំណោមរដ្ឋនានា ។ ប៉ុន្តែ នៅអាស៊ីនិងអាហ្វ្រិក សង្គ្រាមលោកលើកទី ២ និងការផ្តួលរំលំរបបផ្តាច់ការនៅអាល្លឺម៉ង់ និងនៅជប៉ុន ពិតជាបានជួយជំរុញល្បឿននៃការលេចឡើងពួកចលនាជាតិនិយមឆ្វេងនិយមប្រឆាំងនឹងអាណានិគមនិយមនៅក្នុងតំបន់ទាំងនោះ ប្រកបដោយមោទនភាពយ៉ាងខ្ពស់អស់ពេលជាយូរមកហើយ ។ អំណាចរបស់ពួកជាតិនិយមឆ្វេងនិយមទាំងនេះ បានបង្ហាញឲ្យឃើញពីលទ្ធភាពដែលសហភាពសូវៀតមិនអាចពង្រីកព្រំដែនបានតទៅទៀត ហើយ ស្តាលីន និងអ្នកដឹកនាំបន្តបន្ទាប់ទៀត ត្រូវតែទទួលស្គាល់រដ្ឋកុម្មុយនិស្តឯករាជ មានដូចជា ចិន កូរ៉េខាងជើង វៀតណាម ឡាវ និងកម្ពុជា ដែលរដ្ឋភាគច្រើនមានអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិ ។ មូលហេតុចម្បងមួយ ដែលគាំទ្រដល់ជំហរនេះ គឺថា បក្សកុម្មុយនិស្តនៅតាមបណ្តាប្រទេសទាំងនោះ បានប្រយុទ្ធយ៉ាងស្វិតស្វាញ (ជាមួយនឹងទាហានផ្ទាល់ខ្លួន) ដើម្បីរំដោះជាតិ ។ ដំណើរវិវឌ្ឍន៍នេះបានចាប់ផ្តើមបញ្ចុះតម្លៃគំនិតរបស់ លេនីន ដែលគិតថា លទ្ធិកុម្មុយនិស្តពហុជាតិនឹងយកឈ្នះគំនិតជាតិនិយមបាន ។ នៅក្នុងឆ្នាំ ១៩៧៨-១៩៧៩ មានសង្គ្រាមត្រីកោណរវាងប្រទេសកុម្មុយនិស្ត ៣ មានកម្ពុជា វៀតណាម និងចិន ដែលពួកបុលស៊ីវិកចាស់មិនដែលនឹកនាដល់ ។

ការអភិវឌ្ឍទាំងអស់នេះ មានឥទ្ធិពលយ៉ាងខ្លាំងលើការគិតពីជាតិនិយម ដែលត្រូវតែចាត់ទុកថា ជាបាតុភូតសកលមួយ ។ គេមិនអាចគិតបែបឆោតៗថា ជាតិនិយមសុទ្ធតែល្អ និងមានការរីកចម្រើន ឬក៏ថា ជាតិនិយមគឺជាអ្វីម្យ៉ាងរបស់អឺរ៉ុប ឬក៏ថា សង្គមនិយមអន្តរជាតិអាចបង្ការសង្គ្រាមរវាងរដ្ឋសង្គមនិយមនោះទេ ។ បញ្ហាបន្ថែមនោះគឺថា នៅកំលុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ដែលធ្វើឲ្យគ្រប់គ្នាមានការភ្ញាក់ផ្អើល ដោយសារតែប្រជាជាតិចំណាស់ៗ ដូចជា បារាំង បែលហ្ស៊ិក អ៊ីតាលី និងសហអាណាចក្រ (អង់គ្លេស) បានប្រឈមនឹងចលនាជាតិនិយម

យ៉ាងខ្លាំងក្លា ដោយជនជាតិភាគតិចដែលធ្លាប់នៅស្ងៀមស្ងាត់ពីមុនមក មានដូចជា អៀរឡង់ គត្យ ប្រឺតុង ហ្វាម៉ង់ និងពួកអ៊ីតាលីភាគខាងជើង ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺ កន្លែងពិភាក្សាដ៏ធំលើប្រធានបទប្រជាជាតិនិងជាតិនិយម ដែលបានកើតឡើងពីឆ្នាំ ១៩៦៣ ដល់ឆ្នាំ ១៩៨៣ ។ អ្នកប្រហែលជាស្មានថា ការពិភាក្សានឹងត្រូវធ្វើឡើងនៅអាមេរិក ដែលមានសកលវិទ្យាល័យរាប់ពាន់ ឬក៏នៅបារាំង ដែលគេតែងចាត់ទុកថា ជាមជ្ឈមណ្ឌលអ្នកប្រាជ្ញនៅអឺរ៉ុប ។ ប៉ុន្តែការរំពឹងទុកនេះ មិនបានកើតឡើងឡើយ ។ រឿងគួរឲ្យងឿងឆ្ងល់នោះ គឺថា នៅអាមេរិកនៅកំលុងឆ្នាំនោះ គេមានបង្រៀនពីជាតិនិយមខ្លះៗ ប៉ុណ្ណោះ ហើយជនអាមេរិកមិនដែលគិតថា ពួកគេ គឺជាអ្នកជាតិនិយមឡើយ ។ ប៉ុន្តែ ពួកគេគិតថា ខ្លួនឯងជាអ្នកនាំយកតម្លៃសកល ដែលមនុស្សគ្រប់គ្នានៅក្នុងសកលលោក គួរតែធ្វើតាម ។ បារាំងអំពល់ចិត្តជាមួយនឹងមហន្តរាយ ដែលបណ្តាលមកពីសង្គ្រាមជាមួយប្រទេសអាល់ហ្សេរីនិងប្រជាជាតិនៅឥណ្ឌូចិន ហើយត្រូវតស៊ូជាមួយសហគមន៍អឺរ៉ុបទៀត ។ ដូច្នេះ ការពិភាក្សាត្រូវធ្វើឡើងនៅអង់គ្លេស ដែលមិនទាន់ជា «រដ្ឋប្រជាជាតិ» មួយនៅឡើយ ។ រាល់អ្នកចូលរួមដំបូងទាំងអស់ សុទ្ធតែជាពួកជ្វីហ្វ គ្រាន់តែពួកគេមានប្រភពផ្សេងៗ គ្នា ។ អ្នកចូលរួមទាំងនោះ មាន ប្រវត្តិវិទូនិងជនកុម្មុយនិស្ត៖ ហុបស្បោម (Hobsbawm), សង្គមវិទូនិងជាអ្នកសេរីនិយម ហ្គេលណឺរ (Gelner), ប្រវត្តិវិទូអភិរក្សមធ្យម ស្មីធ (Smith), និងប្រវត្តិវិទូស្តាំនិយម កេឌូរី (Kedourie) ។ លោក កេឌូរី កើតនៅអ៊ីរ៉ាក់ លោក ហុបស្បោម កើតនៅអេហ្ស៊ីប លោក ហ្គេលណឺរ កើតនៅឆេកូស្លូវ៉ាគី ហើយនិងលោក ស្មីធ កើតនៅក្រុងឡុងដ៍ ។ លោក ហ្គេលណឺរ ពិតជាអ្នកដែលមានទ្រឹស្តី និងមានឥទ្ធិពលជាងគេ ដែលបានលើកឡើងថា ជាតិនិយមជួយធ្វើឲ្យពិភពលោកសម័យទំនើបរបស់យើង ប្រែក្លាយពីសង្គមកសិកម្មទៅជាសង្គមឧស្សាហកម្ម ។ រាជានិយមនិងសាសនាមិនអាចធ្វើឲ្យសង្គមទាំងអស់រួមរស់នៅក្រោមឧស្សាហូបនីយកម្មឡើយ ។ លោក ហ្គេលណឺរ គិតថា ជាតិនិយមប្រៀបដូចជាប្រេងសាំង ដែលជួយឲ្យរថយន្តទំនើបកម្មមានចលនាបាន ។ ប៉ុន្តែ គំនិតនេះពិបាកនឹងឲ្យមនុស្សទទួលយកណាស់ ។ អ្នកខ្លះនិយាយថា ចលនាជាតិនិយមដំបូងកើតឡើងនៅអឌ្ឍគោលខាងលិច នៅរវាងឆ្នាំ ១៧៧៥ និង ១៨២៥ នៅពេលដែលឧស្សាហូប-នីយកម្មមិនទាន់បានកើតឡើងនៅទីនោះផង ។ អ្នកផ្សេងទៀតដូចជា អែនថូនី ស្មីធ បដិសេធថា ជាតិនិយមមិនមែនជារឿងទំនើបឡើយ ។ ក្នុងនាមជាជនជាតិជ្វីហ្វ គាត់បាននិយាយថា ប្រជាជាតិជ្វីហ្វកើតមានតាំងពីរាប់ពាន់ឆ្នាំមកហើយ ។ ជាតិនិយមមិនមែនជារឿងសម័យថ្មីនេះទេ ពោលគឺវាមានមូលដ្ឋានលើភាសា វប្បធម៌ និងជំនឿសាសនាចាស់ៗ ដែលគេគ្រាន់តែកែប្រែខ្លះៗ នៅសម័យថ្មីនេះប៉ុណ្ណោះ ។ ប្រសិនបើអ្នកលើកឧទាហរណ៍ពីពួកអ្នកជាតិនិយមវៀតណាម ដែលនិយាយថា ប្រជាជាតិវៀតណាមមានអាយុកាល ៤ ពាន់ឆ្នាំ លោក ស្មីធ ប្រហែលជាពេញចិត្ត ប៉ុន្តែ លោក ហ្គេលណឺរ វិញ ប្រហែលជាសើច ។ អ្នកសរសេរពីទ្រឹស្តីជាតិនិយមភាគច្រើន បានប្រកាន់យកគំនិតម្ខាង ឬក៏ប្រកាន់យកទាំងសងខាង ។

ឥឡូវនេះ នៅក្នុងការពិភាក្សារបស់ពួកយើង ខ្ញុំនឹងលើកយ៉ាងខ្លីពីរបៀបដែលខ្ញុំពាក់ព័ន្ធនឹងការពិភាក្សាជាសាធារណៈនេះ ។ មកត្រឹមទសវត្សរ៍ឆ្នាំ ១៩៧០ ខ្ញុំបានចំណាយពេល ២០ ឆ្នាំរួចទៅហើយសិក្សាពីអាស៊ីអាគ្នេយ៍ ពិសេសសិក្សាពីឥណ្ឌូនេស៊ីជាផ្នែកមួយរបស់ទ្វីបអាស៊ី ដែលពួកអាមេរិកនិងអឺរ៉ុបភាគច្រើនបានដឹងតិចតួចពីប្រទេសនេះ ។ ខ្ញុំយល់ថា គ្មានទ្រឹស្តីជាតិនិយមណា ដែលសិក្សាតែលើសង្គមនៅអឺរ៉ុបណាមួយ អាចគ្រប់គ្រាន់នោះទេ ពោលគឺ យើងត្រូវតែសិក្សាលើពិភពលោកទាំងមូល ។ ខ្ញុំក៏បានសន្និដ្ឋានថា ទ្រឹស្តីដែលមានជាច្រើន

មិនអាចពន្យល់ថា ហេតុអ្វីបានជាប្រជាជនមានមនោសញ្ចេតនាយ៉ាងខ្លាំងជាមួយនឹងជាតិ និងថែមទាំងហ៊ានបូជាជីវិតដើម្បីបុព្វហេតុជាតិទៀតផង ។ រហូតដល់ពេលនោះ គ្រប់គ្នាមើលឃើញជាតិនិយមថា ជាមនោគមវិជ្ជា ដូចជាទ្រឹស្តីសង្គមនិយម អនាធិបតេយ្យនិយម អភិរក្សនិយម សេរីនិយម ។ល។ ដែលទ្រឹស្តីទាំងអស់នេះពាងាយពន្យល់ ។ ប្រសិនបើជាតិនិយមពិតជាដូចនឹងទ្រឹស្តីទាំងនោះមែន ហេតុអ្វីបានជាវាពិបាកពន្យល់ម្ល៉េះ ? ដូច្នេះជាតិនិយម ប្រហែលជាមិនដូចទ្រឹស្តីទាំងនោះទេ ។ វាអាចដូចនឹងអ្វីផ្សេងទៀត ។ តែរឿងដែលគួរឲ្យចាប់អារម្មណ៍មួយពីជាតិនិយម គឺទំនាក់ទំនងរបស់វាជាមួយនឹងមរណភាព ។ បូជនីយដ្ឋានជាតិភាគច្រើនត្រូវគេសង់ឡើង ដើម្បីឧទ្ទិសដល់វីរបុរសដែលបានពលីជីវិត ។ យើងគិតថា «ពួកគេស្លាប់ដើម្បីពួកយើង ហើយយើងប្រហែលជាត្រូវពលីជីវិត ដើម្បីអ្នកជំនាន់ក្រោយរបស់យើង ។ យើងដឹងថា យើងនឹងស្លាប់នៅថ្ងៃណាមួយ ប៉ុន្តែប្រជាជាតិរបស់យើង (កម្ពុជា ស៊ុយអែត នីហ្សេរីយ៉ា ។ល។) មិនអាចបាត់បង់បានទេ ។ ដូច្នេះ យើងគួរសាមគ្គីគ្នា ដើម្បីអមតភាពរបស់ជាតិយើង ។» មនោគមវិជ្ជាមិនបានផ្តល់អមតភាពយ៉ាងដូចនេះទេ មានតែនៅក្នុងសាសនាទេ ទើបមាន ។ ដូច្នេះ ខ្ញុំគិតថា យើងប្រហែលជាត្រូវចាត់ទុកជាតិនិយមប្រៀបដូចជាសាសនា មិនមែនដូចជាទ្រឹស្តីសេរីនិយមនោះទេ ។ បន្ទាប់មក យើងអាចមើលឃើញថា ហេតុអ្វីមនុស្សជ្រួលអារម្មណ៍ខ្លាំងជាមួយនឹងជាតិនិយមម្ល៉េះ ។ នៅមានរឿងចម្លែកមួយទៀតមានសារៈសំខាន់គួរយកមកពិចារណា ។ ប្រសិនបើអ្នកមានអារម្មណ៍ស្រឡាញ់ខ្មែរ ហើយអ្នកចង់ធ្វើអ្វីម្យ៉ាងដើម្បីពួកគេ អ្នកប្រហែលជាសួរខ្លួនឯងថា តើខ្ញុំស្គាល់ឈ្មោះប្រជាជនខ្មែរបានប៉ុន្មាននាក់ ? ប្រសិនបើអ្នកពូកែចាំ អ្នកអាចចាំឈ្មោះបានប្រហែល ៣០០ នាក់ ។ ប៉ុន្តែអ្នកពិតជាមិនបានស្គាល់ប្រជាជនខ្មែររាប់លាននាក់ទៀតឡើយ ។ អ្នកមិនស្គាល់ឈ្មោះរបស់ពួកគេ អ្នកមិនដឹងថា ពួកគេរស់នៅឯណា អ្នកមិនដឹងថា ពួកគេធ្វើកិច្ចការអ្វីឡើយ និងរឿងរ៉ាវផ្សេងទៀតដែលអ្នកមិនដឹង ។ នៅទីនេះ ចម្លើយគឺថា ជាតិមានស្ថានភាពពិសេសម្យ៉ាង ដែលខ្ញុំហៅថា ការស្មាន (imagined) ។

យើងម្នាក់ៗ ត្រូវមានគំនិតថា យើងជាខ្មែរ ។ ប៉ុន្តែ តើវាជ្រាបចូលទៅក្នុងខួរក្បាលមនុស្សយ៉ាងដូចម្តេច ? ហេតុអ្វីបានជាយើងគិតថា វាជារឿងពិត ? ប្រសិនបើព្រឹកស្អែក អ្នកចង់ចេញទៅខាងក្រៅ ដើម្បីជួបប្រជាជនកម្ពុជា ដើម្បីនិយាយជាមួយពួកគេ នោះអ្នកមិនអាចធ្វើបានទេ ។ អ្នកមិនអាចមើលឃើញប្រទេសកម្ពុជាទេ ប្រសិនបើអ្នកមិនឡើងលើមេឃ ចូលទៅក្នុងផ្កាយរណប ពោលគឺអ្នកអាចមើលឃើញពីខាងលើ ។ ប៉ុន្តែ អ្នកនៅមិនទាន់អាចមើលឃើញថា តើកម្ពុជាចាប់ផ្តើមនៅចំណុចណា និងបញ្ចប់នៅទីណានោះទេ ។ មធ្យោបាយតែម្យ៉ាងដែលអ្នកអាចមើលឃើញប្រទេសកម្ពុជា គឺតាមរយៈផែនទីដែលគ្រាន់តែជារូបភាពមួយ ដែលមិនមែនជាសច្ចភាពសោះ ។ អ្នកមើលផែនទី ហើយលាន់មាត់ថា «អ្ហ៎! ប្រទេសកម្ពុជា» ។ អ្នកមើលរូបគំនូរ ហើយលាន់មាត់ថា «អ្ហ៎! ប្រទេសកម្ពុជា» ។ អ្នកមើលរូបភាពប្រាសាទអង្គរវត្ត ហើយលាន់មាត់ថា «អ្ហ៎! ប្រទេសកម្ពុជា» ។ ប៉ុន្តែ អ្នកមិនអាចមើលឃើញកម្ពុជាពិតនោះទេ ។

ស្ថានភាពរបស់ជាតិ គឺប្រៀបដូចជាប្រលោមលោកមួយដ៏លន្លង់លន្លោច ។ នៅពេលអ្នកអានប្រលោមលោក អ្នកផ្តោតអារម្មណ៍ជាប់លើតួឯកប្រុសស្រីនៅក្នុងរឿង ។ អ្នកចង់អានបន្ត ពីព្រោះអ្នកចង់ដឹងថា ទៅមុខទៀតមានរឿងអ្វីកើតឡើង ។ អ្នកដឹងថា តួឯកក្នុងរឿង មិនមានពិតនោះទេ ប៉ុន្តែ នៅពេលជំណាលគ្នានឹងការអាននេះដែរ អ្នករំភើប និងមានអារម្មណ៍ជាប់លើតួឯកស្រី ។ អ្នកមានអារម្មណ៍អាណិតអាសូរតួឯងទាំងនោះផង សរសើរតួឯកទាំងនោះផង ពួកគេនៅក្នុងភាពស្រមើស្រមៃរបស់អ្នក ។ អ្នកពិតជាយល់ថា តួឯកមានមែន ។ យើងអាច

*យល់ពីជាតិតាមរបៀបដូចគ្នានេះផងដែរ ។ ប្រសិនបើអ្នកមិនអាចស្រមៃពីជាតិទេនោះ ជាតិមិនមានទេ ។ នេះគឺជាគំនិតដ៏លំបាក ពីព្រោះមនុស្សមួយចំនួនគិតថា ប្រសិនបើអ្នកនិយាយថា «ស្រមើស្រមៃ» វាមានន័យថា មិនមែនជាការពិតនោះទេ ។ នៅក្នុងភាសាអង់គ្លេស យើងប្រើពាក្យផ្សេងៗ ÷ «ការស្រមើស្រមៃ»* (imaginary) *សម្រាប់អ្វីម្យ៉ាងដែលវាពិតជាមិនមាន ដូចជា សត្វនាគ ជាដើម ។ ប៉ុន្តែ ពាក្យ «ស្មាន»* (imagined) *គឺជាអ្វីម្យ៉ាងពិត ពីព្រោះវាមាននៅក្នុងខួរក្បាលរបស់អ្នក ហើយនិងមាននៅក្នុងចិត្តរបស់អ្នកផងដែរ ។ អ្នកមិនអាចឃើញកម្ពុជានោះទេ ប៉ុន្តែ អ្នកអាចស្រមៃឃើញប្រទេសនេះគ្រប់ពេលវេលា ពីភាពអស្ចារ្យ កន្លែងល្បីៗ ប្រវត្តិសាស្ត្រ បទចម្រៀង ភាពយន្ត កំណាព្យ និងសោកនាដកម្មនៅក្នុងប្រទេសនេះ ។*

## សំណួរ-ចម្លើយ

***សំណួរ ៖*** *ប្រសិនបើជាតិ គឺជារបស់អរូបី តើពួកអ្នកនយោបាយធ្វើយ៉ាងម៉េច ទើបអាចយកជាតិទាក់ទាញអារម្មណ៍មនុស្សបានច្រើនម្ល៉េះ ?*

**លោកគ្រូ បេន (បេនិឌិកត៍ អាន់ដឺរសុន) ៖** *ពីព្រោះតែយើងមានការស្រមើស្រមៃ ។ ខ្ញុំសូមលើកឧទាហរណ៍មួយ ដែលប្រហែលជាឧទាហរណ៍អាក្រក់មួយ ។ អ្នកទាំងអស់គ្នាសុទ្ធតែធ្លាប់ដឹងពីស្តេច ជយវរ្ម័ន ទី ៧ ប៉ុន្តែ អ្នកមិនដែលបានជួបទ្រង់ទេ ហើយអ្នកក៏មិនដឹងថា ទ្រង់មានកម្ពស់ត្រឹមណានោះទេ ។ យើងមិនដឹងថា តើទ្រង់ចូលចិត្តសោយអ្វី ? ទ្រង់សព្វព្រះរាជហឫទ័យនឹងបទចម្រៀងប្រភេទណា ? និយាយរួមទៅ យើងមិនបានដឹងពីស្តេចខ្មែរនៅសម័យបុរាណទាល់តែសោះ ។ យើងមិនអាចមានទំនាក់ទំនងផ្ទាល់ជាមួយនឹងពួកព្រះអង្គទេ ។ យើងមិនអាចនិយាយជាមួយពួកទ្រង់ឡើយ ។ យើងមិនអាចរាយការណ៍ពីទស្សនៈរបស់ពួកទ្រង់ឡើយ ប៉ុន្តែ យើងជឿច្បាស់ថា ពួកទ្រង់មានសារៈសំខាន់ណាស់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ យើងត្រូវតែរកមើលរឿងរ៉ាវផ្សេងៗ តាមរយៈស្នាព្រះហស្តរបស់ពួកទ្រង់ដូចជា ចម្លាក់ អត្ថបទចារឹកនៅអង្គរ ។ ពួកព្រះអង្គគឺជានិមិត្តរូបអាថ៌កំបាំង ពីព្រោះពួកព្រះអង្គរស់នៅក្នុងពិភពមួយ ដែលខុសគ្នាទាំងស្រុងពីពិភពដែលយើងកំពុងរស់នៅ ។ នេះគឺជារឿងពិត នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិទាំងអស់ ។*

*នៅមានរឿងមួយផ្សេងទៀត ដែលខ្ញុំគិតថា វាសំខាន់ណាស់ ដែលអ្នកត្រូវយល់នោះគឺការផ្លាស់ប្តូរនៅក្នុងមនសិការ ។ ខ្ញុំនឹងលើកឧទាហរណ៍ដ៏គួរឲ្យចាប់អារម្មណ៍ និងសាមញ្ញមួយ ។ មានព្រះវិហារសាសនាគ្រិស្តដ៏ល្បីល្បាញមួយនៅបារាំង ស្ថិតនៅសាត្រេស៍* (Chartres) *នៅខាងត្បូងទីក្រុងប៉ារីស ។ ព្រះវិហារនេះពិតជាស្អាតខ្លាំងណាស់ លម្អទៅដោយបង្អួចកញ្ចក់និងគំនូរផ្សេងៗ ។ វិហារនេះ កសាងឡើងនៅពេលដំណាលគ្នានឹងអង្គរវត្តផងដែរ ។ សព្វថ្ងៃនេះ ប្រសិនបើអ្នកសួរជនជាតិបារាំងថា «តើអ្នកគិតថា វិហារសាត្រេស៍យ៉ាងម៉េចដែរ ?» ពួកគេគ្រាន់តែនិយាយថា «សាត្រេស៍បានបង្ហាញឲ្យឃើញពីភាពអស្ចារ្យ និងលេចធ្លោរបស់បារាំង» ។ បន្ទាប់មក អ្នកនិយាយថា «តាមពិតទៅ នៅ ស.វ. ទី ១២ មិនមានជនជាតិបារាំងទេ ។ គេសង់វិហារនេះឡើង ដើម្បីធ្វើជាព្រះវិហារគ្រិស្ត ។ វិហារនេះកសាងឡើង មិនមែនដើម្បីជនជាតិបារាំងទេ ប៉ុន្តែ ដើម្បីព្រះអាទិទេព ។» អ្វីដែលគួរឲ្យចាប់អារម្មណ៍ពីការឆ្លើយតបរបស់ពួកគេ គឺជាអ្វីម្យ៉ាងដែលធ្លាប់មានទំនាក់ទំនងជាមួយព្រះអាទិទេព និងមាន*

*លក្ខណៈអភិធម្មជាតិ ស្រាប់តែឥឡូវ បានផ្លាស់ប្ដូរក្លាយជាវត្ថុសិល្បៈ ដែលមិនមែនសម្រាប់សាសនា (ដូចមុន) ហើយមានទេសចរពីជុំវិញពិភពលោកមកទស្សនា ។ សំណួររបស់ខ្ញុំ គឺថា ប្រសិនបើអ្នកមើលអង្គរវត្ត តើអ្នកគិតថា ប្រាសាទនេះសង់ឡើង ដើម្បីបង្ហាញពីភាពអស្ចារ្យរបស់ប្រជាជនខ្មែរឬ ? តើអង្គរគឺជាតឹកតាងនៃការច្នៃប្រឌិតរបស់ប្រជាជនខ្មែរឬ ? ឬក៏ជាអ្វីមួយផ្សេងទៀត ? នៅពេលអ្នកធ្វើដំណើរទៅអង្គរវត្ត តើអ្នកមើលអ្វី ? នៅក្នុងឆន្ទៈអ្វី ? ខ្ញុំចង់ដឹងថា តើអ្នកគិតបែបណា ? តើអារម្មណ៍របស់អ្នកចំពោះទីស្ថានមួយនេះ មានលក្ខណៈសាសនា ឬជាលក្ខណៈជាតិ?*

*នៅក្នុងបរិបទជាតិ និងជាតិនិយម វាក៏ជាគន្លឹះដ៏សំខាន់នៃគំនិតស្ដីអំពីសមភាព ដែលភ្ជាប់ទៅនឹងខ្សែស្រឡាយមិនពិត ។ ពិតណាស់ គំនិតបែបនេះ ពិតជាប្រឆាំងនឹងប្រពៃណីឋានានុក្រម ពិសេសរាជានិយម ។ សូមព្យាយាមស្ដាប់សុន្ទរកថារបស់មេដឹកនាំរបស់អ្នកនៅតាមវិទ្យុ ។ ពួកគេនឹងមិនហៅអ្នកថា កូនចៅ ឬក៏កសិករជាទីរាប់អាន ឬក៏មនុស្សជាទីស្រឡាញ់ទេ ។ ពួកគេនឹងហៅអ្នកថា បងប្អូនខ្មែរប្រុសស្រី ។ ខ្ញុំជឿថា អ្នកដឹងថា នៅក្នុងប្រទេសជាច្រើន គេអូសបន្លាយពេលយូរណាស់ មុនពេលគេអនុញ្ញាតឲ្យស្ត្រីបោះឆ្នោត ពីព្រោះគេចាត់ទុកស្ត្រីជាមនុស្សបន្ទាប់បន្សំ និងល្ងង់ខ្លៅ ។ ប៉ុន្តែ នៅពេលដែលស្ត្រីចាប់ផ្ដើមមានការរៀបចំបានល្អ ការទាមទារដ៏ខ្លាំងក្លារបស់ពួកគេ មិនមែនជាការទាមទារសិទ្ធិស្ត្រីជាសកលនោះទេ ប៉ុន្តែ វាជាសមភាពជាតិទៅវិញទេ ។ យើងទាំងអស់គ្នាជាស្ត្រី ហើយក៏ជាជនជាតិអៀរឡង់ ឥណ្ឌា ឬក៏វៀតណាមដែរ ម្ដេចក៏អ្នកបង្ខាំងមិនឲ្យបោះឆ្នោត ? ពួកយើងគឺជាបងប្អូនស្រីរបស់អ្នក មិនមែនជាទាសករឡើយ ។ ការអះអាងបែបនេះ ក៏មានប្រើជាមួយក្រុមរើសអើងពូជសាសន៍ដទៃទៀតផងដែរ ។ សូមមើលឧទាហរណ៍ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី អូបាម៉ា នៅអាមេរិក ។ រឿងបែបនេះមិនអាចកើតឡើងបានទេ កាលពី ១៥ ឆ្នាំមុន ។ គន្លឹះដ៏សំខាន់នោះគឺថា លោកជាជនជាតិអាមេរិកាំង មិនមែនជាជនស្បែកខ្មៅទេ ហើយក្នុងនាមជាជនជាតិអាមេរិក លោកមានសិទ្ធិឈរឈ្មោះធ្វើជាប្រធានាធិបតីដូចជនឯទៀតដែរ ។*

*ប្រសិនបើអ្នកក្រឡេកមើលទៅលើនយោបាយរបស់ថៃនាពេលថ្មីៗ នេះ អ្នកយល់ឃើញថា វាមិនមែនជារឿងធម្មតានោះទេ ។ ពួកបាតុករស្ដាំនិយមវណ្ណៈកណ្ដាល ដែលបានបិទព្រលានយន្តហោះនៅបាងកក អស់ជាងពីរខែ បានបញ្ជាក់ជាសាធារណៈថា ប្រជាជនថៃនៅជនបទ គឺជាមនុស្សល្ងង់ និងមិនដឹងអ្វី ដែលមិនគួរឲ្យមានសិទ្ធិបោះឆ្នោតដូចពួកវណ្ណៈកណ្ដាលឡើយ ។ នៅក្នុងន័យម្យ៉ាងទៀត គឺថា ប្រជាជននៅក្នុងជនបទមានឋានៈតូចទាបជាពួកបាងកក ។ ពួកគេចង់ប្ដូររដ្ឋធម្មនុញ្ញ ដើម្បីឲ្យប្រាកដថា មនុស្សវណ្ណៈទាបទាំងនោះ មិនអាចជ្រើសរើសរដ្ឋាភិបាលបាន ។ ការប្រកាសបែបនេះបង្ហាញឲ្យឃើញថា ជាតិនិយមរបស់ថៃ នៅមិនទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ និងចាស់ទុំនៅឡើយទេ ។ នៅកន្លែងផ្សេងទៀតវិញ មនុស្សមិនអាចនិយាយពាក្យទាំងអត់អៀនខ្មាស់បែបនេះឡើយ ។*

**សំណួរ៖** *តើលោកគ្រូអាចពន្យល់ពីជាតិនិយមនៅកម្ពុជាបានយ៉ាងដូចម្ដេច តាមរយៈការប្រើប្រាស់និយមន័យរបស់លោកគ្រូ ?*

**លោកគ្រូបេន៖** *សូមចាប់ផ្ដើមនិយាយអំពីអក្ខរកម្ម ។ សព្វថ្ងៃ មានប្រជាជនកម្ពុជាប្រមាណ ៧០ ភាគរយ អាចអាននិងសរសេរបាន ។ អត្រានេះវាខ្ពស់ជាងនៅអង់គ្លេសកាលពី ស.វ. ទី ១៩ ទៅទៀត ។ ពួកគេមិនត្រឹមតែអាចអានសៀវភៅ និងទស្សនាវដ្ដីនោះទេ ប៉ុន្តែ ពួកគេនៅអាចមើលទូរទស្សន៍ និងស្ដាប់វិទ្យុថែមទៀត ។*

ប្រសិនបើអ្នកសួរខ្ញុំថា តើខ្ញុំបានរួមចំណែកអ្វីខ្លះដល់ទ្រឹស្តីជាតិនិយម ចម្លើយរបស់ខ្ញុំ គឺត្រូវតែផ្តោតជាចម្បងជាមួយនឹងការអាន ។ ការលើកឡើងរបស់ខ្ញុំ គឺថា ជាតិនិយមមិនអាចកើតបានទេ ប្រសិនបើគ្មានធាតុ ដែលខ្ញុំហៅថា «មូលធននិយមផ្នែកបោះពុម្ព» (print capitalism) ។ នេះគឺជារឿងមួយ ដែលសូម្បីតែ ម៉ាក្ស ក៏មិនបានចាប់អារម្មណ៍ដែរ ។ ពិតណាស់ សៀវភៅគឺជារបស់របរដូចជា ចាន ស្ករ និងសាប៊ូ ប៉ុន្តែ សៀវភៅមិនមែនគ្រាន់តែជាវត្ថុដែលមានរូបរាងដូចរបស់ដទៃនោះទេ ។ នៅក្នុងសៀវភៅ មានបង្កប់នូវគំនិត និងសារជាច្រើន ។ ប៉ុន្តែ គេមិនអាចថតចម្លង និងលក់សៀវភៅឲ្យទូលំទូលាយ មុនការបង្កើតម៉ាស៊ីនបោះពុម្ព និងការកើនឡើងពួកមូលធន ដែលជាអ្នកលក់សៀវភៅ និងអ្នកចែកចាយសៀវភៅបានឡើយ ។ ប៉ុន្តែ ដើម្បីលក់បានច្រើន គេត្រូវសរសេរសៀវភៅ ដោយប្រើភាសា ដែលអ្នកទិញអាចអានបាន ។ ស្ថាបនិកគំនិតជាតិនិយម គឺអ្នកដែលអាចអានសៀវភៅបោះពុម្ពជាភាសាជាតិខ្លួន ជាពិសេសក្នុងចំណោមជនជាតិខ្មែរ ។ នៅ ស.វ. ទី ២០ ដំបូង យើងមានវិទ្យុ ក្រោយមក មានទូរទស្សន៍ ។ វិទ្យុនិងទូរទស្សន៍នេះ បង្កើតឡើង ដើម្បីបន្ថែមលើសៀវភៅនិងកាសែត ។ នៅកំលុងទសវត្សរ៍ឆ្នាំ ១៩៤០ ពួកមេដឹកនាំវៀតណាម គឺជាអ្នកដែលស្ថិតនៅក្នុងចំណោមមនុស្សដែលដឹងថា មានតែតាមរយៈវិទ្យុទេ ទើបពួកគេអាចអំពាវនាវដល់ប្រជាជនរាប់លាននាក់ ដែលមិនចេះអក្សរ ។ ក្នុងពេលដំណាលគ្នានេះដែរ មេដឹកនាំជាតិនិយមឥណ្ឌូនេស៊ី ក៏យល់ឃើញដូចនេះដែរ ។ ជាតិនិយមកម្ពុជាអាចកើតឡើងបាន ក៏ដោយសារតែមានការបោះពុម្ពផ្សាយនៅចុងសម័យអាណានិគម ។ យើងអាចមើលឃើញរឿងនេះ តាមរយៈតួនាទីដ៏សំខាន់របស់ខ្មែរក្រោមនៅកូសាំងស៊ីន ពិសេសនៅជុំវិញព្រៃនគរ ជាកន្លែងដែលមានសៀវភៅនិងកាសែតជាច្រើន និងសាលារៀនដែលកូនសិស្សអាចរៀនអាននិងសរសេរ ។ ជាតិនិយមនេះបានរីកសាយភាយ ពីតំបន់ដីសណ្តទន្លេមេគង្គ តាមទន្លេ មកកាន់ក្រុងភ្នំពេញ ចូលទៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ និងកន្លែងដទៃទៀត ។ បិតាជាតិនិយមខ្មែរ លោក សឺន ង៉ុកថាញ់ ដែលជាខ្មែរក្រោមសាមញ្ញមួយរូប មិនមែនជាពួកវណ្ណៈខ្ពង់ខ្ពស់នៅភ្នំពេញឡើយ ។

**សំណួរ ៖** *តើលោកគ្រូអាចពន្យល់បានខ្លះទេ អំពីអង្គការក្នុងតំបន់របស់ប្រជាជាតិមួយចំនួន មានដូចជា សហភាពអឺរ៉ុប អាស៊ាន និងសហព័ន្ធអាហ្វ្រិក ?*

**លោកគ្រូបេន ៖** តាមពិត គំនិតបង្កើតអង្គការនេះ កើតចេញពីប្រតិកម្មតបទៅនឹងបទពិសោធន៍យ៉ាងអាក្រក់នៅអឺរ៉ុប ដែលបង្កឡើងដោយសង្គ្រាមលោកទាំងពីរលើក នៅឆ្នាំ ១៩១៤–១៩១៨ និង ១៩៣៩–១៩៤៥ ដែលមនុស្សរាប់លាននាក់ត្រូវបានសម្លាប់ ។ មនុស្សជាច្រើននិយាយថា យើងមិនអាចបណ្តោយឲ្យរឿងនេះ កើតឡើងជាថ្មីម្តងទៀតឡើយ ។ ដូច្នេះ គំនិតជាមូលដ្ឋានសម្រាប់សហគមន៍នេះ គឺដើម្បីការពារសង្គ្រាមផ្សេងទៀត ដែលអាចកើតនៅអឺរ៉ុប ។ ដំបូងឡើយ គេបានបង្កើតផែនការសហគមន៍សេដ្ឋកិច្ច ដោយរំពឹងថា សមាហរណ៍កម្មសេដ្ឋកិច្ចអាចនាំឲ្យមានសមាហរណ៍កម្មនយោបាយ ដែលអាចដំណើរការទៅមុខបានយ៉ាងយូរ ។ មនុស្សមួយចំនួនថែមទាំងជឿថា ប្រសិនបើសហគមន៍នេះទទួលបានជោគជ័យ ជាតិនិយមនៅអឺរ៉ុបអាចជៀសវាងបាន ។ ដូចអ្នកបានដឹងហើយថា សព្វថ្ងៃនេះ សមាហរណ៍កម្មសេដ្ឋកិច្ចនៅអឺរ៉ុប បានដើរទៅមុខយ៉ាងឆ្ងាយ ប៉ុន្តែ ការរំពឹងដែលថា ជាតិនិយមនៅអឺរ៉ុបអាចនឹងរលត់បាត់ បង្ហាញឲ្យឃើញថា នេះគឺជាការយល់ខុសដ៏ធំមួយ ។ សមាជិកសហភាពអឺរ៉ុបមួយចំនួន

មិនទទួលយកលុយ អឺរ៉ូ ឬ យូរ៉ូ ហើយសូម្បីតែប្រទេសមួយចំនួនដែលទទួលយកលុយអឺរ៉ូ ក៏នៅតែទទូចសុំឲ្យមាននិមិត្តសញ្ញាជាតិនៅលើរូបិយវត្ថុក្នុងស្រុករបស់ពួកគេ ។ សហភាពអឺរ៉ុបមិនមានប្រធានាធិបតី ហើយមានអំណាចយោធាតិចតួច ។ ដូច្នេះ មានរឿងចំអកលេងថា សហភាពអឺរ៉ុប គឺជាយក្សសេដ្ឋកិច្ច ក្មេងច្រមក់នយោបាយ និងមនុស្សតឿទាហាន ។ ប៉ុន្តែ សហភាពអឺរ៉ុបបានដើរទៅឆ្ងាយជាងសហភាពនៅក្នុងតំបន់ដទៃទៀត ។ ប្រសិនបើអ្នកមើលទៅអាមេរិកខាងត្បូង អាហ្វ្រិក និងអាស៊ីអាគ្នេយ៍ មានការសម្របសម្រួលមួយចំនួន ពិសេសលើវិស័យសេដ្ឋកិច្ច ប៉ុន្តែ អំណាចនយោបាយនិងយោធាមិនមានប្រសិទ្ធភាពឡើយ ។ ប្រទេសជាសមាជិកភាគច្រើនទើបតែទទួលបានឯករាជ្យថ្មីៗ ម្ល៉ោះហើយមានកម្រិតជាតិនិយមខ្ពស់ ដែលមិនមានឆន្ទៈបោះបង់ចោលអធិបតីភាពរបស់ពួកគេ ដើម្បីមូលហេតុសេដ្ឋកិច្ចឡើយ ។ លោកគ្រូ ឆានវិត ក:សេតសុរិ (ជាញវិទ្យ ក្សេត្រសិរិ) តែងតែនិយាយលេងថា អាស៊ានប្រៀបដូចជាពិធីជប់លៀងស្រាមិនចេះចប់ មិនចេះហើយ សម្រាប់អគ្គរដ្ឋទូតរបស់ខ្លួន ។

តើមាននរណាអាចឆ្លើយសំណួរពីខាងដើមរបស់ខ្ញុំបានដែរឬទេ ? ខ្ញុំចង់ដឹងថា តើអ្នកនឹងនិយាយអ្វី ។ ពេលដែលអ្នកទៅអង្គរវត្ត តើអ្នកយល់ឃើញយ៉ាងម៉េច ?

**សំណួរ ៖** ខ្ញុំចង់ឃើញប្រវត្តិសាស្ត្រនៅតាមជញ្ជាំងប្រាសាទ ។ ក្នុងនាមជាខ្មែរ យើងតែងនិយាយថា មានតែអ្នកមានសំណាងទេ ទើបអាចទៅលេងអង្គរបាន ។ ខ្ញុំបានទៅលេងអង្គរ ។ អង្គរគឺជាវត្ថុដ៏អស្ចារ្យ ។ ប៉ុន្តែខ្ញុំបានជួបរឿងរើសអើងស្ត្រីយ៉ាងច្រើននៅក្នុងចំណោមអង្គការនៅកម្ពុជា ។ ខ្ញុំទៅអង្គរទៅសួរអប្សរា ៖ «តើអប្សរាអាចជាតំណាងឲ្យស្ត្រីខ្មែរយ៉ាងដូចម្តេច ? ហេតុអ្វីបានជាស្ត្រីខ្មែរសព្វថ្ងៃរងទុក្ខខ្លាំងម្ល៉េះ ?» ។

**លោកគ្រូ បេន ៖** ចុះអប្សរានិយាយតបថាម៉េច ?

**សំណួរ ៖** អប្សរាគឺជាស្ត្រីខ្មែរដ៏មានឥទ្ធិពល និងសុភាពរាបសា ។ អប្សរាប្រាប់ខ្ញុំថា អ្នកត្រូវតែខំប្រឹងឲ្យខ្លាំងជាងនេះទៀត កុំឲ្យបាក់ទឹកចិត្តឲ្យសោះ ។

**យោបល់បន្ថែម ៖** ខ្ញុំពិតជាចូលចិត្តគំនិតដែលថា ជាតិនិយមគឺជាអ្វីម្យ៉ាងអំពីអនាគត ។ ខ្ញុំតែងតែស្រមៃថា ប្រសិនបើព្រះបាទ ជ័យវរ្ម័ន ទី ៧ មិនបានកសាងប្រាសាទដ៏ធំស្កឹមស្កៃបែបនេះទេ តើកម្ពុជានឹងស្ថិតនៅឯណា ? ទ្រង់បានគិតពីអនាគតកាល ។ ដូច្នេះ សម្រាប់ខ្ញុំ អ្វីដែលយើងគួរតែធ្វើនាពេលឥឡូវនេះ គឺព្យាយាមធ្វើរឿងល្អ សម្រាប់អនាគតដែលអាចស្ថិតស្ថេរដូចអង្គរវត្ត ។

**លោកគ្រូ បេន ៖** យើងបាននិយាយពីខាងដើមពីគំនិតរបស់លោករ៉ឺណង់ ពីការចាំបាច់ត្រូវតែបំភ្លេចអ្វីមួយ ។ តើអ្នកបានបំភ្លេចអ្វីខ្លះហើយ ?

**យោបល់បន្ថែម ៖** អង្គរតំណាងឲ្យនិមិត្តរូបអាថ៌កំបាំង ។ ប៉ុន្តែ ព្រះរាជាប្រហែលជាកសាងអង្គរ ដើម្បីឧទ្ទិសថ្វាយអាទិទេពអមតៈ ។ ដូច្នេះ ការសាងសង់នេះត្រូវតែមាំ ហើយស្ថិតស្ថេរយូរអង្វែង ។ ខ្ញុំមិនដឹងថា ព្រះរាជា

*គិតថា អង្គរគឺជាអ្វីមួយ សម្រាប់ឲ្យកូនខ្មែរជំនាន់ក្រោយចងចាំនោះមែនឬទេ ។*

**លោកគ្រូបេន៖** *តើអ្នកដឹងថា មានមនុស្សប៉ុន្មាននាក់បានចូលរួមកសាងអង្គរ ?*

**យោបល់បន្ថែម៖** *ប្រហែលជាច្រើន ។ ព្រះមហាក្សត្រមានអំណាចកេណ្ឌប្រមូលប្រជាជន ទាសករ ឬក៏អ្នកផ្សេងទៀតឲ្យមកធ្វើការ ។ ខ្ញុំមិនគិតថា វាជាការងារបង្ខិតបង្ខំនោះទេ ។ មេដឹកនាំបានលួងលោមលើកទឹកចិត្តប្រជាជន ឲ្យមកជួយកសាងសំណង់ដ៏មហិមានេះ ។ ចម្លាក់នៅអង្គរវត្ត រៀបរាប់អំពីប្រវត្តិសាស្ត្រពិត សង្គ្រាម ទាសករ និងរឿងដទៃទៀត ។ នេះប្រហែលជាមធ្យោបាយឲ្យអ្នកជំនាន់ក្រោយចងចាំ ។*

**លោកគ្រូបេន៖** *បាទ! វាគួរឲ្យចាប់អារម្មណ៍ណាស់ ។ ប្រាកដជាមានការបាត់បង់ជីវិតយ៉ាងច្រើន ដើម្បីកសាងប្រាសាទស្ដឹមស្ដៃនេះ ។ ប៉ុន្តែ អ្វីដែលប្រជាជនបានភ្លេចនោះ គឺថា អ្នកដែលកសាងប្រាសាទ និងឆ្លាក់ចម្លាក់ គឺជាជនអនាមិកជាច្រើនរូប ហើយពួកគេនៅតែទទូចថា ស្ដេចជ័យវរ្ម័ន ទី ៧ កសាងប្រាសាទនេះដោយព្រះអង្គឯង ។ យើងក៏មិនប្រាកដថា មនុស្សដែលគ្មានឈ្មោះទាំងនោះ គឺជាខ្មែរ ឬមិនមែន ព្រោះថាមេដឹកនាំខ្មែរបានកេណ្ឌជាតិសាសន៍ដទៃ ពេលធ្វើសង្គ្រាម ហើយប្រើពួកនេះដូចជាទាសករ ។*

**សំណួរ៖** *ពេលដែលលោកគ្រូកាន់តែនិយាយពីការបំភ្លេចចោល ខ្ញុំកាន់តែចង់សួរថា ហេតុអ្វីបានជាវាគឺជាផ្នែកមួយនៃជាតិនិយម ?*

**លោកគ្រូបេន៖** *អ្នកប្រហែលជាយល់ច្រឡំពីគំនិតរបស់រ៉ឺណង់ ។ គាត់មិនមែនមានន័យថា មនុស្សដែលបំភ្លេចគឺជាមនុស្សវិកលចរិត ឬក៏ល្ងង់ខ្លៅឡើយ ។ គាត់និយាយពីការផ្លាស់ប្ដូរជាមូលដ្ឋានពីលក្ខខណ្ឌជីវិត និងមនសិការ ។*

*កាលពី ៨០០ ឆ្នាំមុន មនុស្សម្នាធ្វើដំណើរទៅសាត្រេស៍ ដើម្បីបួងសួងព្រះ ។ សព្វថ្ងៃ ពួកគេភាគច្រើនគឺជាទេសចរ ដែលមិនបានទៅកាន់ព្រះវិហារក្នុងបំណងសាសនាឡើយ ។ ពួកគេមិនបានគិតពីសាត្រេស៍ក្នុងរបៀបសាសនាឡើយ ដូច្នេះ ពួកគេអាចបំភ្លេចពីរឿងដែលថា សាត្រេស៍ គឺជាទីសក្ការៈរបស់គ្រិស្តបរិស័ទទៅបួងសួង ។ ពួកគេចង់ឃើញភាពស្រស់ស្អាត ។ ដូច្នេះ នៅពេលពួកគេទៅកាន់ព្រះវិហារ ពួកគេមិនបានប្រដូចខ្លួនគេទៅនឹងអ្នកសង់វិហារកាលពី ៧០០ ឬ ៨០០ ឆ្នាំមុន ពោលពួកគេមិនមានជំនឿសាសនាមុតមាំ ដូចមនុស្សសម័យមុនឡើយ ។ ខ្ញុំចង់និយាយថា វាមិនអាចទៅរួចទេ សម្រាប់ប្រជាជនបារាំងសព្វថ្ងៃឲ្យគិតដូចមនុស្សកាលពី ៨០០ ឆ្នាំមុន ។ ដូច្នេះហើយបានជាខ្ញុំសួរអ្នកថា តើអាចស្រមៃដល់កម្រិតណាពីអ្នក ដែលបានជួយកសាងអង្គរវត្ត ? តើមនុស្សនៅសម័យនោះ គិតយ៉ាងដូចម្ដេចពីរឿងនេះ ? ហើយតើអ្នកមើលវាបែបណា នាពេលសព្វថ្ងៃនេះ ? អ្នកអាចគិតថា «ការផ្លាស់ប្ដូរមនសិការ» គឺជាគំនិតដ៏លំបាក ប៉ុន្តែ វាមិនដូច្នោះទេ ។ ឧទាហរណ៍ តើក្នុងចំណោមអ្នកទាំងអស់គ្នា មានប៉ុន្មាននាក់ដែលធ្លាប់ឃើញរូបថតរបស់អ្នកកាលនៅជាទារក ?*

**សំណួរ៖** *ខ្ញុំសំណាងណាស់ ពីព្រោះឪពុករបស់ខ្ញុំគឺជាអ្នកថតរូប ។ គាត់បានថតរូបខ្ញុំ នៅពេលខ្ញុំមានអាយុ*

១ ឆ្នាំ ។

**លោកគ្រូ បេង៖** *ប្រសិនបើអ្នកឃើញរូបភាពរបស់អ្នក ហើយគ្មាននរណាម្នាក់ប្រាប់អ្នកថា រូបនោះជារូបនរណាទេ តើអ្នកដឹងថា រូបថតនោះជារូបរបស់អ្នកឬទេ ?*

**ចម្លើយ៖** *អត់ទេ ។*

**លោកគ្រូ បេង៖** *តើអ្វីដែលធ្វើឲ្យអ្នកជឿជាក់ថា ទារកនោះជាអ្នក ប្រសិនបើគ្មាននរណាដែលស្គាល់អ្នកប្រាប់អ្នក ? អ្នកត្រូវតែមានមនុស្សជួយប្រាប់អ្នក ។ អ្នកមិនអាចស្គាល់ខ្លួនឯងនោះទេ ពីព្រោះតែអ្នកមិនមែនជាទារកអាយុ ១ ឆ្នាំទៀតទេ ។*

**សំណួរ៖** *ខ្ញុំចង់សួរលោកគ្រូពីទំនាក់ទំនងជាតិនិយមជាមួយនឹងសមភាព ។ ខ្ញុំគិតថា កត្តានាំឲ្យមានសមភាពអាចនាំឲ្យមានការតស៊ូអំណាច ពីព្រោះនៅក្នុងសម័យទំនើប មិនមានសមភាពទេ ។ ការប្រកួតប្រជែងអំណាចនេះ អាចនាំឲ្យមានអស្ថិរភាព ហើយពេលមានអស្ថិរភាព ប្រទេសជាតិនឹងធ្លាក់ដុនដាប ។ ដូច្នេះ តើអ្នកអាចហៅខ្លួនឯងថា ជាអ្នកជាតិនិយមយ៉ាងដូចម្ដេច ?*

**លោកគ្រូ បេង៖** *ខ្ញុំគិតថា អ្នកកំពុងគិតពីរាជាធិបតេយ្យ ។ យើងគួរតែចាំថា នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិភាគច្រើន រាជាធិបតេយ្យគឺជារបបធម្មតានៅគ្រប់កន្លែងក្នុងពិភពលោក ប៉ុន្តែ ឥឡូវនេះ វាមិនមែនជារបបធម្មតាទៀតឡើយ ។ នៅក្នុងអង្គការសហប្រជាជាតិ មានប្រទេសតិចជាង ១៥% ដែលប្រកាន់របបរាជាធិបតេយ្យ ។ របបរាជាធិបតេយ្យមួយបានរលត់បាត់ទៅហើយនៅក្នុងប្រទេសនេប៉ាល់ កាលពីឆ្នាំមុននេះ ហើយរបបរាជាធិបតេយ្យផ្សេងទៀត ក៏នឹងបាត់បង់ផងដែរ ។ ភាគច្រើនក្នុងចំណោមរាជាធិបតេយ្យដែលនៅរស់រាន គ្រាន់តែជានិមិត្តរូបតែប៉ុណ្ណោះ ។ នៅក្នុងរបបនោះ ព្រះរាជាមិនមានអំណាចទេ ។ រាជាធិបតេយ្យនៅថៃ និងរដ្ឋអារ៉ាប់មួយចំនួន ដូចជា អារ៉ាប៊ីសាអូឌីត ជាដើម គឺជាករណីលើកលែង ។ មានប្រទេសប្រមាណ ៨៥% នៅក្នុងពិភពលោក ប្រកាន់របបសាធារណរដ្ឋ ។ ការប្រែប្រួលយ៉ាងសម្បើមនៅក្នុងរយៈពេល ១០០ ឆ្នាំនេះ គឺជាបម្រែបម្រួលដ៏ធំ ដែលពុំអាចថយក្រោយបាន ហើយមូលដ្ឋាននៃការប្រែប្រួលនេះ គឺជាការបដិសេធគំនិតដែលថា ព្រះមហាក្សត្រ គឺជាមនុស្សពិសិដ្ឋ ទិព្វ អស្ចារ្យ និងមានតែមួយ ។ ព្រះមហាក្សត្រមិនមែនជាមនុស្សខុសពីយើងនោះទេ ។ ពួកទ្រង់ក៏ត្រូវការដោះទុក្ខសត្វដូចយើងដែរ ។ ពួកទ្រង់ក៏មានចំណង់ផ្លូវភេទដូចយើងដែរ ពួកទ្រង់អាចល្ងង់ ឬក៏ឆ្លាតជាងយើងផង ក៏មិនដឹង ។ ប៉ុន្តែ ក៏មានព្រះរាជាឧស្សាហ៍ខ្លះដែរ ។ ព្រះរាជាមិនមានអ្វីខុសពីយើងឡើយ ។ ហេតុអ្វីបានជាពួកព្រះអង្គមានឯកសិទ្ធិ ? នេះគឺជាមូលហេតុដែលនាំឲ្យរាជាធិបតេយ្យសាបរលាបជាបណ្ដើរៗ ។*

**យោបល់បន្ថែម៖** *ប្រសិនបើយើងធ្វើដំណើរទៅប្រទេសសាធារណរដ្ឋ ដែលមានប្រធានាធិបតី នោះអ្នកនឹងមានការភ្ញាក់ផ្អើល ។ នៅឥណ្ឌូនេស៊ី ប្រធានាធិបតីដើរតួដូចព្រះមហាក្សត្រអញ្ចឹង បើទោះជាគាត់ត្រូវបាន*

*ជ្រើសតាំងដោយប្រជាជនក៏ដោយ ។ នៅមានប្រទេសផ្សេងទៀត ដែលប្រកាន់របបរាជានិយម ហើយព្រះមហាក្សត្រមានទំនួលខុសត្រូវយ៉ាងធំធេង ក្នុងការមើលថែប្រជាជន ដូច្នេះហើយប្រជាជនមានសមភាពច្រើនជាងប្រទេសសាធារណរដ្ឋមួយចំនួន ដែលប្រធានាធិបតីក្ដោបអំណាចទាំងអស់ ។ ខ្ញុំចង់មានន័យថា អ្នកអាចមានរបបរាជាធិបតេយ្យ ហើយនិងនៅតែមានជាតិនិយមដដែល ដូចប្រទេសកម្ពុជានៅសម័យសង្គមរាស្ត្រនិយម ។ បើទោះជាទ្រង់មិនមែនជាអ្នកមានអំណាចខ្លាំងជាងគេទៀតក៏ដោយ ក៏ព្រះមហាក្សត្រនៅតែជានិមិត្តរូបរបស់ប្រទេសនិងជាតិ ដូចប្រធានាធិបតីឯទៀតៗដែរ ។ ដូច្នេះ ខ្ញុំគិតថា អាចមានជាតិនិយមនៅក្នុងរបបរាជាធិបតេយ្យ ។*

*គំនិតរបស់ខ្ញុំគឺថា ពេលខ្លះ អ្នកជាតិនិយមពិតប្រាកដ ត្រូវតែបោះបង់ចោលសមភាព ដើម្បីរក្សាស្ថិរភាពប្រទេសជាតិ ដូច្នេះប្រទេសជិតខាងមិនអាចឈ្លានពានប្រទេសយើងបានឡើយ ។ គ្មានអ្វីចោទជាបញ្ហាទេ បើពេលខ្លះមនុស្សមិនមានភាពស្មើគ្នា ឬក៏មានអំណាចមិនស្មើគ្នា ប្រសិនបើនេះជាបុព្វហេតុដើម្បីការពារប្រទេសពីការឈ្លានពាន ។*

**លោកគ្រូបេន៖** *ខ្ញុំគិតថា រឿងនេះតែងតែកើតឡើងនៅពេលមានវិបត្តិ ។ ប៉ុន្តែ វាមិនបានផ្លាស់ប្តូរគំនិតជាមូលដ្ឋាន ដែលអ្នកជាតិនិយម ឬក៏ប្រជាជននៃជាតិមួយ ត្រូវបានគេចាត់ទុកថា មានភាពស្មើគ្នាជាបងប្អូនប្រុសស្រី មិនមែនជាចៅហ្វាយនាយ និងទាសករ ឬក៏មិនមែនជាលោកធំ និងអ្នកបម្រើឡើយ ។ នេះគឺជាមូលហេតុ ដែលធ្វើឲ្យរាជាធិបតេយ្យនាពេលបច្ចុប្បន្នមិនមានស្ថិរភាព ពីព្រោះតែរបបនេះដើរបញ្ច្រាសនឹងលក្ខខណ្ឌទំនើបនៃគោលការណ៍ «បងប្អូនប្រុសស្រី» ។ ព្រះមហាក្សត្រនៅប្រទេសថៃ មិនមែនជាបងប្អូនរបស់ប្រជានុរាស្ត្រទេ ។ ដូច្នេះហើយបានជាអំណាចរបស់ទ្រង់មិនមានស្ថិរភាព ហើយរាជសម្បត្តិសម្រាប់ព្រះរាជបុត្រារបស់ទ្រង់ កាន់តែគ្មានស្ថិរភាពទៅទៀត ។ ឥឡូវនេះ យើងអាចងាកទៅរករបបផ្តាច់ការរបស់ពួកយោធាវិញម្តង ។ របបយោធាផ្តាច់ការភាគច្រើន បានឡើងកាន់អំណាច ហើយប្រកាសតាមវិទ្យុថា ស្ថានភាពប្រទេសអាក្រក់មានគ្រោះថ្នាក់ខ្លាំង ហើយមានតែពួកយើង (ពួកយោធា) ទេ ទើបអាចដោះស្រាយបញ្ហាបាន ។ ការនិយាយបែបនេះ ពិតជាត្រឹមត្រូវក្នុងរយៈពេលខ្លីមួយ ប៉ុន្តែភ្លាមនោះ បញ្ហាធំក៏លេចឡើង ។ ប្រសិនបើពួកគេចង់ដោះស្រាយបញ្ហាប្រទេសជាតិ ហេតុអ្វីបានជាពួកគេនៅតែក្រាញនឹងអំណាច ? ប្រសិនបើពួកគេបរាជ័យក្នុងការដោះស្រាយបញ្ហា ហេតុអ្វីបានជាពួកគេនៅតែក្រាញនឹងអំណាចទៀត ? ប្រសិនបើពួកគេដោះស្រាយមិនកើត ពួកគេគួរតែលាចេញពីអំណាច ។ រឿងនេះក៏អាចប្រើចំពោះបណ្តាមេដឹកនាំនយោបាយថា នៅក្នុងស្ថានភាពគ្រោះអាសន្ន អ្នកអាចក្តោបអំណាចខ្លាំងបាន ប៉ុន្តែ អ្នកមិនអាចធ្វើបែបនេះជារៀងរហូតនោះទេ ។*

# ជាតិនិយមនៅទ្វីបអាស៊ី

បាឋកថារបស់លោកសាស្ត្រាចារ្យ បេនិឌិកត៍ អាន់ដឺរសុន
មជ្ឈមណ្ឌលខេមរសិក្សា ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៨

*ប្រធានបទថ្ងៃនេះ គឺជាសំណួរថា តើជាតិនិយមនៅអាស៊ី មានអ្វីពិសេសដែរឬទេ ? អ្វីដែលខ្ញុំចង់និយាយជាបឋម គឺការសង្ខេបយ៉ាងខ្លីពីមូលហេតុ ដែលធ្វើឲ្យកើតមានឡើងនូវគំនិតបែបនេះ ។ បន្ទាប់មក ខ្ញុំនឹងព្យាយាមបង្ហាញអ្នកពីមូលហេតុ ដែលខ្ញុំជឿថា គំនិតបែបនេះគ្មានប្រយោជន៍ ហើយមិនត្រឹមត្រូវ ។*

*រឿងទី ១ ដែលយើងត្រូវតែដឹង គឺចំណោទត្រង់អ្វីដែលអ្នកសិក្សា ក៏ដូចជាអ្នកនយោបាយសព្វថ្ងៃ ហៅថាអត្តសញ្ញាណ ។ ពួកគេធ្វើឲ្យពាក្យនេះស្ដាប់ទៅហាក់ដូចជាកប់ជ្រៅនៅក្នុងខ្លួនយើងម្នាក់ៗ អញ្ចឹង ។ ប៉ុន្តែ នេះគ្រាន់តែជាការបំភាន់មួយតែប៉ុណ្ណោះ ។ អត្តសញ្ញាណនេះកើតឡើងពីមជ្ឈដ្ឋានខាងក្រៅខ្លួនរបស់មនុស្ស ច្រើនជាងកើតចេញពីក្នុងខ្លួន ។ វាអាស្រ័យទាំងស្រុងទៅលើការវាយតម្លៃរបស់អ្នកដទៃ ។ ហើយការឲ្យតម្លៃនេះទៀតសោត ពឹងផ្អែកទាំងស្រុងទៅលើចំណុចថា តើនរណាកំពុងនិយាយជាមួយអ្នក ហើយនៅកន្លែងណា ។ ខ្ញុំសូមលើកឧទាហរណ៍ដ៏សាមញ្ញមួយស្ដីពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ។ ខ្ញុំមានមិត្តភក្ដិជនជាតិឥណ្ឌូនេស៊ីម្នាក់ដែលបាននិយាយរឿងប្រាប់ខ្ញុំថា ៖ «ឧបមាថាខ្ញុំជួបជនជាតិឥណ្ឌូនេស៊ីម្នាក់ទៀតនៅក្នុងប្រទេសឥណ្ឌូនេស៊ី ហើយខ្ញុំសួរមនុស្សនោះថា តើអ្នកមកពីណា ? មនុស្សនោះនឹងមិនឆ្លើយថា ខ្ញុំជាជនជាតិឥណ្ឌូនេស៊ីទេ ពីព្រោះវាស្ដាប់ទៅវាងចម្លែក និងឡប់ៗ ដោយសារយើងទាំងពីរនាក់នៅប្រទេសឥណ្ឌូនេស៊ីដូចគ្នា ។ មនុស្សនោះអាចនិយាយថា ខ្ញុំមកពីកោះជ្វា ឬក៏កោះកាលីម៉ាន់តាន់ ។ ប៉ុន្តែ ប្រសិនបើអ្នកសួរ គឺជាជនជាតិអាហ្វ្រិក ហើយសួរមនុស្សដដែលនោះនៅហុងកុងវិញ មនុស្សនោះនឹងមិនឆ្លើយថា ខ្ញុំមកពីជ្វាទេ ប៉ុន្តែ ឆ្លើយថា ខ្ញុំមកពីឥណ្ឌូនេស៊ី ឬ ខ្ញុំជាជនជាតិឥណ្ឌូនេស៊ី ដោយសារតែគេមិនប្រាកដថា ជនជាតិអាហ្វ្រិកនោះធ្លាប់ឮពីកោះជ្វាឡើយ ។ ប្រសិនបើមនុស្សដដែលនោះទៅអាមេរិក ហើយមានគេសួរគាត់ថា តើគាត់មកពីណា ? នោះប្រហែលជាគាត់ឆ្លើយថា ខ្ញុំមកពីអាស៊ី ឬ ខ្ញុំជាជនជាតិអាស៊ី ពីព្រោះខ្ញុំគិតថា ជនជាតិអាមេរិកនោះ ប្រហែលជាមិនដែលឮពីឥណ្ឌូនេស៊ី ឬអាចច្រឡំប្រទេសឥណ្ឌូនេស៊ីថា ជាប្រទេសឥណ្ឌា ។ ដូច្នេះ មនុស្សដដែលនេះអាចមានអត្តសញ្ញាណជាជាតិអាស៊ីពេលនៅអាមេរិក អត្តសញ្ញាណជាពលរដ្ឋឥណ្ឌូនេស៊ីពេលនៅហុងកុង និងអត្តសញ្ញាណជាអ្នកកោះជ្វាពេលនៅហ្សាការតា ។ វាអាស្រ័យលើកន្លែង ដែលអ្នកកំពុងស្ថិតនៅ និងនរណាដែលកំពុងនិយាយជាមួយអ្នក ។ រឿងនេះវាសំខាន់ណាស់ ពីព្រោះអ្នកទាំងអស់គ្នាសុទ្ធតែមានបទពិសោធន៍បែបនេះ ។»*

*នៅថ្ងៃតែមួយ អត្តសញ្ញាណរបស់អ្នកម្ដងថា ជាអ្នកបាត់ដំបង ម្ដងថា ជាជាតិខ្មែរ ម្ដងថា ជាជាតិអាស៊ី ។ ដូច្នេះ អត្តសញ្ញាណប្រែប្រួលទៅតាមការធ្វើដំណើរឬការបម្លាស់ទី ។ ប្រសិនបើអ្នកជួបជនជាតិអាមេរិកនៅប៉ារីស ហើយអ្នក*

សួរគាត់ថា មកពីណា គាត់នឹងមិនឆ្លើយថា «ខ្ញុំមកពីទីក្រុងឡូសអាន់ចឺឡេសទេ ។» គាត់នឹងនិយាយថា «ខ្ញុំជាជនជាតិអាមេរិក» លើកលែងតែអ្នកសួរសំណួរនោះ ជាជនជាតិអាមេរិកដូចគ្នា ។ នៅក្នុងន័យនេះ យើងអាចស្មានបានថា គេចាប់ផ្ដើមមើលឃើញពីអត្តសញ្ញាណនៅក្នុងសម័យថ្មីនេះតែម្ដង ពោលគឺ នៅពេលដែលមានមនុស្សរាប់លាននាក់ ធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយទៀត ពីទ្វីបមួយទៅទ្វីបមួយទៀត ពីក្រុងមួយទៅក្រុងមួយទៀត ។ល។ ខ្ញុំគិតថា ទើបតែ ៥០–៦០ ឆ្នាំមុននេះទេ ដែលបណ្ដាជននៅអាស៊ី ចាប់ផ្ដើមហៅខ្លួនឯងថា ជាជនអាស៊ី ។

រឿងទី ២ ដែលខ្ញុំសូមឲ្យអ្នកកត់ចំណាំនោះគឺថា ឈ្មោះអាស៊ីត្រូវបានបង្កើតឡើងជាដំបូង ដោយពួកក្រិកបុរាណដ៏ល្ងិតល្ងង់ សម្រាប់ហៅផ្នែកមួយនៃសកលលោក ដែលស្ថិតនៅឆ្ងាយ ចម្លែក ឃោរឃៅ និងស្ថិតនៅខាងក្រៅប្រទេសរបស់ខ្លួន ។ សម្រាប់ពួកក្រិក ពាក្យថា «អាស៊ី» នាពេលនោះ សំដៅលើប្រទេសពែក្ស (បច្ចុប្បន្នជាអ៊ីរ៉ង់) ប្រទេសទួរគី និងប្រទេសអ៊ីរ៉ាក់ ហើយពួកគេមិនទាន់ស្គាល់ប្រទេសចិន ប្រទេសជប៉ុន និងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍នៅឡើយទេ ។ ភាពផ្ទុយគ្នា មិនមែនរវាងអឺរ៉ុបនិងអាស៊ីទេ ប៉ុន្ដែ រវាងក្រិក (ល្អ) និងអាស៊ី (អាក្រក់) ។ ខ្ញុំសន្មតថា ការចូលចិត្តមាក់ងាយអ្នកដទៃ ជាធម្មជាតិរបស់មនុស្សទៅហើយ ។ គំនិតដែលថា អាស៊ីអន់ជាង ដែលដំបូង កើតចេញពីពួកក្រិក និងក្រោយមក ទទួលយកដោយពួកអឺរ៉ុប បានកើនឡើងខ្លាំងនៅសតវត្សរ៍ទី ១៩ ជាមួយនឹងការរីកសាយភាយនៃចក្រពត្តិនិយមអឺរ៉ុប ដែលអាចកើតឡើងបាន ដោយសារបដិវត្តន៍ឧស្សាហកម្ម ឧស្សាហកម្មមូលធននិយម ប្រព័ន្ធការិយាធិបតេយ្យសម័យទំនើប មនោគមវិជ្ជាប្រកាន់ពូជសាសន៍ ។ល។ ឥទ្ធិពលអំណាចរបស់ពួកអឺរ៉ុប (ពិសេស បារាំង និងអង់គ្លេស) មានទំហំធំធេង ហើយវិធីដែលពួកគេព័ណ៌នាពីមូលហេតុដែលធ្វើឲ្យពួកគេមានអំណាចខ្លាំង មានដូចជា បច្ចេកវិទ្យាខ្ពស់ វិទ្យាសាស្ត្រទំនើប ឧស្សាហកម្ម ម៉ាស៊ីនសង្គ្រាម គឺធ្វើឲ្យមានការភ័យខ្លាច ដោយសារតែការបញ្ចេញប្រតិកម្មរបស់វាទៅលើតំបន់ជាច្រើននៅអាស៊ី (កើតមានរួចទៅហើយនៅចុង ស.វ. ទី ១៩ និងថែមទាំងនៅបន្តមានរហូតដល់សព្វថ្ងៃ) ។ បញ្ញវន្តនៅអាស៊ី បានលើកឡើងថា ពួកបស្ចិមប្រទេសអាចមានឧត្តមភាពខាងវិទ្យាសាស្ត្រនិងសម្ភារៈ ប៉ុន្ដែ អាស៊ីមានឧត្តមភាពខាងផ្លូវចិត្ត ។ ឧត្តមភាពខាងផ្លូវចិត្តនេះ មានកប់ជ្រៅនៅក្នុងចិត្តគំនិតរបស់មនុស្សម្នាក់ៗ ស្ទើរតែដូចទៅនឹងគំនិតរបស់ពួកគ្រិស្តបរិស័ទ ស្ដីពីវិញ្ញាណទៅហើយ ។ ប៉ុន្ដែ តាមធម្មជាតិ ដោយសារតែអាស៊ីជាតំបន់ដែលមានសង្គមដទៃៗ ពីគ្នាជាច្រើន នោះលក្ខណៈធម្មជាតិនៃភាពទាក់ទងខាងផ្លូវចិត្ត ក៏មានសណ្ឋានខុសៗគ្នាខ្លាំង ពីសង្គមមួយទៅសង្គមមួយទៀតដែរ ។ ពុទ្ធសាសនិកជនគិតថា ជំនឿត្រឹមត្រូវគឺមានតែនៅក្នុងពុទ្ធសាសនាទេ ចំណែកពួកហិណ្ឌូគិតថា ជំនឿត្រឹមត្រូវ គឺមានតែនៅក្នុងសាសនាហិណ្ឌូទេ ហើយពួកមុស្លីមគិតថា ជំនឿត្រឹមត្រូវ គឺមានតែនៅក្នុងសាសនាមុស្លីមទេ ។ ដូច្នេះ យើងពិបាកនឹងរកអ្វីម្យ៉ាង ដែលពួកគេមានជារួម យកមកនិយាយណាស់ ។ តាមពិតទៅ សាសនាអ៊ិស្លាមមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសាសនាគ្រិស្ត និងសាសនាជ្វីហ្វ ជាងសាសនាព្រះពុទ្ធនិងសាសនាហិណ្ឌូ ។ ថ្មីៗនេះ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក មេដឹកនាំនយោបាយអាស៊ីមួយចំនួន ពិសេស លោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ី មហាធៀរ បាននិយាយថា «យើងនឹងមិនធ្វើត្រាប់តាមក្បួនច្បាប់លទ្ធិប្រជាធិបតេយ្យបស្ចិមប្រទេសទេ ។ យើងនឹងមានលទ្ធិប្រជាធិបតេយ្យរបស់យើងផ្ទាល់ ពីព្រោះយើងចង់រក្សាតម្លៃរបស់អាស៊ី ដែលប្រសើរជាងតម្លៃរបស់បស្ចិមប្រទេស ។ យើងមិនចាំបាច់ត្រូវសុំទោស ដែលថា មកពីយើងមិនបានគិតគូរពីសិទ្ធិមនុស្ស ឬក៏សិទ្ធិបុគ្គលនោះទេ ។ យើងជាជនជាតិអាស៊ី គិតនិងធ្វើសកម្មភាពរួមគ្នា ព្រមទាំងមានឆន្ទៈផ្លូវចិត្តរួមគ្នាផងដែរ» ។ ប៉ុន្ដែ យើងសង្កេតឃើញយ៉ាងច្បាស់ថា គំនិត

ទាំងនេះបាននាំឲ្យអ្នកនយោបាយ ដែលមានគំនិតស្របគ្នា ដាក់របបផ្តាច់ការទៅជារឿងមួយស្របច្បាប់ ។ គេអាចយកលោក មហាធៀរ ផ្ទាល់ ធ្វើជាឧទាហរណ៍ដាក់ស្តែង ។ នៅពេលដែលគាត់កាន់អំណាច គាត់បានរឹតបន្តឹងសេរីភាពសារព័ត៌មាននិងទូរទស្សន៍យ៉ាងខ្លាំង និងចាប់មនុស្សដាក់គុក ដោយគ្មានកាត់ក្តី ក្នុងនាមតម្លៃអាស៊ី ។ ប៉ុន្តែក្រោយពីគាត់ឈប់ធ្វើនាយករដ្ឋមន្ត្រី អ្នកស្នងរបស់គាត់ បានរឹតបន្តឹងសេរីភាពរបស់គាត់ ហើយលោក មហាធៀរ ខឹងយ៉ាងខ្លាំង ដោយនិយាយថា លទ្ធិប្រជាធិបតេយ្យបានរលាយបាត់បង់ពីប្រទេសម៉ាឡេស៊ីហើយ ។

ឥឡូវនេះ យើងអាចត្រឡប់ទៅកាន់សំណួរដែលនិយាយថា ជាតិនិយមអាស៊ីគឺជារបស់ពិសេស ដែលមានតែមួយ គ្មានពីរប៉ុយ៉ាងណា ។ ចម្លើយផ្ទាល់របស់ខ្ញុំ គឺថា មិនមានជាតិនិយមអាស៊ីតែមួយនោះទេ គឺមានច្រើនណាស់ ហើយគ្មានមួយណាមានលក្ខណៈពិសេសពិត ប៉ុមានតែមួយគ្មានពីរនោះទេ ។

ខ្ញុំបានសរសេរទម្រង់ជាតិនិយមចំនួនប្រាំ នៅលើក្តារខៀន ជាទម្រង់ជាតិនិយមដែលបានលេចចេញជារូបរាងច្បាស់ ក្នុងចលនាសង្គម នៅចុង ស.វ. ទី ១៨ ។ បន្ទាប់មក យើងអាចពិនិត្យមើលថា តើយើងអាចរកឃើញទម្រង់ជាតិនិយមទាំងប្រាំនេះនៅអាស៊ីដែរប៉ុទេ ។

ទម្រង់ទី ១ គឺជាអ្វីដែលខ្ញុំហៅថា ជាតិនិយមក្រេអូល (Creole Nationalism) (ន័យដើមរបស់ក្រេអូល សំដៅលើជនជាតិអឺរ៉ុប ដែលបានកើត និងធំដឹងក្តីនៅក្រៅទ្វីបអឺរ៉ុប) ។ នេះគឺជាទម្រង់ជាតិនិយមដំបូង លេចឡើងក្នុងចំណោមជនជាតិអឺរ៉ុប ដែលបានកាន់កាប់គ្រប់គ្រងអាមេរិកខាងត្បូង អាមេរិកកណ្តាល អាមេរិកខាងជើង និងតំបន់ការ៉ាអ៊ីប ហើយបន្ទាប់មក បានតាំងទីលំនៅនៅទីនោះ ។ ពួកគេតែងតែមានទំនាក់ទំនងផ្លូវភេទជាមួយនារីក្នុងស្រុក និងចាប់ផ្តើមបង្កើតកូនចៅ ដែលកាត់ចម្រុះជាមួយជាតិសាសន៍អឺរ៉ុប ។ បន្ទាប់មក ក្រោយពីការនាំចូលទាសករអាហ្វ្រិករាប់លាននាក់ ពួកគេក៏មានទំនាក់ទំនងផ្លូវភេទ និងមានកូនជាមួយនារីស្បែកខ្មៅទាំងនោះដែរ ។ ក្រោយមក យើងប្រទះឃើញរឿងស្រដៀងគ្នានេះដែរ នៅអូស្ត្រាលី អាហ្វ្រិកខាងត្បូង និងកន្លែងដទៃទៀត ។ នេះគឺជាប្រទេសនៅឯនាយសមុទ្រ ដែលគ្រប់គ្រងដោយពួកស្បែកស ដែលយើងបានដឹងនាពេលសព្វថ្ងៃ ។ ហេតុអ្វីបានជាចលនាជាតិនិយមដំបូង កកើតឡើងក្នុងចំណោមពួកក្រេអូល ? មូលហេតុដ៏ធំមួយនោះ គឺថា បើទោះជាមនុស្សទាំងនេះគិតថា ពួកគេជាជនជាតិអេស្ប៉ាញ ជាជនជាតិអង់គ្លេសក៏ដោយ ក៏មនុស្សនៅចក្រភពអង់គ្លេស និងអេស្ប៉ាញ និយាយទៅកាន់ពួកគេថា «អ្នកឯងជាជនអង់គ្លេសវណ្ណៈទីពីរ ប៉ុក៏អេស្ប៉ាញវណ្ណៈទីពីរ ។ យើងមិនដឹងថា តើម្តាយរបស់អ្នកជាជនជាតិឥណ្ឌា ប៉ុក៏ជីដូនរបស់អ្នកជាពួកស្បែកខ្មៅឡើយ ។ អ្នកឯងមិនមែនជនជាតិជាអឺរ៉ុបសុទ្ធទេ ដូច្នេះ អ្នកឯងត្រូវតែស្តាប់បង្គាប់របស់យើង និងបង្កើតអាណានិគមនៅឯនាយសមុទ្រឲ្យយើង ។» ប៉ុន្តែពួកក្រេអូលមិនសប្បាយចិត្តនឹងការនៅក្រោមបង្គាប់បែបនេះទេ ហើយបានឆ្លើយតបវិញថា «យើងមានសាសនាដូចអ្នកដែរ ។ យើងនៅនិយាយភាសាដូចអ្នក ។ យើងអានសៀវភៅដូចអ្នក ។ យើងដឹងពីរបៀបធ្វើកាំភ្លើង និងរបៀបបាញ់កាំភ្លើងដូចអ្នកដែរ ។ គ្មានភាពខុសគ្នារវាងពួកយើងនិងពួកអ្នកទេ លើកលែងតែត្រង់ចំណុច ដែលពួកអ្នកមានភាពក្រអឺតក្រទម និងចង់ប្រើប្រាស់ពួកយើងប៉ុណ្ណោះ ។ ដូច្នេះ យើងនឹងប្រយុទ្ធតបតវិញ ។» ពួកគេអាចប្រយុទ្ធតបតយ៉ាងមានប្រសិទ្ធភាព ពីព្រោះតែមានភាពខុសប្លែកគ្នាតិចតួចប៉ុណ្ណោះរវាងពួកគេជាមួយនឹងអធិរាជចក្រពត្តិនៅអង់គ្លេស និងនៅអេស្ប៉ាញ ។ ដូច្នេះហើយ ប្រសិនបើអ្នកសម្លឹងរកមើលថា តើនរណាជាមេសកម្មជននៅក្នុងចលនាជាតិនិយមនៅអាមេរិកខាងជើង និងខាងត្បូង អ្នកនឹងឃើញថា ពួកគេមិនមែនជានិស្សិត ប៉ុក៏បញ្ញវន្តនោះទេ ។ ពួកគេគឺជាពាណិជ្ជករ អ្នកឯកទេស ម្ចាស់ដីធំៗ និងអ្នកសារព័ត៌មាន ។ ដូច្នេះ មនុស្សដែលមាន

ការពាក់ព័ន្ធជាមួយនឹងចលនាជាតិនេះ គឺជាមនុស្សមានជោគជ័យ ដែលមានបំណងចង់គ្រប់គ្រងប្រទេសរបស់ពួកគេដោយខ្លួនឯងផ្ទាល់ ។ នៅពេលពួកគេទទួលបានជោគជ័យ ពួកគេបោះបង់ចោលនូវរបបរាជាធិបតេយ្យ និងបានក្លាយជាបណ្តារដ្ឋ ដែលនឹងក្លាយជាទម្រង់សាធារណរដ្ឋ នៅកំលុងពេលដែលតំបន់ដទៃទៀតនៅក្នុងពិភពលោក កំពុងស្ថិតនៅក្រោមរបបគ្រប់គ្រងរាជាធិបតេយ្យ ។ យើងចាំបាច់ត្រូវកត់សម្គាល់ពីករណីលើកលែងមួយ ទាក់ទងនឹងបដិវត្តន៍ដ៏ល្បីល្បាញរបស់ពួកទាសករស្បែកខ្មៅ នៅក្នុងតំបន់មួយ ដែលសព្វថ្ងៃនេះ ជាប្រទេសហៃទី ។ បន្ទាប់ពីការបង្ហូរឈាមយ៉ាងច្រើនមក ពួកគេទទួលបានជោគជ័យ ហើយហៃទីនៅតែជាប្រទេសស្បែកខ្មៅ ដែលទទួលបានឯករាជ្យចំណាស់ជាងគេក្នុងលោក ។ តាមពិតទៅ ហៃទីជាប្រទេសទទួលបានឯករាជ្យទីពីរ នៅតំបន់អឌ្ឍគោលខាងលិច មុនប្រទេសអារហ្សង់ទីន វេណេហ្ស៊ុយអេឡា ឈីលី និងកាណាដាទៅទៀត ។

ចរន្តជាតិនិយមទី ២ ចាប់ផ្តើមកាលពីប្រហែល ៤០ ឆ្នាំក្រោយមក (គឺបន្ទាប់ពីចលនាជាតិនិយមក្រេអូល) ។ សៀវភៅភាគច្រើននៅតែរឹងសរសេរថា វាជាចលនាជាតិនិយមដំបូងគេ ទោះជាដឹងថាខុសក៏ដោយ ។ ចលនានេះបានកើតឡើង ក្រោយចលនាជាតិរបស់ពួកអេស្ប៉ាញ-អាមេរិក និងពួកអង់គ្លេស-អាមេរិកទៅទៀត ។ ចុះហេតុអ្វីបានជាមនុស្សជាច្រើន នៅតែទទូចថា ជាតិនិយមប្រភេទទីពីរ ដែលយើងហៅថា ជាតិនិយមដោយផ្អែកលើជាតិពន្ធុ-ភាសាវិទ្យា នេះ ថា ជាប្រភពពិតនៃជាតិនិយមសម័យថ្មីទៅវិញ ?

មូលហេតុមួយនោះគឺជាភាពក្រអឺតក្រទមរបស់ពួកអឺរ៉ុប ។ ពួកគេចូលចិត្តគិតថា អ្វីៗ ដែលសំខាន់នៅសម័យថ្មី ត្រូវតែចាប់ផ្តើមពីអឺរ៉ុប ហើយបន្ទាប់មក ទើបបានទៅដល់មនុស្សដទៃទៀត ។ ដូច្នេះ ពួកគេមិនចង់ទទួលស្គាល់ការពិតជាក់ស្តែងឡើយ ។ មូលហេតុទីពីរ គឺថា ជាតិនិយមនៅអឌ្ឍគោលខាងលិច មិនសមស្របនឹងបុរេវិនិច្ឆ័យរបស់ពួកគេ ដែលលើកឡើងថា គ្រប់ប្រទេសទាំងអស់ គួរតែមានភាសាផ្ទាល់ខ្លួន ។ ប៉ុន្តែ រដ្ឋឯករាជទាំង ១៥ ដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុងម៉ាឌ្រីដ សុទ្ធតែជាប្រទេសនិយាយភាសាអេស្ប៉ាញ និងបានប្រើប្រាស់ភាសានេះជាភាសាជាតិ ។ ដូចគ្នានេះដែរ អាមេរិក កាណាដា ហ្សាម៉ាអ៊ិក និងរដ្ឋអតីត-អាណានិគមរបស់អង់គ្លេស បានយកភាសាអង់គ្លេសធ្វើជាភាសាជាតិរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ ពិតណាស់ ប្រទេសនីមួយៗ និយាយភាសាអង់គ្លេសក្នុងទម្រង់ផ្សេងៗគ្នា ប៉ុន្តែ ពួកគេទាំងអស់គ្នា ងាយស្តាប់គ្នាយល់ណាស់ ។ លើសពីនេះទៅទៀត រាល់ប្រទេសនិយាយភាសាអង់គ្លេស សុទ្ធតែជាពួកគ្រិស្តសាសនិក និកាយប្រូតេស្តង់ ដូចអង់គ្លេស ហើយប្រទេសនិយាយភាសាអេស្ប៉ាញទាំងអស់ គឺជាពួកគ្រិស្តសាសនិក និកាយកាតូលិក ដូចអេស្ប៉ាញផងដែរ ។ ដូច្នេះ ប្រទេសទាំងអស់នេះ ប្រៀបដូចជាបងប្អូនជីដូនមួយគ្នា ដែលទំនាក់ទំនងនេះមានលក្ខណៈស្អិតល្មួតជាងទំនាក់ទំនងរវាងប្រទេសនិយាយភាសាអារ៉ាប់ និងប្រទេសមុស្លីមជាច្រើននៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើងទៅទៀត ។

អ្នកនឹងយល់ថា ចរន្តទី ២ នេះមានអ្វីម្យ៉ាងខុសគេយ៉ាងខ្លាំង ។ មូលហេតុចម្បងដែលពន្យល់ពីភាពខុសប្លែកគ្នានេះ គឺថា អឺរ៉ុបគឺជាកន្លែងគួរឲ្យអស់សំណើចនៅក្នុងលោក ។ វាមានទំហំតូចណាស់ បើប្រៀបធៀបជាមួយអាមេរិកខាងត្បូង ឬក៏អាមេរិកខាងជើង ហើយវាក៏ជាកន្លែងដែលមានបញ្ហាស្មុគស្មាញជាច្រើនទាក់ទងនឹងភាសាដែរ ។ ប្រទេសឯករាជនៅអឺរ៉ុបស្ទើរតែទាំងអស់ នាពេលបច្ចុប្បន្ន មានភាសាជាតិរបស់ខ្លួន លើកលែងតែប្រទេសអូទ្រីស និងស្វីស ។ (តំបន់នេះក៏មានទម្រង់សាសនាគ្រិស្តប្រកួតប្រជែងគ្នាច្រើនប្រភេទផងដែរ ។) អឺរ៉ុបទាំងមូលក៏មិនដែលស្ថិតនៅក្រោមចក្រភពតែមួយ និងប្រើភាសាចក្រភពតែមួយនោះឡើយ ។ ដោយឡែក

ប្រទេសចិនមានចំណុចទាំងពីរនេះ ។ ប្រជាជននៅអឺរ៉ុបនិយាយភាសាផ្សេងៗ ពីគ្នា ។ បណ្តារដ្ឋនៅអឺរ៉ុប មានសង្គ្រាមជាមួយគ្នាឥតឈប់ឈរ មានខ្លះរំលោភបានដីនិងប្រជាជនមក មានខ្លះក៏បាត់បង់ទឹកដីមួយផ្នែក និងប្រជាជនទៅវិញ ។ បន្ទាប់មក យើងឃើញថា អឺរ៉ុបមានលក្ខណៈស្រដៀងគ្នាមួយចំនួនជាមួយនឹងអាស៊ីអាគ្នេយ៍ ដែលមិនដែលស្ថិតនៅក្រោមចក្រភពតែមួយ និងមានភាសាតែមួយឡើយ ប៉ុន្តែ មានការប្រកួតប្រជែងយ៉ាងច្រើនក្នុងចំណោមរាជាធិបតេយ្យដែលតែងតែប្រយុទ្ធគ្នា និងរំលោភយកទឹកដី ឬធ្វើឲ្យបាត់បង់ទៅវិញ និងថែមទាំងបាត់បង់ប្រជាជនថែមទៀត ។

យើងគួរតែចងចាំថា ចក្រភពរាជាធិបតេយ្យធំៗ ដែលនិយាយភាសាច្រើនដូចជា អូទ្រីស-ហុងគ្រី អង់គ្លេស បារាំង និងរុស្ស៊ី ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ពួកអភិជន ដែលមានភាសាខុសប្លែកគ្នាពីភាសារបស់ប្រជាជននៅក្រោមការដឹកនាំរបស់ពួកគេ ។ ឧទាហរណ៍ នៅរុស្ស៊ីរហូតដល់ឆ្នាំ ១៨៨០ ភាសាដែលនិយាយនៅក្នុងរាជវាំង មិនមែនជាភាសារុស្ស៊ីនោះទេ ប៉ុន្តែគឺជាភាសាបារាំង ។ ពួកគេចាត់ទុកភាសាបារាំងថា ជាភាសាដែលមានអរិយធម៌ខ្ពង់ខ្ពស់ ។ ប្រទេសព្រុស្សនៅសតវត្សរ៍ទី ១៨ ក៏ធ្វើដូចរុស្ស៊ីដែរ ។ នៅហូឡង់ គេប្រើភាសាហូឡង់ តែជាមួយអ្នកបម្រើនៅក្នុងផ្ទះ និងអ្នកលក់អីវ៉ាន់ប៉ុណ្ណោះ ។ អ្នកនឹងឃើញរឿងដូចគ្នានេះ នៅក្នុងតំបន់មួយចំនួន នៅទ្វីបអាស៊ីនៅសព្វថ្ងៃនេះ ។ ប្រសិនបើអ្នកធ្វើដំណើរទៅហ្វីលីពីន អ្នកនឹងឃើញថា ពួកអ្នកដែលមានវណ្ណៈខ្ពស់ និយាយភាសាអង់គ្លេស ដោយឡែក ប្រជាជនសាមញ្ញនិយាយភាសាក្នុងតំបន់ ពោលគឺ ភាសាតាហ្កាឡុក ។ នៅក្នុងន័យនេះ ពួកអភិជនភាគច្រើនមិនមែនជាអ្នកជាតិនិយមនោះទេ ។ ពួកគេមានមោទនភាពក្នុងការប្រើភាសា ដែលមនុស្សវណ្ណៈទាប ស្តាប់មិនយល់ ដែលនេះគឺជាសញ្ញាមួយនៃភាពខ្ពង់ខ្ពស់របស់ពួកគេ ។ នៅក្នុងកាលៈទេសៈបែបនេះ ការតស៊ូរបស់ពួកជាតិនិយមប្រឆាំងនឹងមេដឹកនាំចក្រពត្តិនិយម កើតឡើងក្នុងទម្រង់នៃការតស៊ូខាងភាសា ។ ពួកជាតិនិយមទាំងនោះអាចនិយាយប្រកបដោយមានប្រសិទ្ធភាពថា «ភាសារបស់យើង (ដូចជា ភាសាឆេក្ហូ ហុងគ្រី អៀរឡង់ រូម៉ានី និងស៊ែប៊ី) ប្រសើរដូចភាសារបស់អ្នកដែរ ហើយវាក៏ជាភាសាពិតរបស់មនុស្សសាមញ្ញផងដែរ ។ យើងចង់និយាយ និងសរសេរដោយប្រើភាសារបស់ពួកយើង យើងចង់បោះពុម្ពសៀវភៅជាភាសាយើង និងបង្កើតតន្ត្រីជាភាសាយើង ។» នៅរវាងឆ្នាំ ១៨៣០-១៩២០ តន្ត្រីប្រជាប្រិយមានសារៈសំខាន់ណាស់ ។ អ្នកនិពន្ធបានប្រើចម្រៀងនិងរបាំប្រពៃណី ដើម្បីបង្កើតតន្ត្រីជាតិនិយមជាលក្ខណៈតន្ត្រីបុរាណ ។

និយាយជារួមមក ឃើញថា វាមិនមែនជាការងឿងឆ្ងល់នោះទេ ដែលថា បណ្តាអ្នក ដែលត្រួសត្រាយជាតិនិយម ដោយផ្អែកលើជាតិពន្ធុ-ភាសាវិទ្យា មានលក្ខណៈខុសគ្នាច្រើនពីអ្នកជាតិនិយមនៅអឌ្ឍគោលខាងលិច ។ បណ្តាមនុស្សទាំងនោះមានដូចជា ពួកអាចារ្យគ្រិស្តសាសនានិកាយប្រូតេស្តង់ (ដែលបានបកប្រែគម្ពីរប៊ីប ជាភាសាហ៊ីន័រ ឬក៏ភាសាឆេក្ហូជាដើម) កវីនិពន្ធ អ្នកនិពន្ធប្រលោមលោក កូនសិស្ស អ្នកនិពន្ធបទភ្លេង អ្នករៀបចំវចនានុក្រម និងពាណិជ្ជករវណ្ណៈកណ្តាល ។ ពួកគេប្រើភាសាក្នុងតំបន់ និយាយទៅកាន់ប្រជាជនសាមញ្ញជាច្រើន ដែលអាចអាន និងសរសេរបាន ។ ភាពខុសប្លែកពីអឌ្ឍគោលខាងលិចផ្សេងទៀត គឺថា ភាគច្រើននៃអ្នកត្រួសត្រាយជាតិនិយមអឺរ៉ុប គឺជាអ្នកនិយាយភាសាពីរ ខុសគ្នាពីពួកនៅអាមេរិក ដែលនិយាយភាសាតែមួយប៉ុណ្ណោះ ។ ពួកគេមិនត្រឹមតែចេះភាសាក្នុងតំបន់ប៉ុណ្ណោះទេ តែថែមទាំងអាចនិយាយភាសារបស់ព្រះរាជាដែលគ្រប់គ្រងពួកគេទៀតផង ។ ឧទាហរណ៍ ពួកគេចេះទាំងភាសាឆេក្ហូ និងភាសាអាឡឺម៉ង់ បើទោះបីជាក្រោយមក ពួកគេបានបោះបង់ចោលភាសាអាឡឺម៉ង់ក៏ដោយ ។

ចរន្តទី ៣ នៃជាតិនិយម កើតឡើងមួយជំនាន់ក្រោយមក ហើយដែលមានបាតុភូតដើមពីអឺរ៉ុប ។ ខ្ញុំហៅវាថា ជាតិនិយមបែបផ្លូវការ (Official Nationalism) ។ នៅពាក់កណ្ដាលសតវត្សរ៍ទី ១៩ នៅពេលដែលចលនាជាតិនិយមតូចៗ ដែលស្ថិតនៅក្រោមរបបរាជានិយមធំៗ កាន់តែមានកម្លាំងខ្លាំងឡើង ពួកមេដឹកនាំ និងពួកអភិជនមានការបារម្ភកាន់តែខ្លាំងឡើង ។ ពួកគេចាប់ផ្ដើមដឹងថា ពួកគេអាចឈានទៅរកការចោទប្រកាន់ពីសំណាក់អ្នកជាតិនិយមវ័យក្មេងថា ជាជនក្បត់ជាតិ ។ បញ្ហាបែបនេះគឺកាន់តែអាក្រក់ឡើងនៅកន្លែងណា ដែលមេដឹកនាំមានដើមកំណើតជាជនបរទេស ដូចជានៅក្រិកជាដើម ។ ដូច្នេះ ពួកវណ្ណៈដឹកនាំព្យាយាមទទួលយកឬក៏ធ្វើខ្លួនឲ្យក្លាយជាអ្នកជាតិនិយម ។ ឧទាហរណ៍ដ៏ល្បីល្បាញមួយ គឺករណីប្រទេសរុស្ស៊ី ។ នៅរវាងទសវត្សរ៍ឆ្នាំ ១៨៨០ ពួកមេដឹកនាំរុស្ស៊ី ឈប់ប្រើប្រាស់ភាសាបារាំង និងចាប់ផ្ដើមប្រើប្រាស់ភាសារុស្ស៊ី ហើយព្យាយាមបង្ខំឲ្យប្រព័ន្ធអប់រំនៅក្នុងចក្រភពទាំងមូល ប្រើប្រាស់តែភាសារុស្ស៊ីមួយគត់ ។ មនុស្សនៅក្នុងចក្រភពដ៏ធំ និយាយភាសារុស្ស៊ីនៅក្នុងសាលា ។ ប៉ុន្តែ វាមានលទ្ធផលដែលនឹកស្មានមិនដល់មួយ គឺក្រុមជាតិពន្ធុ-ភាសាវិទ្យាជាច្រើនក្រុម ចង់ឲ្យមានការអប់រំជាភាសាផ្ទាល់របស់ពួកគេ និងមានការខឹងសម្បាជាមួយនឹងគោលនយោបាយថ្មីរបស់សាលារៀន ។ នៅឆ្នាំ ១៩០៥ មានបដិវត្តន៍យ៉ាងធំនៅក្នុងចក្រភពរុស្ស៊ី មានក្រុមជាតិពន្ធុ-ភាសាវិទ្យាជាច្រើនបានចូលរួមដើម្បីទាមទារឯករាជ្យ ។ រឿងដូចគ្នានេះដែរ បានកើតឡើងនៅអូទ្រីស-ហុងគ្រី និងចក្រភពអូតូម៉ង់ ។ រឿងដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថា ជាតិនិយមបែបផ្លូវការនេះ មិនមែនកើតចេញពីចលនារបស់ប្រជារាស្ត្រនោះទេ ប៉ុន្តែកើតចេញពីអាវុធនយោបាយនៃភាពភ័យព្រួយ ដែលស្ថិតនៅក្នុងដៃរបស់ពួកអភិជន និងព្រះរាជាពិសិដ្ឋ ដែលបានរីកសាយភាយយ៉ាងរហ័សទៅកាន់ទ្វីបអាស៊ី ។ ឧទាហរណ៍ដ៏ល្បីល្បាញ គឺករណីប្រទេសជប៉ុន ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៨៧០ និង ១៨៨០ ពួកអភិជនម៉ីជិ ដែលចង់ធ្វើទំនើបកម្មប្រទេសជប៉ុន និងធ្វើឲ្យប្រទេសនេះក្លាយជារដ្ឋមហាអំណាចឧស្សាហកម្មនិងយោធា តាមរយៈការបញ្ជូនតំណាងនិងគិញឲ្យធ្វើដំណើរទៅកាន់អឺរ៉ុប ដើម្បីស្វែងរកយុទ្ធសាស្ត្រថា តើត្រូវធ្វើអ្វីខ្លះ ដើម្បីអាចប្រកួតប្រជែងជាមួយមហាអំណាចអឺរ៉ុបធំៗ ទាំងនោះ ។ ពួកគេបានសិក្សាជាច្រើនពីចក្រភពអាឡឺម៉ង់ ។ ជាលទ្ធផល ជាតិនិយមបែបផ្លូវការនៅជប៉ុន ត្រូវបានលើកកម្ពស់ឡើង ដោយមានព្រះចៅអធិរាជ ។ ជាថ្មីម្ដងទៀត វាគឺជាគោលនយោបាយដែលគេរៀបចំ ដើម្បីរក្សាពួកអភិជនឲ្យកាន់អំណាច ។ ចរន្តនេះគឺខុសគ្នាឆ្ងាយពីចរន្តជាតិនិយម ដែលសុទ្ធតែចេញពីប្រជាជន ដូចយើងបានលើកនិយាយពីខាងដើម ហើយចេតនារបស់វា គឺអភិរក្សនិយមមិនមែនជាការរំដោះឡើយ ។ អ្នកក៏អាចឃើញរឿងដូចគ្នានេះដែរនៅក្នុងប្រទេសថៃ ដែលទន់ខ្សោយជាងប្រទេសជប៉ុន ហើយជាប្រទេសដែលទទួលរងការគំរាមកំហែងពីម្ចាស់អាណានិគមបារាំងនិងអង់គ្លេស ។ នៅក្នុងរជ្ជកាលស្ដេចព្រះរាមទី ៦ (សោយរាជ្យពីឆ្នាំ ១៩១០-១៩២៦) របបរាជាធិបតេយ្យបានចាត់ទុកខ្លួនឯងថា ជាអ្នកជាតិនិយម លែងនៅក្នុងន័យសាសនា (ទេវរាជ) ដូចមុនទៀតហើយ ។ ព្រះចៅព្រះរាមទី ៦ បានបង្កើតបាវចនាមួយបែបអភិរក្ស គឺ ជាតិ សាសនា ព្រះមហាក្សត្រ ដែលនៅតែប្រើរហូតដល់សព្វថ្ងៃនេះ ។ អ្នកអាចនិយាយបានថា ទ្រង់ឈប់ធ្វើជាស្ដេចលើប្រជាជនថៃទៀតហើយ ប៉ុន្តែទ្រង់គឺជាព្រះមហាក្សត្រជាតិថៃមួយអង្គវិញ ។

ចរន្តទី ៤ កើតនៅសតវត្សរ៍ទី ២០ ។ វាគឺជាចរន្តជាតិនិយមប្រឆាំងនឹងអាណានិគម និងចក្រពត្តិនិយម (Anti-Colonial Nationalism Against Imperialism) ។ អ្នកត្រួសត្រាយ គឺជាសិស្ស និស្សិត អ្នកសារព័ត៌មាន អ្នករៀបចំសហគមន៍ពាណិជ្ជកម្ម និងអ្នកនយោបាយជំនាញ ។ ពួកគេភាគច្រើនបានរៀនពីទម្រង់ជាតិនិយមដើម

ពិសេសចរន្តជាតិនិយមទី ២ ។ ឧទាហរណ៍ដ៏ល្បីល្បាញ គឺករណីប្រទេសវៀតណាម ដែលបញ្ញវន្តសម្រេចចិត្តទទួលប្រើអក្សររ៉ូម៉ាំង ធ្វើជាភាសាវៀតណាម ដើម្បីបង្កភាពងាយស្រួលដល់កសិករ អ្នកស្រែចម្ការ និងមនុស្សសាមញ្ញ អាចអានយ៉ាងលឿននិងមានភាពងាយស្រួល ។ ពួកគេបោះបង់តួអក្សរចិនទាំងអស់ ដែលពួកគេធ្លាប់បានប្រើអស់ជាច្រើនសតវត្សរ៍មកហើយ ។

ប៉ុន្តែ អ្នកនឹងឃើញថា ខ្សែបន្ទាត់ព្រំដែនដែលរៀបចំដោយចក្រពត្តិអឺរ៉ុប តែងតែមានការរំលោភបំពាន និងមិនសមស្របជាមួយនិងតំបន់ជាច្រើននៃក្រុមជាតិពន្ធុ-ភាសាវិទ្យាផ្សេងៗ ។ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី និយាយភាសាដូចគ្នា បើទោះជាមានការសរសេរខុសគ្នាក៏ដោយ ហើយពួកគេអាចយល់គ្នាបានយ៉ាងងាយ ។ ប៉ុន្តែ ដោយសារតែប្រទេសមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចក្រភពហូឡង់ ហើយប្រទេសមួយទៀតស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង់គ្លេស ប្រទេសទាំងពីរមិនមានចលនាជាតិនិយមដូចគ្នាឡើយ ពោលគឺមានចលនាជាតិនិយមពីរ ។ ដូច្នេះ អ្នកជាតិនិយមអឺរ៉ុប ដែលទាមទារឲ្យប្រទេសមួយមានភាសាផ្ទាល់ខ្លួនមួយនោះ គឺមិនអាចធ្វើទៅរួចនោះទេ ។ ករណីប្រទេសថៃ និងប្រទេសលាវ ក៏មានលក្ខណៈស្រដៀងគ្នានេះដែរ ។ ពួកគេនិយាយភាសាស្រដៀងគ្នាខ្លាំងណាស់ ប៉ុន្តែដោយសារតែប្រទេសមួយស្ថិតនៅក្រោមអាណានិគមនិយមបារាំង ប្រទេសមួយទៀតមានឯករាជ្យ ម្ល៉ោះហើយ ជាតិនិយមនៅប្រទេសទាំងពីរនេះ មានទម្រង់ផ្សេងគ្នា ។

អ្នកធ្វើចលនាទាំងនេះ ចង់លើកកម្ពស់ភាសាផ្ទាល់ខ្លួនរបស់ពួកគេ ។ ពួកគេអាចធ្វើដូច្នេះបាននៅក្នុងសម័យសកលភាវូបនីយកម្ម និងក្រោយការបង្កើតសម្ព័ន្ធប្រជាជាតិ ។ ដូច្នេះ ពួកគេត្រូវទទួលស្គាល់ថា ភាសាក្នុងតំបន់របស់ពួកគេ ភាគច្រើនមិនមានប្រើនៅពេលទាក់ទងជាមួយមនុស្សមកពីតំបន់ដទៃនៅក្នុងសកលលោកឡើយ ។ ឧទាហរណ៍ អ្នកជាតិនិយមភូមា ប្រហែលជាស្រឡាញ់ និងកោតសរសើរភាសាភូមា ប៉ុន្តែ ពួកគេក៏ដឹងថា បើពួកគេនិយាយភាសាភូមានៅក្រៅប្រទេសភូមា គ្មានអ្នកណាម្នាក់យល់ពួកគេឡើយ ។ ដូច្នេះ ចរន្តជាតិនិយមទី ៤ នេះ ក៏មានលក្ខណៈដូចចរន្តជាតិនិយមទី ២ ដែរ គឺការប្រើភាសាពីរ ។ សព្វថ្ងៃនេះ ប្រសិនបើអ្នកសម្លឹងមើលពិភពលោកជុំវិញ មានប្រទេសជាច្រើន (នៅអាស៊ីផងដែរ) ប្រើភាសាពីរជាមូលដ្ឋាន ។ ភាសាទីមួយ គឺជារបស់ខ្លួនផ្ទាល់ ដូចជាភាសាខ្មែរ ហើយភាសាមួយទៀត មិនមែនជាភាសារបស់ខ្លួនទេ ។ វាអាចជាភាសាចិន អារ៉ាប់ អង់គ្លេស ព័រទុយហ្គាល់ និងបារាំង ។ ចំណុចនោះគឺថា វាគួរតែជាភាសាដែលបណ្ដាប្រទេសផ្សេងៗប្រើដែរ ។ ពិតណាស់ សព្វថ្ងៃនេះ មានភាសាបែបនេះប្រហែលជា ៥ ឬក៏ ៦ តែប៉ុណ្ណោះ ។

បន្ទាប់ពីទទួលបានឯករាជ្យ មេដឹកនាំចលនាឯករាជ្យជាច្រើន ចាប់ផ្ដើមខ្ចីគំរូជាច្រើនពីចរន្តជាតិនិយមទី ៣ ។ ពួកគេចាប់ផ្ដើមប្រើប្រាស់ជាតិនិយមជាឧបករណ៍រក្សាអំណាច និងទទួលបានការគាំទ្រពីប្រជាជន ។ ជាធម្មតា មធ្យោបាយដែលគេប្រើ មាន ទូរទស្សន៍រដ្ឋ ពិធីបុណ្យសាធារណៈ និងសៀវភៅពុម្ពស្ដង់ដារនៅតាមសាលារៀន ។ ជារឿយៗ ភាសាមួយត្រូវបានគេបង្ខំឲ្យក្រុមមនុស្សតូចៗប្រើ ទាំងពួកគេមិនពេញចិត្ត ។ ប្រសិនបើអ្នកពិនិត្យមើលជាតិនិយមប្រភេទនេះនៅចុង ស.វ. ទី ២០ និង ស.វ. ទី ២១ វិញ អ្នកអាចមើលឃើញថា វាបានរៀនយ៉ាងច្រើនពីទម្រង់មុនៗ ។

ទម្រង់ជាតិនិយមចុងក្រោយ ដែលលើកឡើងយ៉ាងខ្លីនេះ គឺទើបតែកើតមានតែប៉ុណ្ណោះ ។ ខ្ញុំហៅជាតិនិយមបែបនេះថា ជាតិនិយមពីនាយសមុទ្រ (Long Distance Nationalism) ។ វាកើតឡើងពីការផ្លាស់ទីលំនៅយ៉ាងច្រើនពាសពេញសកលលោក កាលពី ៥០ ឆ្នាំមុន ព្រមជាមួយនឹងបដិវត្តន៍នៅក្នុងវិស័យទូរគមនាគមន៍នាកំលុង

ទសវត្សរ៍ឆ្នាំ ១៩៩០ ។អ្នកអាចប្រទះឃើញជាតិនិយមប្រភេទនេះក្នុងចំណោមប្រជាជន ដែលមានជំនឿជាក់យ៉ាងខ្លាំងថា ខ្លួនឯងជាជនជាតិចិន ខ្មែរ ថៃ ឬក៏នីហ្សេរីយ៉ា ប៉ុន្តែពួកគេបានធ្វើដំណើរទៅតាំងទីលំនៅនៅតំបន់ខ្លះនៃទ្វីបអឺរ៉ុប អូស្ត្រាលី អាមេរិកខាងជើង និងខាងត្បូង និងតំបន់ដទៃទៀត ។ ជារឿយៗ ពួកគេមានលិខិតឆ្លងដែនពីរ ។ ពួកគេស្ថិតនៅក្នុងស្ថានភាពចម្លែក ពីព្រោះគំនិតជាតិនិយមទាំងមូល គឺថា មនុស្សគ្រប់រូបគួរតែមានប្រទេសជាតិផ្ទាល់ខ្លួនរបស់គេ ហើយពួកគេត្រូវរស់នៅក្នុងប្រទេសនោះ ។ ប្រជាជនកម្ពុជាគួរតែមានប្រទេសកម្ពុជា ដើម្បីរស់នៅ ជនជាតិឥណ្ឌូនេស៊ីគួរតែមានប្រទេសឥណ្ឌូនេស៊ីសម្រាប់រស់នៅ ។ល។ មិនមានករណីបែបនេះទៀតទេ ពិសេសប្រសិនបើជនអន្តោប្រវេសន៍កម្ពុជា ឬក៏ជនអន្តោប្រវេសន៍ឥណ្ឌូនេស៊ី បានក្លាយជាពលរដ្ឋកាណាដា ។ ដូច្នេះ ពួកគេបង្កើតជាតិនិយមខ្មែរ ឬក៏ឥណ្ឌូនេស៊ី នៅកន្លែងដែលមានចម្ងាយរាប់ពាន់គីឡូម៉ែត្រពីប្រទេសកម្ពុជា និងប្រទេសឥណ្ឌូនេស៊ី ។ នេះបង្កើតឲ្យមានប្រភេទជាតិនិយមពិសេសមួយ ដែលភាគច្រើនមាននៅលើទំព័រអ៊ីនធើណេត ។ ឧទាហរណ៍ នៅកាណាដា មនុស្សអង្គុយពីមុខកុំព្យូទ័រយួរដៃរបស់ពួកគេ នៅពេលយប់ ហើយសរសេរសារមានដូចជា «ឥណ្ឌាមិនត្រូវបណ្តោយឲ្យរបូតតំបន់កស្មីរ (កាស្មៀរ) ឡើយ» «ចិនដីគោកត្រូវតែកម្ទេចតៃវ៉ាន់» «បរាជ័យឧត្តមសេនីយ៍នៅភូមា!» ។ល។ ពួកគេពិតជាមានភាពស្មោះត្រង់ ប៉ុន្តែបើពិនិត្យមើលឲ្យមែនទែនទៅ ពួកគេក្លាយទៅជាអ្នកជាតិនិយមចង់ជ្រុលទៅវិញ មូលហេតុប្រហែលមកពីថា ពួកគេមានអារម្មណ៍មិនសុខស្រួល ពេលចាកចេញពីប្រទេសកំណើតរបស់ខ្លួន ហើយទទួលយកសញ្ជាតិបរទេស ។ ខ្ញុំមិនគិតថា ជាតិនិយមប្រភេទនេះ វាអាក្រក់នោះទេ ។ ប៉ុន្តែ វាអាចមានលទ្ធផលដ៏គួរឲ្យគ្រោះថ្នាក់ផងដែរ ។ មនុស្សដែលរស់នៅក្រៅប្រទេស អស់រយៈពេលយូរ ហាក់បីដូចជាបាត់បង់ទំនាក់ទំនងជាតថភាពជាមួយប្រទេសកំណើត ហើយរស់នៅជាមួយក្តីសុបិនពី «ស្រុកកំណើត» ។ ពួកគេរស់នៅដោយសុវត្ថិភាព និងផាសុកភាព នៅក្នុងប្រទេសអង់គ្លេស ឬក៏បារាំង ឬក៏អាមេរិក ហើយពួកគេអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ពួកគេ ដោយផ្ញើជាថវិកា មធ្យោបាយសម្រាប់យុទ្ធនាការផ្សព្វផ្សាយ និងថែមទាំងអាចបញ្ជូនអាវុធទៅឲ្យក្រុមប្រឆាំងផ្សេងៗ នៅក្នុងប្រទេសកំណើត ដែលបង្កឲ្យមានបញ្ហាយ៉ាងធំ ។ ហើយពួកគេក៏បានគេចវេះពីទំនួលខុសត្រូវ ក្នុងនាមជាពលរដ្ឋផងដែរ ពោលគឺ ពួកគេមិនបានព្រមទៅបោះឆ្នោតនៅប្រទេសកំណើតសោះ (គ្មាននរណាឃាត់ខ្លួនពួកគេទេ) ពួកគេមិនបង់ពន្ធនៅប្រទេសកំណើត ។ល។ ពួកគេមានការងាយស្រួលរស់នៅក្នុងពិភពដ៏រីករាយ ។ អ្នកអាចរកឃើញមនុស្សប្រភេទនេះក្នុងចំណោមពួកអន្តោប្រវេសន៍លាវ ហ្មុង វៀតណាម ភូមា ទមិឡ អ៊ុយហ្គួរ និងក្រុមជនជាតិចិនជាច្រើនប្រភេទ ។

ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយពីទ្វីបអាស៊ីវិញ ដើម្បីបង្ហាញឲ្យអ្នកឃើញថា យើងអាចប្រទះឃើញប្រភេទជាតិនិយមទាំងអស់ខាងលើនេះបាន ។ អ្នកប្រហែលជាគិតថា គ្មានប្រភេទជាតិនិយមក្រេអូលនៅទ្វីបអាស៊ីទេ ប៉ុន្តែខ្ញុំថា វាមាននៅតៃវ៉ាន់ ។ តៃវ៉ាន់ កាលពីដើមឡើយ មានមនុស្សមានរូបរាងស្រដៀងពួកហ្វីលីពីន និងមឡាយូ រស់នៅ ។ ប៉ុន្តែ នៅ ស.វ. ទី ១៧ មានមនុស្សមួយចំនួនមកពីភាគអាគ្នេយ៍នៃប្រទេសចិន បានចាប់ផ្តើមមករស់នៅតៃវ៉ាន់ ដោយរុញច្រានជនជាតិដើម ឲ្យទៅរស់នៅតំបន់ភ្នំ ហើយពួកចំណូលថ្មីរស់នៅតាមតំបន់ឆ្នេរ ។ ដំបូងឡើយ រដ្ឋាភិបាលចក្រភព (ចិន) មិនបានយកចិត្តទុកដាក់ចំពោះពួកនេះទេ ។ ប៉ុន្តែ ក្រោយមកពួកគេចាប់ផ្តើមបញ្ជូនមន្ត្រីឲ្យទៅដឹកនាំនៅទីនោះ ។ វាស្រដៀងនឹងអ្វីដែលបានកើតឡើងនៅអាមេរិកខាងជើង និងខាងត្បូង ។ ក្រោយមកទៀត ពួកនិគមជនទាំងនេះចាប់ផ្តើមធ្វើឲ្យតៃវ៉ាន់ក្លាយជាប្រទេសផ្សេងមួយ ។ ពួក

ជប៉ុនបានដាក់អាណានិគមលើពួកគេអស់ ៥០ ឆ្នាំ (គ.ស. ១៨៩៥-១៩៤៥) ។ នៅពេលដែលលោក ជៀង ខៃឆេក រត់គេចពីទាហានរបស់លោកប្រធានម៉ៅ ទៅកាន់កោះតៃវ៉ាន់ ជៀង ខៃឆេក បានបង្កើតរបបផ្តាច់ការឃោរឃៅ និងបានសម្លាប់ជនជាតិតៃវ៉ាន់អស់ជាច្រើន ។ ដូច្នេះ ជាបណ្តើរៗ តៃវ៉ាន់បានបដិសេធចោលគំនិតដែលលើកឡើងថា តៃវ៉ាន់គឺជាចិន ហើយមើលឃើញខ្លួនឯងថា ជាប្រជាជាតិរងគ្រោះ ដោយសារការគាបសង្កត់ ដូចពួកក្រេអូលអេស្ប៉ាញនៅចក្រភពម៉ិចស៊ិច នាដើម ស.វ. ទី ១៩ ។ ឥឡូវនេះតៃវ៉ាន់គឺជាប្រទេសជាតិនិយមដ៏ខ្លាំងក្លាមួយ ។ ពួកគេធ្វើដូចពួកអូស្ត្រាលី ដែលនិយាយភាសាអង់គ្លេស ប៉ុន្តែមិនចាត់ទុកខ្លួនឯងថា ជាជនជាតិអង់គ្លេស ឬក៏ធ្វើដូចប្រជាជនសិង្ហបុរីមួយចំនួនដែលចេះភាសាចិន ប៉ុន្តែចាត់ទុកខ្លួនឯងថា ជាជនជាតិសិង្ហបុរី ។

ជាតិនិយមដែលផ្អែកលើជាតិពន្ធុ-ភាសាវិទ្យា ហាក់បីដូចជាសាមញ្ញ ។ អ្នកអាចប្រទះឃើញទម្រង់ចាស់នៅកូរ៉េ នៅក្នុងប្រវត្តិសាស្ត្រដើមរបស់កម្ពុជាសម័យទំនើប នៅក្នុងប្រទេសស្រីលង្កាមុនសង្គ្រាមលោកលើកទីពីរ ដែលកាលនោះ មានចលនាភាសាសីហឡៈ ។ សព្វថ្ងៃនេះ អ្នកក៏អាចឃើញចលនាជាតិនិយមបែបនេះនៅក្នុងតំបន់មួយចំនួនក្នុងប្រទេសឥណ្ឌា ទីបេត៍ និងស៊ីនកៀងផងដែរ ។ វាជារឿងធម្មតាទេ ដែលក្រុមជាតិពន្ធុ-ភាសាវិទ្យា បារម្ភខ្លាចបាត់ភាសា និងវប្បធម៌ប្រពៃណីរបស់ខ្លួន ។

ដូចខ្ញុំបានលើកឡើងពីខាងដើមហើយថា ជាតិនិយមបែបផ្លូវការបានមកដល់អាស៊ីនៅ ស.វ. ទី ១៩ ពិសេសនៅជប៉ុន និងក្រោយមក នៅប្រទេសថៃ ។ ប៉ុន្តែ ឥឡូវនេះ យើងអាចមើលឃើញយ៉ាងច្បាស់នៅប្រទេសចិន ។ គណបក្សកុម្មុយនិស្តកាលពី ៥០ ឆ្នាំមុន បានផ្តួលរំលំសន្តតិវង្សឈីង ហើយប្តូររបបគ្រប់គ្រងជាសង្គមនិយមវិញ តែឥឡូវនេះ បែរជាខំខ្នះខ្នែងចង់កាន់កាប់ទីបេត៍ និងអាស៊ីកណ្តាល ដែលធ្លាប់ជាទឹកដីរបស់សន្តតិវង្សនេះទៅវិញ ។ គណបក្សកុម្មុយនិស្តធ្វើសកម្មភាពពោរពេញទៅដោយជាតិនិយមពេញទី ពីព្រោះខ្លួនបានបោះបង់ចោលរបបសង្គមនិយម ។

ក្នុងករណីជាតិនិយមប្រឆាំងនឹងអាណានិគមនិយម ខ្ញុំគិតថា ខ្ញុំមិនចាំបាច់និយាយអ្វីច្រើននោះទេ ពីព្រោះអ្នកទាំងអស់គ្នាបានដឹងពុគ្រប់គ្នាហើយ ។ វាមានសកម្មភាពខ្លាំងនៅកន្លែងមួយចំនួនជាងកន្លែងដទៃទៀត ប៉ុន្តែវាមាននៅគ្រប់ទីកន្លែងទាំងអស់ ។ ជាតិនិយមពីនាយសមុទ្រ ក៏ឃើញមានផងដែរ ប្រសិនបើអ្នកមើលសកម្មភាពនយោបាយនៅតាមបណ្តាសហគមន៍ចិនក្រៅប្រទេស នៅកាណាដា អាមេរិក អឺរ៉ុប និងកន្លែងដទៃទៀត ។ នៅក្នុងករណីខ្លះពួកគេពិតជាសកម្មជាងរដ្ឋាភិបាលចិនទៅទៀត ។ ពួកគេលួងលោមក្រុងប៉េកាំង កុំឲ្យសម្របសម្រួលជាមួយតៃវ៉ាន់ ។ ប៉ុន្តែ ការលួងលោមនេះគ្មានតម្លៃអ្វីឡើយ ពីព្រោះតែពួកគេមិនមែនរស់នៅក្នុងប្រទេសតៃវ៉ាន់ ឬក៏ប្រទេសចិនទេ ប៉ុន្តែនៅឡូសអាន់ចឺឡេស តូរ៉ាន់តូ ឬក៏ក្រុងឡុងដ្រ៍ទៅវិញ ។ អ្នកក៏ប្រហែលឃើញជនជាតិឥណ្ឌា និងប៉ាគីស្ថានរាប់លាននាក់នៅបរទេស ដែលបានក្លាយជាអ្នកមានទ្រព្យ ហើយបានព្យាយាមធ្វើអន្តរាគមន៍នៅក្នុងនយោបាយឥណ្ឌា និងប៉ាគីស្ថាន ដែលពេលខ្លះ គឺជារឿងអយុត្តិធម៌ពន់ពេក និងបង្កឲ្យមានអំពើហិង្សា ។

សម្រាប់តំបន់អាស៊ីអាគ្នេយ៍ ឧទាហរណ៍ច្បាស់នោះ គឺប្រហែលជាករណីប្រទេសវៀតណាម ប៉ុន្តែ ក៏មានក្រុមសកម្មជនភូមាមួយចំនួនផងដែរ ដែលព្យាយាមបញ្ចុះបញ្ចូលអង្គការសហប្រជាជាតិឲ្យដាក់ទណ្ឌកម្មដល់របបយោធានិយមនៅភូមា ។ ក៏មានជនអន្តោប្រវេសន៍លាវមួយចំនួន ដែលបារម្ភពីស្ថានភាពប្រទេសឡាវ ហើយក៏មានសកម្មជនជាតិហ្វីលីពីនក្រៅប្រទេសមួយចំនួន ព្យាយាមធ្វើឲ្យមានឥទ្ធិពលលើការអភិវឌ្ឍនយោបាយនៅហ្វីលីពីនផងដែរ ។

*ចុងក្រោយ ខ្ញុំគួរតែលើកយករឿងមួយ ដែលធ្វើឲ្យអ្នកចាប់អារម្មណ៍ គឺរឿងសញ្ជាតិពីរ ។ តើអ្នកអាចទាយបានទេថា តើក្រុមណាដែលចង់មានលិខិតឆ្លងដែនពីរមុនគេ ? គឺស្ត្រី ។ ទំនោរបែបនេះកើតឡើងក្រោយឆ្នាំ ១៩១៨ នៅពេលដែលមានស្ត្រីជាច្រើនមានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាពលរដ្ឋពេញសិទ្ធិ នៅអាមេរិកខាងត្បូង អាមេរិកខាងជើង អឺរ៉ុប និងកន្លែងដទៃទៀត ។ ប៉ុន្តែ សិទ្ធិពលរដ្ឋនេះក៏មិនមានស្ថិរភាពផងដែរ ដោយសារតែពួកគេអាចបាត់បង់នៅពេលរៀបការជាមួយជនបរទេស ។ ដោយឡែក បុរសមិនទទួលរងគ្រោះដោយសាររឿងបែបនេះ ។ ឧបមាថា មានក្មេងស្រីបារាំងម្នាក់រៀបការជាមួយបុរសអារហ្សង់ទីន ហើយទៅរស់នៅប្រទេសអារហ្សង់ទីន ។ រដ្ឋាភិបាលអារហ្សង់ទីននិយាយថា គាត់គឺជាកម្មសិទ្ធិរបស់ប្តីគាត់ ហើយគាត់គួរតែប្តូរសញ្ជាតិជាអារហ្សង់ទីនវិញ ។ ប៉ុន្តែ គាត់មានមោទនភាពជាមួយនឹងសញ្ជាតិបារាំង ហើយមិនចង់បោះបង់សញ្ជាតិដើមរបស់ខ្លួនឡើយ ។ ជាបណ្តើរៗ ក៏មានការសម្របសម្រួលមួយរវាងប្រទេសបារាំង និងអារហ្សង់ទីន ។ នៅក្នុងករណីមានការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិបារាំងនិងអារហ្សង់ទីន ភរិយាអាចកាន់លិខិតឆ្លងដែនពីរ និងមានសញ្ជាតិពីរផងដែរ ។ ប៉ុន្តែ បុរសមិនអាចមានឯកសិទ្ធិបែបនេះទេ ។ ភ្លាមនោះ បុរសនឹងច្រណែនស្ត្រី ហើយទាមទារឲ្យអនុម័តច្បាប់ ដែលអនុញ្ញាតឲ្យពួកគេមានសញ្ជាតិពីរផងដែរ ។ បើទោះជាមានជាតិនិយមខ្លាំងយ៉ាងណាក៏ដោយ ក៏មកត្រឹមទសវត្សរ៍ឆ្នាំ ១៩៧០ សហរដ្ឋអាមេរិកត្រូវតែទទួលយកគោលការណ៍សញ្ជាតិពីរ ។*

## សំណួរ–ចម្លើយ

**សំណួរ ៖** *តើខ្ញុំអាចសួរលោកគ្រូពីរឿងជាតិនិយមពីនាយសមុទ្របានដែរឬទេ ? តើជាតិនិយមប្រភេទនេះអាចកើតឡើងជាមួយនឹងចលនាជាតិនិយមផ្សេងទៀតនៅក្នុងប្រទេសមួយបានយ៉ាងដូចម្តេច ? ពីព្រោះខ្ញុំសង្កេតឃើញថា របៀបដែលក្រុមទាំងពីរគិតពីអនាគតប្រទេសរបស់ពួកគេមានភាពខុសគ្នា ។*

**លោកគ្រូ បេង ៖** *ជារឿយៗ វាគឺជាស្ថានភាពដ៏លំបាក ។ ខ្ញុំអាចនិយាយរឿងកំប្លែងមួយពីប្រទេសកំណើតអៀរឡង់របស់ខ្ញុំ ។ ដូចអ្នកបានដឹងហើយថា ជនជាតិអៀរឡង់ជាច្រើនបានធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិកនៅ ស.វ. ទី ១៩ ។ សព្វថ្ងៃនេះ ពួកគេមានចំនួនយ៉ាងច្រើននៅសហរដ្ឋអាមេរិក ។ ពួកគេជាអ្នកកាន់ជើងខាងប្រទេសអៀរឡង់ ហើយពួកគេទាំងអស់គ្នា សុទ្ធតែចង់ប្រារព្ធទិវាបុណ្យខួប សន្តប៉ាទ្រិក* (Saint Patrick's Day) *ដែលជាថ្ងៃបុណ្យជាតិដ៏ធំរបស់អៀរឡង់ នៅញូយ៉ក បូស្តុន និងកន្លែងដទៃទៀត ។ ពួកគេមានសភាពក្លៀវក្លា ប៉ុន្តែគំនិតរបស់ពួកគេស្តីអំពីប្រទេសអៀរឡង់ គឺដូចកាលពី ១០០ ឆ្នាំមុន ដែលវាហួសសម័យទៅហើយ ។ ដូច្នេះ អៀរឡង់នៅក្នុងការស្រមើស្រមៃរបស់ពួកគេ គឺជាអៀរឡង់ដែលពួកគេស្តាប់ពុពីជីដូនជីតារបស់ពួកគេ ។ វាគ្មានអ្វីត្រូវធ្វើជាមួយអៀរឡង់សព្វថ្ងៃទាល់តែសោះ ។ ដូច្នេះ ប្រហែល ៧ ឆ្នាំមុន មានសង្គ្រាមប៉ាកកាយ៉ាងធំនៅក្នុងកាសែតអាមេរិក ពីព្រោះមេដឹកនាំក្រុមអៀរឡង់–អាមេរិកនៅក្នុងសហរដ្ឋអាមេរិក បានចេញសេចក្តីព្រមានមួយថា គ្មានជនជាតិអៀរឡង់ណាដែលស្រឡាញ់ភេទដូចគ្នា អាចចូលរួមក្នុងពិធីបុណ្យសន្តប៉ាទ្រិកបានទេ ពីព្រោះតែពួកនេះលែងជាពលរដ្ឋអៀរឡង់ទៀតហើយ ។ អៀរឡង់ពិតប្រាកដមិនមានមនុស្ស «ដ៏គួរឲ្យ*

*ស្អប់ខ្ពើម» បែបនេះទេ ។ ពិតណាស់ មេដឹកនាំនេះបានទទួលរងការវាយប្រហារពីសំណាក់ក្រុមជាច្រើន ដែលគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា ។ រឿងដែលគួរឲ្យអស់សំណើចនោះគឺថា ក្នុងពេលជំណាលគ្នានេះដែរ នៅឯប្រទេសអៀរឡង់ មានក្បួនដង្ហែសន្តប៉ាទ្រិក ដែលមានមនុស្សច្រើនក្រុមលើរទេះបានចូលរួមប្រកួតប្រជែងគ្នា ។ តើអ្នកទាយទៅមើលថា ក្រុមណាជាអ្នកឈ្នះដោយហេតុតែមានរទេះហ៊ឺហាល្អជាងគេ ? គឺក្រុមស្ត្រីស្រឡាញ់ភេទដូចគ្នា ជាអ្នកឈ្នះ ។ ពួកអ្នកសារព័ត៌មានបានយករឿងនេះទៅឌឺដងមេដឹកនាំអៀរឡង់-អាមេរិក ។ ចម្លើយដែលពួកគេទទួលបាន គឺថា អៀរឡង់ត្រូវបានបំផ្លាញដោយសហភាពអឺរ៉ុប ដូច្នេះជនជាតិអៀរឡង់ពិតប្រាកដ មាននៅតែអាមេរិកប៉ុណ្ណោះ ។ ក្នុងពេលជំណាលគ្នានេះ អ្នកយកការណ៍ព័ត៌មាននៅអៀរឡង់ ក៏បានសើចចំអកឲ្យពួកអៀរឡង់ហួសសម័យនៅអាមេរិក ។ រឿងបែបនេះ គឺជារឿងសាមញ្ញ មិនមែនតែក្នុងចំណោមពួកអន្តោប្រវេសន៍អៀរឡង់ឡើយ ។ ពេលខ្លះ វាជារឿងអស់សំណើច ប៉ុន្តែ ពេលខ្លះ វាអាចនាំឲ្យកើតមានរឿងធ្ងន់ៗ និងអំពើហិង្សា ។ ឧទាហរណ៍ ពួកសិខនៅបរទេសស្រមៃគិតថា ពួកសិខទាំងអស់នៅឥណ្ឌា កំពុងប្រយុទ្ធដើម្បីទាមទារឯករាជ្យ ដូច្នេះពួកគេបានបញ្ជូនអាវុធនិងលុយយ៉ាងច្រើនទៅឲ្យពួកនោះ ។ ប៉ុន្តែ ពួកសិខភាគច្រើននៅឥណ្ឌា រស់នៅសុខស្រួល និងមានសន្តិភាព ។ ដូច្នេះហើយបានជាខ្ញុំនិយាយថា មានចលនាជាតិនិយមគ្រប់ទម្រង់ទាំងអស់កើតមាននៅទ្វីបអាស៊ី ហើយគំនិតដែលលើកឡើងថា ជាតិនិយមនៅអាស៊ីមានលក្ខណៈពិសេស ឬមានតែមួយគ្មានពីរនោះ គ្មានន័យឡើយ ។*

**សំណួរ ៖** *សូមទោស! តើលោកធ្វើចំណាត់ថ្នាក់ជាតិនិយមនៅកម្ពុជាក្រោមបានយ៉ាងដូចម្ដេច ?*

**លោកគ្រូ បេន ៖** *ខ្ញុំជឿថា មានជាតិនិយមលើសពីមួយប្រភេទនៅក្នុងប្រទេសនីមួយៗ ។ គំនិតរបស់ខ្ញុំ គឺយ៉ាងនេះ មានប្រជាជនខ្មែរនៅប្រទេសកម្ពុជា ប៉ុន្តែក៏មានខ្មែរនៅវៀតណាមខាងត្បូង នៅភាគឦសាននិងភាគខាងកើតប្រទេសថៃ ។ តាមតែខ្ញុំដឹង ក៏មានខ្មែរជាច្រើន រស់នៅអាមេរិក កាណាដា បារាំង និងកន្លែងដទៃទៀត ។ ពួកគេប្រហែលជាមានគំនិតផ្សេងគ្នាអំពីកម្ពុជា ។ ប្រហែលជាមានអ្នកខ្លះ មានគំនិតធ្ងន់ៗ ហើយអ្នកខ្លះទៀត មានគំនិតសមហេតុសមផល ។ នៅទីនេះ អ្នកមានស្ថានភាពសកលលោកមួយ ដែលមនុស្សម្នាក់ និងប្រទេសមួយ មិនមានភាពស៊ីសង្វាក់គ្នាល្អទៀតទេ ដែលអ្នកជាតិនិយមសតវត្សរ៍ទី ១៩ ពិបាកនឹងជឿ ។ សព្វថ្ងៃនេះ សង្គ្រាម ការធ្វើទុក្ខបុកម្នេញ ឱកាសសេដ្ឋកិច្ច និងការងារផ្សេងៗ រួមទាំងភាពងាយស្រួលក្នុងការធ្វើដំណើរ មានន័យថា មានមនុស្សកាន់តែច្រើនឡើង មិនបានរស់នៅក្នុងប្រទេសកំណើតខ្លួនឡើយ ។ សំណួរសួរថា តើមានអ្វីកើតឡើង ចំពោះការស្រមៃពីជាតិរបស់ពួកគេទាំងនោះ ? ជនជាតិខ្មែរដែលរស់នៅក្នុងប្រទេសកម្ពុជា ទទួលបទពិសោធន៍ច្បាស់នឹងភ្នែកគ្រប់ពេលវេលា ។ ប៉ុន្តែ សម្រាប់ជនជាតិខ្មែរដែលរស់នៅរដ្ឋកាលីហ្វូរនីញ៉ា ប្រហែលជាគិតពីប្រទេសកម្ពុជា ប្រៀបដូចជាសុបិនមួយអញ្ចឹង ។*

**សំណួរ ៖** *ម្សិលមិញ យើងនិយាយថា ជាតិនិយមទាក់ទងនឹងអតីតកាលនិងបច្ចុប្បន្នកាល ប៉ុន្តែ នៅក្នុងករណីជាតិនិយមពីនាយសមុទ្រ តើវាផ្ដោតតែទៅលើអតីតកាលឬ ? ការលើកឧទាហរណ៍របស់លោកពីប្រទេសអៀរឡង់ ហាក់ដូចជាបន្ទាញថាអញ្ចឹង ។*

**លោកគ្រូ បេន ៖** *ឧទាហរណ៍របស់ខ្ញុំ បង្ហាញឲ្យឃើញពីគំនិតរបស់ពួកជាតិនិយមអៀរឡង់-អាមេរិកាំង ដែលគិតថា អៀរឡង់សព្វថ្ងៃ ត្រូវបានបំពុល ដែលជាប្រភេទគំរូអនាគតមិនល្អ ដែលពួកគេច្រានចោល ។ ពួកគេចង់នាំយកអៀរឡង់អតីតកាលត្រឡប់មកវិញ ។ ប៉ុន្តែ មិនអាចធ្វើទៅកើត ដូច្នេះហើយពួកគេជឿថា អៀរឡង់ពិតប្រាកដដូចអតីតកាល មាននៅអាមេរិក ។ ដូច្នេះ ពួកគេផ្តោតអារម្មណ៍ គឺការស្រមើស្រមៃពីអតីតកាល ។ ម្យ៉ាងទៀត ពួកគេក៏ជាជនជាតិអាមេរិក និងជាអ្នកជាតិនិយមអាមេរិក ដូច្នេះ ពួកគេគិតពីអនាគតរបស់អាមេរិក ។*

**សំណួរ ៖** *ដូច្នេះ តើមានសារៈសំខាន់អ្វី ក្នុងការញែកជាតិនិយមដែលផ្តោតលើអតីកាល ចេញពីជាតិនិយមដែលផ្តោតលើបច្ចុប្បន្នកាល បើជាតិនិយមទាំងពីរនេះ វាមានទំនាក់ទំនងជាមួយគ្នា ?*

**លោកគ្រូ បេន ៖** *អតីតកាលអាចចាត់ទុកថា ជាបេតិកភណ្ឌដ៏មានតម្លៃ ប្រសិនបើអ្នកចង់រក្សាវាទុកដើម្បីអនាគត ។ មូលហេតុដែលគេចង់រក្សាទុក គឺដើម្បីអនាគត នេះមានន័យថា អ្វីដែលអ្នកគិត មានទំនាក់ទំនងជាមួយនឹងបេតិកភណ្ឌ ។ ឧទាហរណ៍ អ្នកមិនចាំបាច់បង្កើតឲ្យមានសាសនានិកាយព្រះនារាយណ៍ (វិស្ណុ) ឡើងវិញនៅប្រទេសកម្ពុជាទេ ។ ប៉ុន្តែ អ្នកពិតជាចង់រក្សាអង្គរឲ្យនៅស្ថិតស្ថេរសម្រាប់អនាគត ។ រាជានិយមគឺជាឧទាហរណ៍ផ្សេងមួយទៀត ។ នៅក្នុងប្រវត្តិសាស្ត្រចិន មានរាជវង្សដឹកនាំជាច្រើន ដូចជា ហាន ថាង សុងមីង និងរាជវង្សផ្សេងទៀត ។ ជាធម្មតា រាជវង្សមួយៗ មានអាយុកាលប្រហែលពី ២០០-៣០០ ឆ្នាំ បន្ទាប់មក ត្រូវដួលរលំពីព្រោះចុះទន់ខ្សោយ និងគ្មានសមត្ថភាពប្រកួតប្រជែង ។ ប្រជាជនរំពឹងបែបនេះ ពីព្រោះពួកគេដឹងថា រាជវង្សថ្មីនឹងចូលមកជំនួសរាជវង្សចាស់ ក្នុងរយៈពេល ២០០-៣០០ ឆ្នាំ ។ គ្មាននរណាធ្លាប់គិតថា ប្រទេសចិនគ្មានស្តេចសោយរាជ្យនោះទេ ។ ប៉ុន្តែ នៅ ស.វ. ទី ២០ រាជាធិបតេយ្យភាគច្រើននៅក្នុងលោក ត្រូវបានបំផ្លាញដោយគ្មានឱកាសរស់ឡើងវិញ និងត្រូវបានជំនួសដោយរបបសាធារណរដ្ឋ ។ ដូច្នេះ យើងអាចសម្លឹងមើលរាជាធិបតេយ្យខ្មែរក្នុងអតីតកាល និងសរសើរពីសមិទ្ធផលមួយចំនួន ដោយមិនចាំបាច់ជឿជាក់ថា នឹងមានរាជាធិបតេយ្យមួយនៅក្នុងប្រទេសកម្ពុជា នាពេល ១០០ ឆ្នាំទៅមុខទៀត ដែលមនុស្សគ្រប់គ្នាជឿថា នឹងមានអាយុកាល ២០០-៣០០ ឆ្នាំ ។ ប្រទេសថៃក៏ជួបបញ្ហាបែបនេះដែរ ។ ព្រះមហាក្សត្រ សព្វថ្ងៃ ទទួលបានការគោរពច្រើន ប៉ុន្តែ មានមូលហេតុជាច្រើន ដែលធ្វើឲ្យគេឆ្ងល់ថា តើប្រទេសថៃនឹងមានរាជាធិបតេយ្យទៀតទេ ក្នុងរយៈពេល ៥០ ឆ្នាំខាងមុខ ។*

**សំណួរ ៖** *តើលោកគ្រូគិតយ៉ាងណាពីបាតុកម្មនៅប្រទេសថៃ ? តើវាមានទំនាក់ទំនងនឹងរាជាធិបតេយ្យយ៉ាងដូចម្តេច ?*

**លោកគ្រូ បេន ៖** *ខ្ញុំមិនគិតថា ការកាន់កាប់ព្រលានយន្តហោះយ៉ាងយូរនៅបាងកក មានទំនាក់ទំនងដោយផ្ទាល់ជាមួយជាតិនិយមឡើយ ប៉ុន្តែមានដោយប្រយោល ។ ពួកអ្នកវាតទីព្រលានយន្តហោះ គិតថា «នេះគឺជាប្រទេសរបស់យើង ។ យើងចង់បិទព្រលានយន្តហោះ ដើម្បីបង្ខំឲ្យរដ្ឋាភិបាលឥតតម្លៃរបស់យើង លាលែងពីតំណែង ។ យើងអាចធ្វើវាបាន បើទោះជាវាបំផ្លាញដល់សេដ្ឋកិច្ចជាតិក៏ដោយ ។» តើអ្នកនៅចាំទេ នៅពេលដែល លោក ថាក់ស៊ីន (ទក្សិណ) នៅជានាយករដ្ឋមន្ត្រី ហើយមានពាក្យចចាមអារ៉ាមថា តួកុនថៃបាននិយាយ*

រឿង ដែលប៉ះពាល់ដល់ប្រទេសកម្ពុជា ? ប្រជាជនខ្មែរភាគច្រើនខឹងសម្បា ហើយបានដុតស្ថានទូតថៃនៅភ្នំពេញ ។ ថាក់ស៊ីនដោះស្រាយបញ្ហាយ៉ាងស្ងប់ស្ងៀម ។ គាត់មិនបញ្ចេញកំហឹង និងតម្លើងសំលេងឡើយ ប៉ុន្តែព្យាយាមរកដំណោះស្រាយសន្តិភាពយ៉ាងលឿន តាមតែអាចធ្វើទៅបាន ។ ខ្ញុំគិតថា អ្នកដែលមិនចូលចិត្តគាត់គិតថា ឥរិយាបថរបស់គាត់ចំពោះប្រទេសកម្ពុជា អាចយកមកប្រើដើម្បីបំផ្លាញគាត់ ។ នេះគឺជាមូលហេតុនៃជម្លោះលើប្រាសាទព្រះវិហារ ដោយក្រុមប្រឆាំងលោក ថាក់ស៊ីន ។ ខ្ញុំមិនគិតថា ពួកអ្នកនយោបាយទាំងនេះ ពិតជាយកចិត្តទុកដាក់លើរឿងប្រាសាទព្រះវិហារឡើយ ។ ប៉ុន្តែ ពួកគេមិនអាចយកឈ្នះលោក ថាក់ស៊ីន នៅក្នុងការបោះឆ្នោតទូទៅបាន ។ ដូច្នេះ ពួកគេមួយចំនួន បានធ្វើរឿងអាក្រក់ជាងតារាភាពយន្តថៃទៅទៀត ។ ពួកគេនិយាយថា ប្រជាជនថៃនៅទីជនបទភាគច្រើនឆ្កួត និងគ្មានការអប់រំ ដែលមិនសមធ្វើជាពលរដ្ឋឡើយ ។ ពួកគេមិនគួរណាបានសិទ្ធិឲ្យបោះឆ្នោតទេ ។ សូម្បីតែរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៥ ក៏មានអនុវែមួយចែងថា មានតែពួកមានសញ្ញាបត្រខ្ពស់ទេ ដែលអាចក្លាយជាសមាជិករដ្ឋសភា ។ នៅក្នុងជីវិតពិត ប្រសិនបើអ្នកមានលុយ អ្នកអាចទទួលបានសញ្ញាបត្រពីសកលវិទ្យាល័យជាច្រើននៅក្នុងប្រទេស ។ ប៉ុន្តែ ប្រយោគនោះក៏មិនល្អដែរ ។ ប្រសិនបើអ្នកជាអ្នកជាតិនិយមពិតប្រាកដ អ្នកមិនអាចមាក់ងាយជនរួមជាតិរបស់ខ្លួននោះទេ ។

**លោកត្រូ ឆានវិត (ជាញវិទ្យ)៖** មានព័ត៌មានមិនល្អចំពោះប្រទេសថៃនិងប្រទេសកម្ពុជា ពីព្រោះលោកក្បិត ភិរម្យ (กมิต ภิรมย์) ដែលជាមនុស្សនៅជាមួយពួក «ពន្ធមិត្រប្រជាជនដើម្បីប្រជាធិបតេយ្យ» (พันธมิตรประชาชนเพื่อประชาธิปไตย) អស់ពេលជាយូរមកហើយនោះ នឹងក្លាយជារដ្ឋមន្ត្រីការបរទេសថ្មី ។ ដូច្នេះ អ្នកនឹងឃើញមានបញ្ហាកាន់តែច្រើនឡើងនៅតាមព្រំដែន ។ សហគមន៍ពាណិជ្ជកម្មថៃនៅកម្ពុជា មិនសប្បាយចិត្តនោះទេ ។ ខ្ញុំគិតថា អ្វីដែលលោកសាស្ត្រាចារ្យ អាន់ឌឺរសុន និយាយអំពីជាតិនិយមបែបផ្លូវការ នៅមានឥទ្ធិពលខ្លាំងនៅប្រទេសថៃ ប្រសិនបើអ្នកសម្លឹងមើលប្រទេសថៃក្នុងបរិបទសកល ។ ប្រទេសថៃបានក្លាយជាប្រទេសអភិរក្សនិយម ។ ពេលខ្លះ ខ្ញុំចូលចិត្តប្រើពាក្យថា ដើរថយក្រោយ ។ ពួកគេអន់ថយ និងហាក់ដូចជាល្ងង់ខ្លៅពិសេសពួកអ្នកដឹកនាំវណ្ណៈវរជនទាំងនោះ ។ ខ្ញុំមិនដឹងថា តើអ្នកនៅចាំពីបញ្ហាសុំបញ្ចូលប្រាសាទព្រះវិហារទៅក្នុងអង្គការយូណេស្កូដែរឬទេ ។ រដ្ឋមន្ត្រីក្រសួងការបរទេសកំលុងរបបយោធារបស់សុរយុទ្ធ គឺលោក និត្យពិបូលសង្គ្រាម (นิตย์ พิบูลสงคราม) ។ ឪពុករបស់គាត់ គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលបានយកខេត្តសៀមរាប បាត់ដំបង និងព្រះវិហារ (នៅអំឡុងសង្គ្រាមលោកលើកទី ២) ។ ឪពុករបស់គាត់ គឺជាអ្នកដែលបានប្តូរឈ្មោះខេត្តសៀមរាបទៅជាចន្ទបុរី ។ ដូច្នេះហើយបានជាបញ្ហាទាំងអស់ កើតមាននៅពេលដែលកម្ពុជាបញ្ជូនសំណើទៅកាន់ ក្រុងគ្រិស្តឆឺច នៅប្រទេសនូវែលហ្សេលង់ (ប្រទេសញូហ្ស៊ីឡែន) និងក្រុងកេបិក (ប្រទេសកាណាដា) ។ ដូច្នេះ ខ្ញុំចង់មានន័យថា ជាតិនិយមផ្លូវការរបស់រដ្ឋ នៅមានឥទ្ធិពលខ្លាំង ។ ដូច្នេះ វាប្រហែលជានឹងមានបញ្ហាច្រើនថែមទៀត ។ ពួកគេមានបញ្ហាច្រើននៅបាងកក ។ ពួកគេអាចប្រើកម្ពុជានិងឡាវ ធ្វើជាលេសដោះសា ។ វាអាក្រក់ខ្លាំងណាស់ ។ ដូច្នេះ វាប្រហែលជាដូចទៅនឹងទំនាយដែលថា «បាងកករលំ ភ្នំពេញរលាយ ព្រៃនគរខ្ចាត់ខ្ចាយ សប្បាយអង្គរវត្ត ។» ប្រជាជននៅសុរិន្ទ ក៏និយាយពីពាក្យទំនាយនេះផងដែរ ។

ត្រឡប់ទៅករណីប្រទេសកម្ពុជាវិញ ខ្ញុំបានឮមន្ត្រីជាន់ខ្ពស់ម្នាក់និយាយថា អស់រយៈពេល ៣០-៤០ ឆ្នាំមកនេះកម្ពុជាបានបាត់បង់ព្រលឹង ពីព្រោះតែសង្គ្រាមស៊ីវិលយ៉ាងយូរ និងជម្លោះនៅក្នុងប្រទេស ។ ជាតិនិយមកម្ពុជា

*និងព្រលឹងជាតិបានបាត់បង់ ។ ប៉ុន្តែ ខ្ញុំគិតថា ករណីរឿងតាពភាពយន្តថៃ និងរឿងប្រាសាទព្រះវិហារ ឥឡូវនេះ គឺជាផ្លូវនាំយកព្រលឹងជាតិត្រឡប់មកវិញ ។ ដូច្នេះ ខ្ញុំគិតថា ជាតិនិយមនៅកម្ពុជា ឥឡូវនេះ កំពុងតែកើតឡើងវិញ ដោយសារប្រទេសជិតខាង ដូចជារឿងដែលថៃកំពុងធ្វើ ។ ដូច្នេះ វាមិនមែនកើតចេញតែពីបញ្ហានយោបាយខាងក្នុងប្រទេសមួយមុខនោះទេ ដែលបង្កើតជាតិនិយមបាន ។ ប៉ុន្តែ ប្រហែលជាកើតចេញពីប្រទេសជិតខាងផងដែរ ព្រោះប្រទេសកម្ពុជាត្រូវបានបំបែកឥតឈប់ឈរនៅក្នុងប្រវត្តិសាស្ត្រ ។ មនុស្សលែងជឿទុកចិត្តគ្នានៅក្នុងសម័យខ្មែរក្រហម និងសម័យកាលវៀតណាម ។ ដូច្នេះ ជាតិនិយមខ្មែរបានបាត់បង់ ។ ប្រហែលជាក្នុងករណីជាមួយប្រទេសថៃ ដែលជាតិនិយមកម្ពុជាចាប់ផ្តើមរះឡើងវិញ ។*

**លោកគ្រូ បេន ៖** *ខ្ញុំចង់បន្ថែមចំណុចខ្លះ ។ ជាតិនិយមមានលក្ខណៈចម្លែកៗ ជាច្រើន ។ តើអ្នកធ្លាប់មានបទពិសោធន៍ទៅកន្លែងណាមួយជាមួយឪពុកម្តាយរបស់អ្នក ជីដូនជីតា ឬក៏សមាជិកគ្រួសារណាមួយរបស់អ្នក កាលពីកុមារភាពទេ ។ ហើយពួកគេបានធ្វើរឿង ដែលបណ្តាលឲ្យអ្នកមានភាពអាម៉ាស់ ហើយអ្នកគិតថា អ្នកមិនគួរណានៅទីនោះជាមួយនឹងពួកគេ ដែរឬទេ ? អ្នកប្រាថ្នាចង់ឲ្យខ្លួនអ្នកអវត្តមាននៅក្នុងហេតុការណ៍នោះ ប៉ុន្តែ មិនអាចទៅរួចទេ ពីព្រោះតែពួកគេជាញាតិសន្តានរបស់អ្នក ។ ខ្ញុំគិតថា វាជារឿងសំខាន់សម្រាប់អ្នកជាតិនិយមដ៏ល្អម្នាក់ក្នុងការសម្រួបខ្លួនទៅនឹងភាពអាម៉ាស់ក្នុងបុព្វហេតុជាតិ ។ វាបង្ហាញថា អ្នកពិតជាស្រឡាញ់ប្រទេសរបស់អ្នក និងចង់ឲ្យប្រទេសនេះមានការរីកចម្រើន ។ ជនជាតិអាមេរិកភាគច្រើន រួមទាំងមនុស្សចាស់ផង បានចូលរួមយ៉ាងសកម្មក្នុងចលនាប្រឆាំងនឹងសង្គ្រាមវៀតណាម នាកំលុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ពីព្រោះតែពួកគេមានការអាម៉ាស់នឹងអ្វីដែលអាមេរិកកំពុងធ្វើនៅឥណ្ឌូចិន ។ ដូច្នេះ ការអាម៉ាស់នាំអ្នកឲ្យកាន់តែសកម្មឡើង ក្នុងការផ្លាស់ប្តូរប្រទេសរបស់អ្នកឲ្យកាន់តែប្រសើរ ។ វាផ្ទុយនឹងពាក្យស្លោកអតិរេកជាតិនិយមដែលថា «ប្រទេសរបស់ខ្ញុំ ត្រូវឬក៏ខុស» ។*

**សំណួរ ៖** *ខ្ញុំចង់ដឹងបន្ថែមទៀតពីរឿងខ្មែរក្រោម ដែលចង់បង្កើតរបបសាធារណរដ្ឋនៅវៀតណាមខាងត្បូង ។ តើវាមានមនុស្ស ៥ នាក់ឬក៏ ១០ ម៉ឺននាក់? បាទ ពួកគេកំពុងរស់នៅកាលីហ្វូរនីញ៉ា ។ វាជាជាតិនិយមពីនាយសមុទ្រ ។ តើយើងអាចមើលលើគំនិតរបស់ពួកគេភ្ជាប់ទៅនឹងប្រព័ន្ធនយោបាយក្នុងប្រទេស ដែលពួកគេកំពុងរស់នៅបានដែរឬទេ ?*

**លោកគ្រូ បេន ៖** *ខ្ញុំគិតថា ប្រសិនបើអ្នកជាខ្មែរក្រោម ដែលរស់នៅក្នុងប្រទេសវៀតណាម អ្នកប្រហែលជាត្រូវដោះស្រាយបញ្ហាប្រឈមមុខជាក់ស្តែង និងព្យាយាមរកមើលអ្វី ដែលអាចធ្វើទៅបាន ។ វាខុសពីពួកខ្មែរក្រោម ដែលរស់នៅស៊ីអាថល និងកាលីហ្វូរនីញ៉ា ។ អ្នកអាចធ្វើអ្វីៗ ដែលអ្នកចង់ធ្វើ ។ គ្មាននរណាម្នាក់ចាប់អ្នកដាក់គុកទេ ដូច្នេះ វាងាយស្រួលក្នុងការធ្វើរឿងឆ្កួតៗ ប្រសិនបើអ្នកចង់ ។ អ្នកអាចបញ្ជូនអាវុធឬលុយ ប៉ុន្តែ វាមិនមែនជារូបអ្នកទេ ដែលនឹងទទួលរងការឈឺចាប់ តែអ្នកដែលរងគ្រោះគឺប្រជាជនដែលរស់នៅក្នុងប្រទេសវៀតណាម ។ នយោបាយបែបនេះ វាមិនចម្លែកនោះទេចំពោះខ្មែរ ។ អ្នកអាចឃើញករណីស្រដៀងគ្នានេះជាច្រើន ជាពិសេសមនុស្សដែលរស់នៅក្នុងប្រទេសអ្នកមាន ដែលមានការចងចាំមិនល្អ មានមនសិការមិនល្អ អ្នកមានលុយច្រើន និងគ្មានទំនួលខុសត្រូវ ។*

*ខ្ញុំនៅចាំលោកសាស្ត្រាចារ្យចាស់ម្នាក់ ដែលខ្ញុំបានជួបនៅអាមេរិក កាលពីប៉ុន្មានឆ្នាំមុន ។ គាត់គឺជាជនជាតិសិខ និងជាមនុស្សដ៏ល្អម្នាក់ ។ គាត់មិនសប្បាយចិត្តនិងកូនប្រុសរបស់គាត់ ដែលជាអ្នកជំនួញមានជោគជ័យនៅកាណាដា ។ កូនរបស់គាត់ ចំណាយពេលទំនេរទាំងអស់របស់គេ ដើម្បីធ្វើសកម្មភាពយ៉ាងសកម្មគាំទ្រដល់សមាជិកចលនាហិង្សាដើម្បីរដ្ឋឯករាជ (រដ្ឋខាលិស្ថាន) នៅឥណ្ឌា ។ ពួកគេថែមទាំងបានរៀបចំធ្វើឃាតនាយករដ្ឋមន្ត្រី ឥន្ទិរា គន្ធី ទៀតផង ។ កូនប្រុសរបស់គាត់ តែងតែបញ្ជូនសារ បង្កើតគេហទំព័រ ផ្ញើលុយ និងលើកទឹកចិត្តក្មេងកំលោះៗ ឲ្យធ្វើសង្គ្រាម ។ ឪពុកបាននិយាយទៅកាន់កូនប្រុសថា «តើឯងកំពុងធ្វើរឿងនេះដើម្បីអ្វី ?» កូនប្រុសឆ្លើយថា «ខ្ញុំពិតជាសរសើរដល់ក្មេងប្រុស និងអ្នកដែលក្លាហានប្រយុទ្ធដើម្បីឯករាជ្យប្រទេសរបស់យើងទាំងនេះណាស់ ។ ខ្ញុំត្រូវតែធ្វើអ្វីគ្រប់យ៉ាង ដើម្បីគាំទ្រពួកគេ ។ ខ្ញុំអាចជួយពួកគេជាមួយអ៊ីនធើណេត លុយ អាវុធ និងរបស់ផ្សេងទៀត ។» ឪពុកនិយាយថា «ចុះក្រែងឯងមានកូនប្រុសពីរនាក់ អាយុ ១៩ និង ២០ ឆ្នាំដែរ ។ ហេតុអ្វីបានជាឯងមិនបញ្ជូនពួកគេឲ្យទៅប្រយុទ្ធនៅប្រទេសឥណ្ឌាទៅ ប្រសិនបើឯងចង់យ៉ាងដូច្នេះ?» លោកសាស្ត្រាចារ្យចាស់បានសើចហើយនិយាយមកកាន់ខ្ញុំថា «តើអ្នកអាចស្មានបានទេថា តើកូនរបស់ខ្ញុំឆ្លើយតបមកខ្ញុំថាយ៉ាងដូចម្តេច ?» កូនរបស់ខ្ញុំនិយាយថា «ថាម៉េច ? បញ្ជូនកូនប្រុសខ្ញុំឲ្យទៅច្បាំងនៅឥណ្ឌា ? មូលហេតុចម្បងដែលខ្ញុំមកកាណាដានេះ គឺដើម្បីឲ្យកូនរបស់ខ្ញុំមានសុវត្ថិភាព!» ។*

**លោកគ្រូ ឆានវិត៖** *ដូចលោកបាននិយាយពីរឿងជាតិនិយមពីនាយសមុទ្រ ខ្ញុំចង់និយាយពីរឿងនេះ ដោយលើកយកបទពិសោធន៍របស់ពួកអ្នកជាតិនិយមលាវមកនិយាយ ។ មានពួកជាតិនិយមលាវយ៉ាងច្រើននៅអាមេរិក ហើយពួកគេទទួលបានជោគជ័យច្រើននៅក្នុងជីវិត ។ មានអ្នកខ្លះធ្លាប់ជាមិត្តរួមថ្នាក់របស់ខ្ញុំ នៅបាងកកដែលមកពីលាវ ហើយឥឡូវរស់នៅកាលីហ្វូរនីញ៉ា ។ មនុស្សទាំងនេះមានគំនិតជាតិនិយមជ្រុលបន្តិច ហើយពួកគេធ្វើការជាមួយពួកអភិរក្សស្តាំនិយម ។ ពួកគេអាចត្រឡប់មកប្រទេសលាវវិញ ។ ប្រសិនបើអ្នកតាមដានព័ត៌មានអ្នកនឹងរកឃើញបញ្ហាមួយចំនួននៅតាមបណ្តោយព្រំដែនឡាវ-ថៃ ។ វាមិនមែនជាបញ្ហារបស់រដ្ឋាភិបាលឡាវនិងរដ្ឋាភិបាលថៃឡើយ ប៉ុន្តែ វាគឺជាបញ្ហារបស់អ្នកដែលមកពីកាលីហ្វូរនីញ៉ា ។ នៅពេលដែលពួកគេធ្វើដំណើរត្រឡប់ពីកាលីហ្វូរនីញ៉ា ពួកគេត្រូវចូលតាមបាងកក ហើយបន្តទៅព្រំដែន ហើយបង្កើតបញ្ហាយ៉ាងច្រើនដល់រដ្ឋាភិបាលឡាវ ។ ដូច្នេះ នេះគឺជាប្រភេទនៃការឡើងចុះ (ទៅមក) គ្រប់ពេលវេលា ។ ខ្ញុំគិតថា ជាតិនិយមពីនាយសមុទ្រនេះ ក៏ស្រដៀងគ្នានឹងជនជាតិវៀតណាមនៅកាលីហ្វូរនីញ៉ា ដែលមកបង្កើតបញ្ហាឲ្យរដ្ឋាភិបាលទីក្រុងហាណូយផងដែរ ។ តើអ្នកមានជាតិនិយមប្រភេទនេះនៅកម្ពុជាដែរឬទេ ? មូលដ្ឋានធំប្រហែលជានៅបារាំងនិងហាវ៉ៃ ហើយបានមកបង្កបញ្ហាឲ្យលោក ហ៊ុន សែន ។*

**លោកគ្រូ បេង៖** *វាជាកំហុសមួយក្នុងការគិតថា ជាតិនិយមតែងតែត្រូវការសត្រូវខាងក្រៅ ។ ក្នុងកាលៈទេសៈភាគច្រើន វាមិនសំខាន់នោះទេ ជាពិសេសប្រសិនបើស្ថានភាពដំណើរការទៅរលូន ។ រឿងល្អមួយពីជាតិនិយមគឺថា វាជំរុញឲ្យមនុស្សប្រព្រឹត្តល្អចំពោះគ្នា ។ អ្នកគឺជាបងប្អូនប្រុសស្រី ។ អ្នកព្យាយាមគោរពច្បាប់ ។ ខ្ញុំគិតថា វាគឺជារឿងដ៏មានអត្ថប្រយោជន៍មួយ ។ ពេលខ្លះ ខ្ញុំខឹងនឹងជាតិនិយមអាមេរិក ។ ប៉ុន្តែថា តើកន្លែងនេះនឹងទៅជាយ៉ាងណា ប្រសិនបើគ្មានជាតិនិយមនោះ ? មានការប្រើប្រាស់កាំភ្លើងយ៉ាងច្រើននៅអាមេរិក ហើយអត្រាធ្វើឃាត*

*ក៏មានកម្រិតខ្ពស់ផងដែរ ។ ហើយបើគ្មានជាតិនិយមទេនោះ មនុស្សនឹងបាញ់គ្នាគ្រប់ពេលវេលា ។ ខ្ញុំក៏គិតផងដែរថា មិនសូវមានបទចម្រៀងស្អប់សត្រូវរបស់ប្រទេសអ្នកទេ ប៉ុន្តែមានបទចម្រៀងជាច្រើនច្រៀងពីការស្រឡាញ់ជាតិរបស់អ្នក ។*

**លោកគ្រូ បេន៖** *តើអ្នកមានចម្រៀងច្រៀងថា ថៃគឺជាលាមកដែរឬទេ ?*

**ចម្លើយ៖** *យើងមានតែបទចម្រៀង ដែលនិយាយចំអកតែប៉ុណ្ណោះ ។ យើងមានបទចម្រៀងតិចតួចដែលចំអកថៃ ។*

**លោកគ្រូ បេន៖** *ការនិយាយចំអក វាខុសពីការស្អប់ ។ ក្នុងទំនាក់ទំនងរបស់មនុស្ស តែងតែមានការចំអកលេងជាធម្មតា ។*

**សំណួរ៖** *តើមានចលនាអន្តរជាតិក្នុងចំណោមខ្មែរសុរិន្ទដែរឬទេ ?*

**លោកគ្រូ ឆានវិត៖** *ខ្ញុំមិនគិតថា វាជាចលនានោះទេ ។ វាគឺជាអារម្មណ៍រវាងខ្មែរនៅសុរិន្ទនិងនៅប៊ុរីរ៉ាំ (ប៊ុរីរម្យ) ។ មានអ្នកនយោបាយថៃខ្លះ គឺជាខ្មែរ ហើយពួកគេប្រើភាសាខ្មែរនៅក្នុងយុទ្ធនាការបោះឆ្នោត នៅក្នុងស្រុករបស់ពួកគេ ។ រឿងនោះគឺថា អ្នកដែលមានឈាមជ័រខ្មែរបានទទួលការលើកតម្កើង ។ មានឈាមជ័រជាជាតិខ្មែរ មិនមែនជាឧបសគ្គឡើយ ។ ជាការពិត មេដឹកនាំបក្សប្រជាធិបតេយ្យ* (พรรคประชาธิปัตย์) *គឺខ្មោចលោក ឃួង អភ័យវង្ស* (ควง อภัยวงศ์) *មានប្រភពកំណើតចេញពីបាត់ដំបង ។ ឪពុករបស់លោក គឺជាលោកម្ចាស់បាត់ដំបងចុងក្រោយបំផុត គឺរហូតដល់ឆ្នាំ ១៩០៧ ។ រីឯប្អូនជីដូនមួយស្រីរបស់លោក ឃួង ម្នាក់ បានក្លាយជាព្រះរាជទេពីនៃព្រះចៅ ព្រះរាម ទី ៦ ។ ព្រះនាមរបស់ព្រះរាជទេពីនោះ គឺ ព្រះនាងសុវទនា ជាព្រះមាតានៃព្រះនាងសម្តេចព្រះចៅភគិនីថី ចៅហ្វា ពេជ្ររតនរាជសុតា (សព្វថ្ងៃនេះ មានព្រះជន្មាយុ ៨៤ ឆ្នាំ) ។*

*រដ្ឋាភិបាលថ្មីរបស់ថៃ អាចកើតឡើងបាន ក៏ដោយសារតែមានការចូលរួមមួយផ្នែកតូចរបស់លោក នេវិន*[១] *នៅប៊ុរីរម្យផងដែរ ។ លោក នេវិន គឺជាខ្មែរប៊ុរីរម្យ ។ គាត់និយាយភាសាខ្មែរ ។ ខ្ញុំគិតថា ប្រសិនបើអ្នកច្រានចោលវា (ការនិយាយភាសាខ្មែរនៅថៃ) ស្ថានភាពនឹងអាក្រក់ដូចនៅភាគខាងត្បូង ប៉ុន្តែមិនមែននៅសុរិន្ទនិងប៊ុរីរម្យនោះទេ ។*

---

**(១)** កំណត់បណ្ណាធិការ ៖ លោក នេវិន ឈិតឆប (เนวิน ชิดชอบ) កើតនៅថ្ងៃទី ៤ ខែតុលា ឆ្នាំ ១៩៥៨ ជាអ្នកតំណាងរាស្ត្រខេត្តបុរីរម្យច្រើនអាណត្តិ ហើយក៏ធ្លាប់បម្រើការក្នុងរាជរដ្ឋាភិបាលថៃច្រើនអាណត្តិដែរ ។ គាត់បានចូលជាសមាជិកគណបក្សសហប្រជាធិបតេយ្យ (គ.ស. ១៩៨៦) រួចបានក្លាយជាសមាជិកបក្សចឹតថៃ (បក្សលើកស្ទួយថៃ) (គ.ស. ១៩៨៨) បន្ទាប់មក ជាសមាជិកបក្សសាមគ្គីធម៌ (គ.ស. ១៩៩២) ។ នៅឆ្នាំដដែលនោះ (១៩៩២) គាត់បានចុះចូលបក្សជាតិថៃ ។ នៅឆ្នាំ ១៩៩៦ លោក នេវិន បានចូលជាសមាជិកបក្សឯកភាព ។ នៅឆ្នាំ ២០០១ គាត់ត្រឡប់ជាសមាជិកបក្សជាតិថៃវិញ ប៉ុន្តែនៅឆ្នាំ ២០០៤ គាត់ក្លាយជាសមាជិកបក្សថៃរ៉ាក់ថៃ (ថៃស្រឡាញ់ថៃ) ដែលក្រោយមក បានដូរឈ្មោះជា បក្សពលំប្រជាជន ។ នៅឆ្នាំ ២០០៨ គាត់បានចេញពីបក្សនេះ និងចុះចូលបក្សប្រជាធិបត្យ ។ សព្វថ្ងៃនេះ→

**សំណួរ៖** *តើពួកគេមានអារម្មណ៍ថាមានទំនាក់ទំនងជាមួយខ្មែរនៅកម្ពុជាដែរឬទេ ?*

**លោកគ្រូ ឆានវិត៖** *ព្រំដែនបើកចំហចំពោះពួកគេ ។ សូម្បីតែឥឡូវនេះ បើទោះជាមានបញ្ហាច្រើននៅព្រះវិហារក៏ដោយ ក៏ខ្ញុំទើបតែបាននិយាយជាមួយខ្មែរសុរិន្ទម្នាក់កាលពីម្សិលមិញ ។ គាត់បានធ្វើដំណើរមកកម្ពុជា ។ គាត់និយាយថា ពួកគេអាចទៅមកបាន ។ ខ្ញុំគិតថា ព្រំដែនបើកចំហច្រើន ។ អារម្មណ៍របស់ខ្ញុំគឺថា ប្រជាជនដែលមានឈាមជ័រជាខ្មែរ និងលាវ នៅភាគឦសាន ប្រហែលជាមិនបានគិតពីរឿងប្រទេសកម្ពុជាប៉ុន្មានទេ ។ ឥឡូវនេះ វាមិនទាន់ត្រូវពេលវេលានោះទេ ។ នៅទីនោះ ប្រជាជនក្រខ្សត់ណាស់ ។ ប៉ុន្តែ ខ្ញុំគិតថា ពួកគេមិនគិតបុយល់ឃើញ ដូចពួកនៅភាគខាងត្បូងឡើយ ។ ខ្ញុំបានសង្កេតពីអារម្មណ៍ផ្សេងគ្នារវាងប្រជាជនខ្មែរនៅសុរិន្ទ និងប្រជាជនខ្មែរនៅវៀតណាមខាងត្បូង ។ អ្នកឃើញហើយថា ខ្មែរនៅវៀតណាមខាងត្បូង តែងតែធ្វើដំណើរចូលមកកម្ពុជា ដើម្បីស្វែងរកជីវិតប្រសើរ ។ ប៉ុន្តែ ខ្មែរភាគច្រើននៅភាគខាងជើងក្នុងទឹកដីនៃប្រទេសថៃ ប្រហែលជាគិតខុសពីនេះ ។*

*ខ្ញុំសូមសួរអ្នកពីរឿងអត្តសញ្ញាណ ដែលលោកគ្រូបេនបានលើកឡើង ។ ខ្ញុំនៅចាំថា ពេលខ្ញុំទៅដល់សុរិន្ទនិងបុរីរម្យដំបូង ក្នុងចិត្តខ្ញុំគិតថា វាគឺជាតំបន់នៅដាច់ស្រយាលមួយ ។ ខ្ញុំបានជួបប្រជាជនសុរិន្ទយ៉ាងច្រើន ។ ខ្ញុំសួរពួកគេថា តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះកម្ពុជា ? តើអ្នកគិតបែបណាចំពោះសម្ដេចសីហនុ ? ពួកគេគិតថា នេះជាសំណួរឆ្កួតៗ របស់អ្នកបាងកក ។ បន្ទាប់មក ខ្ញុំយល់ពីអត្តសញ្ញាណជាអ្នកសុរិន្ទរបស់ពួកគេ ។ ពួកគេត្រូវឲ្យតម្លៃលើចំណុចថា តើអ្នកជានរណា ? យើងជាខ្មែរសុរិន្ទ ។ ខ្ញុំមិនគិតថា ពួកគេភ្ជាប់ខ្លួនគេជាមួយកម្ពុជានោះទេ ។ ខ្ញុំក៏មិនគិតថា ពួកគេធ្លាប់ឮពីរឿងព្រះបាទ ជ័យវរ្ម័ន ទី ៧ ដែរ ។ ខ្ញុំមានរឿងគួរឲ្យចាប់អារម្មណ៍មួយ នៅពេលដែលខ្ញុំនៅស្រុកថៃ ។ ខ្មែរសុរិន្ទមិនដែលនិយាយថា ពួកគេជាខ្មែរ ។ ពួកគេគឺជាថៃទេ ។*

*ខ្ញុំមិនគិតថា ពួកគេនិយាយថា ពួកគេជាថៃនោះទេ ។ ពួកគេអាចនិយាយថា ពួកគេជាអ្នកសុរិន្ទ ។ ប្រសិនបើខ្មែរសុរិន្ទស្ថិតរស់នៅសិង្ហបុរីវិញ ពួកគេនឹងនិយាយថា ពួកគេជាថៃមកពីសុរិន្ទ ។ ខ្ញុំគិតថា វាអាស្រ័យលើកន្លែងដែលពួកគេស្ថិតនៅ ។ ជាទូទៅ ប្រសិនបើអ្នកជាខ្មែរសុរិន្ទធ្វើដំណើរទៅបាងកក អ្នកនិយាយថាអ្នកជាអ្នកសុរិន្ទ ។*

*ប៉ុន្តែ ខ្ញុំគិតថា វាអាស្រ័យលើនរណាជាអ្នកសួរសំណួរផងដែរ ។ ខ្ញុំចង់មានន័យថា ប្រសិនបើខ្មែរជាអ្នកសួរសំណួរ វាខុសពីអ្នកបាងកកជាអ្នកសួរ ។ ខ្ញុំគិតថា ពួកគេនិយាយបែបនោះ ពីព្រោះតែអ្នកជាអ្នកសួរសំណួរ ។*

**ចម្លើយ៖** *ខ្ញុំនៅចាំរឿងរ៉ាវរបស់អ្នកបើកឡានតាក់ស៊ីម្នាក់ ដែលនិយាយខ្មែរមកកាន់ខ្ញុំ ។ ខ្ញុំសួរគាត់ថា អ្នកជាខ្មែរឬ ? គាត់ឆ្លើយថា មិនមែនទេ ។ ខ្ញុំជាថៃ ។ ខ្ញុំសួរគាត់ជាភាសាថៃ ។*

---

↲ គាត់នៅក្នុងគណបក្សថ្មីមួយ ពោលគឺ បក្សភូមិចៃថៃ (បក្សមោទនភាពថៃ) ដែលបានចូលរួមក្នុងរដ្ឋាភិបាលជាមួយបក្សប្រជាធិប័ត្យ និងគណបក្ស ៤ ទៀត ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី អភិសិទ្ធ វេជ្ជាជីវៈ ។

មានអ្នកខ្លះដាក់ឈ្មោះក្រៅហៅលោក នេវិន ថា « ឈ្មោះភូមា មុខលាវ និយាយខ្មែរ » (ชื่อพม่า หน้าลาว เว้าเขมร /ឈឺផះម៉ា ណាឡាវ វ៉ាវខះម៉េន/) ព្រោះឈ្មោះ នេវិន នេះមកពីឪពុកគាត់ដាក់ តាមឈ្មោះអតីតមេទាហានផ្ដាច់ការភូមា ដែលឪពុកគាត់កោតសរសើរ ហើយម្យ៉ាងទៀត ពេលធ្វើយុទ្ធនាការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រប្រចាំខេត្តបុរីរម្យ លោក នេវិន ចូលចិត្តឃោសនាជាភាសាខ្មែរ ៕

**លោកគ្រូ ឆានវិត៖** *ខ្ញុំយល់ពីអ្វីដែលអ្នកចង់និយាយ ។ ប្រសិនបើអ្នកនិយាយថា អ្នកជាខ្មែរ ប៉ូលិសប្រាកដនឹងចាប់អ្នក ពីព្រោះអ្នកឆ្លងដែនខុសច្បាប់ ។ ដូច្នេះ ខ្ញុំចង់និយាយសំដៅដូចលោកគ្រូបេនដែរ ហើយខ្ញុំក៏មានមិត្តភក្តិនៅសុរិន្ទ ដែលពួកគេមួយចំនួនបានធ្វើដំនួញនៅបាងកកទៀតផង ។ ពិតណាស់ ពួកគេមានសញ្ជាតិថៃ ដូច្នេះ ពួកគេមិនខ្លាចនោះទេ ។*

*ខ្ញុំធ្លាប់ឮខ្លះដែរ ប៉ុន្តែ ខ្ញុំមិនគិតថា នោះគឺជាការពន្យល់ដ៏សមស្របនោះទេ ។ គាត់និយាយថា នៅពេលដែលគាត់មកដល់កម្ពុជា គាត់ឃើញថា អ្នកនៅភ្នំពេញសើចគាត់ ពីព្រោះគាត់និយាយភាសាសុរិន្ទកាលពីរាប់រយឆ្នាំមុន ហើយស្តាប់ទៅគួរឲ្យចង់សើច ។ គាត់និយាយថា អ្នកនៅភ្នំពេញមានបុកខ្ពស់ និងមាក់ងាយពួកគាត់ ។*

*រឿងមួយទៀត ខ្មែរសុរិន្ទនិយាយថា ខ្មែរនៅភ្នំពេញ គឺជាខ្មែរក្រោម មិនមែនខ្មែរកណ្តាលទេ ។ ខ្មែរនៅភ្នំពេញមិនល្អទេ ។ យើងជាខ្មែរសុរិន្ទឆ្លាតជាង និងមានជីវភាពរស់នៅគ្រាន់បើជាង ។ ដូច្នេះ ខ្មែរនៅភ្នំពេញឥឡូវ ដូចជាមិនសូវឆ្លាតទេ ។*

**លោកគ្រូ បេន៖** *ចំណុចត្រង់នេះបញ្ជាក់ថា មនុស្សស្ទើរតែគ្រប់គ្នា ចូលចិត្តមើលងាយអ្នកដទៃ ៕*

# ការខំរកឃើញអាស៊ីអាគ្នេយ៍ពីខាងក្នុង ៖ តើការសិក្សាអំពីអាស៊ីអាគ្នេយ៍នៅប្រទេសថៃ នៅឯណា? *

ដោយ ទង់ជ័យ វិនិច្ចកូល (ថុងឆៃ វិនិតចះគូន)
សាកលវិទ្យាល័យវិស្កុនស៊ិន-ម៉ាឌីហ្សុន (សហរដ្ឋអាមេរិក)

ក្នុងរង្វង់សាស្ត្រាចារ្យនិងនិស្សិតថៃ ដែលមានចំណាប់អារម្មណ៍នឹងការសិក្សាអំពីអាស៊ីអាគ្នេយ៍ គេមានជំនឿទូទៅថា ថៃ[(១)] ស្គាល់អាស៊ីបូព៌ា និង បស្ចិមប្រទេស ច្រើនជាងប្រទេសជិតខាងរបស់ខ្លួន ។ លោក ជាញវិទ្យ ក្សេត្រសិរិ (ឆានវិត កៈសេតស៊ិរិ) ដែលបច្ចុប្បន្នកាលនេះ ជាអ្នកជំរុញឲ្យការសិក្សាអាស៊ីអាគ្នេយ៍ មានការលូតលាស់ ហើយដែលជាអ្នកសកម្មជាងគេនៅក្នុងវិស័យនេះ បានពិព័ណ៌នាអំពីស្ថានភាពនៅប្រទេសថៃ ដោយថ្លែងនូវភាសិតសៀមមួយថា «ក្លៃក្លឺគិនដាង ใกล้เกลือกินดาง [ជិតអំបិលស៊ីកំបោរ]» ដែលមានន័យស្រដៀងគ្នានឹងភាសិតខ្មែរថា «ដេកលើក្អៅទៅបៅដោះអ្នកដទៃ»[(២)] ។ ចំណែកកម្មវិធីថ្នាក់ឧត្តមសិក្សា ដូចជាមាននៅសាកលវិទ្យាល័យចុឡាលង្ករណ៍ នៅបាងកក ដែលមានគម្រោងសិក្សាអំពីអាស៊ីអាគ្នេយ៍ ជាផ្នែកមួយរបស់វិទ្យាស្ថានសិក្សាអំពីអាស៊ី ។ វិទ្យាស្ថាននេះ មានគោលដៅតែមួយគត់ គឺការស្រាវជ្រាវ ហើយជាស្ថាប័នដែល

---

* កំណត់បណ្ណាធិការ ៖ យើងខ្ញុំបានបោះពុម្ពផ្សាយអត្ថបទនេះជាលើកដំបូង ក្នុង **សិក្សាចក្រ** លេខ ៦ (គ.ស. ២០០៤) ។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះលោក ទង់ជ័យ វិនិច្ចកូល និងវិទ្យាស្ថានឧត្តរនៃការសិក្សាអាស៊ី ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបកប្រែអត្ថបទដើមពីភាសាអង់គ្លេសជាភាសាខ្មែរ ។

**(១)** កំណត់អ្នកបកប្រែ ៖ នៅក្នុងអត្ថបទនេះ ពាក្យថា « សៀម » គឺសំដៅទៅលើភាសាផ្លូវការរបស់ប្រទេសថៃ និងជនជាតិភាគច្រើនដែលរស់នៅក្នុងភូមិភាគកណ្តាលនៃប្រទេសថៃ ។ ពាក្យថា « ថៃ » គឺសំដៅទៅលើប្រជាជននៅប្រទេសថៃ ដែលមានសញ្ជាតិថៃ តាំងពីទសវត្សរ៍ឆ្នាំ ១៩៣០ ទោះសៀមក្តី ឬជាតិសាសន៍ដទៃទៀតក្តី ពោលគឺសំដៅទៅលើអ្វី ៗ ដែលជារបស់ថៃតាំងពីពេលនោះមក ហើយក៏សំដៅទៅលើជនជាតិទាំងឡាយក្នុងអំបូរភាសាថៃនិងតៃ ដែលរស់នៅប្រទេសថៃ ប្រទេសលាវ ប្រទេសភូមា ។ល។ « ប្រទេសសៀម » ឬ « ប្រទេសស្យាម » ឬ « ស្យាមប្រទេស » ឬ « ស្យាមរដ្ឋ » សំដៅទៅលើប្រទេសដែលនៅខាងលិចប្រទេសកម្ពុជា រហូតដល់គ្រិស្តសតវត្សរ៍ទី ២០ (ទសវត្សរ៍ឆ្នាំ ១៩៣០) ។ « ប្រទេសថៃ » សំដៅទៅលើប្រទេសសៀមតាំងពីទសវត្សរ៍ឆ្នាំ ១៩៣០ ពេលដែលប្រទេសនេះបានដូរឈ្មោះជាផ្លូវការ ។ ពាក្យថា « សៀម » ពុំមានន័យទ្រគោះមើលងាយឡើយ គឺគ្រាន់តែជាឈ្មោះភាសានិងជាតិសាសន៍ប៉ុណ្ណោះ ។ « បារាំង » គឺសំដៅទៅលើជនជាតិបស្ចិមប្រទេសទាំងឡាយ ពុំមែនតែជនជាតិបារាំងសែសប៉ុណ្ណោះទេ ។

**(២)** *บรรณานุกรมเอเชียอาคเนย์ศึกษาในประเทศไทย* **បណ្ណានុក្រមអេឈៀអាខៈណេស៊ឹក្សាណៃប្រះថេតថៃ** [**បណ្ណានុក្រម (គន្ថនិទ្ទេស) ការសិក្សាអាស៊ីអាគ្នេយ៍ក្នុងប្រទេសថៃ**] រៀបរៀងដោយ ជាញវិទ្យ ក្សេត្រសិរិ (ชาญวิทย์ เกษตรศิริ) និងអ្នកដទៃ ការបោះពុម្ពលើកទី ២ បាងកក មូលនិធិទំនុកបម្រុងការស្រាវជ្រាវនៃប្រទេសថៃ គ.ស. ១៩៩៥ ទំព័រទី ៥ ។ មានអត្ថបទសាកល្បង ១ ទៀតដែលប្រហាក់ប្រហែល ក្នុង *เอเชียตะวันออกเฉียงใต้ศึกษา : สายไปแล้วหรือยัง ?* **អេឈៀតះវ៉ាន់អកឆៀងតាយស៊ឹក្សា ៖ សាយប៉ៃឡែវរឺយ៉ាំង ?** [**ការសិក្សាអំពីអាស៊ីខាងកើតឆៀងខាងត្បូង ៖ យឺតពេលហើយឬនៅ ?**] អម្ពរ ចិរដ្ឋតិករ (อำพร จิรัฐติกร អាំផន ជិរ៉ាត់ទិកន) ជាបណ្ណាធិការ (អ្នកចងក្រង) ឈុតបោះពុម្ពលេខ ១ បាងកក គ្រោងការសិក្សាអាណាបរិវេណ ៥ ភូមិភាគ គ.ស. ២០០០ សេចក្តីផ្តើម (គ្មានលេខទំព័រ) ។

មានអាយុកាលចាស់ណាស់ទៅហើយ និងទទួលប្រាក់ឧបត្ថម្ភច្រើន ថែមទាំងសកម្មទៀតផង ។ នៅក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ គឺចាប់តាំងពីវិទ្យាស្ថាននេះមានកំណើតឡើង ចំណាប់អារម្មណ៍ជាចម្បងរបស់វិទ្យាស្ថាននេះ ទាក់ទងទៅនឹងអាស៊ីបូព៌ា ។ ក៏ប៉ុន្តែ នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទិសដៅនេះ មាននិន្នាការបែរទៅរកអាស៊ីអាគ្នេយ៍ថែមទៀត ។ ចំណុចនេះជាកត្តាមួយដែលគួរឲ្យកត់សម្គាល់ ។ សាកលវិទ្យាល័យធម្មសាស្ត្រ នៅបាងកក ក៏មានវិទ្យាស្ថានសិក្សាអំពីអាស៊ីបូព៌ា ១ ដែរ ដែលបានទទួលប្រាក់ឧបត្ថម្ភជាច្រើន តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ តែពុំមានវិទ្យាស្ថានសិក្សាអំពីអាស៊ីអាគ្នេយ៍ឡើយ ។ កម្មវិធីសិក្សានានាដែលផ្តល់សញ្ញាប័ត្រ ហើយដែលនៅក្នុងចំណងជើងមានពាក្យថា «អាស៊ីអាគ្នេយ៍» គឺមានតែកម្មវិធីសិក្សា ១ អំពីភាសាសាស្ត្រនៅសាកលវិទ្យាល័យមហិតល នៅនគរបឋម និងកម្មវិធីសិក្សា ២ ទៀត អំពីប្រវត្តិសាស្ត្រ នៅសាកលវិទ្យាល័យសិល្បាករ នៅបាងកក និងសាកលវិទ្យាល័យឈៀងម៉ៃ នៅទីក្រុងឈៀងម៉ៃ ។ កម្មវិធីទាំង ៣ ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យពិសេសៗ ។ តាមពិត ទាំងនេះគឺជាកម្មវិធីតូចៗ ដែលធ្វើការសិក្សាតិចតួចប៉ុណ្ណោះ (និក្ខេបបទ និងសិក្សាដទៃទៀត) ទៅលើបណ្តាប្រទេសអាស៊ីអាគ្នេយ៍ក្រៅពីប្រទេសថៃ ។ នៅក្នុងចំណោមការសិក្សាទាំងនេះ ប្រធានបទភាគច្រើន ទាក់ទងទៅនឹងប្រទេសថៃ ឬទាក់ទងទៅនឹងសម្ព័ន្ធភាពរវាងប្រទេសថៃនឹងប្រទេសជិតខាង ។ មានតែកម្មវិធីថ្មីៗ ផ្នែកអាស៊ីអាគ្នេយ៍ នៅសាកលវិទ្យាល័យចុឡាលង្ករណ៍ និងសាកលវិទ្យាល័យធម្មសាស្ត្រទេ ដែលសាកល្បងធ្វើតាម «ភូមិភាគសិក្សា» របៀបអាមេរិកាំង ដែលជាការសិក្សាអន្តរវិស័យ[៣] ។ ហើយមានតែកម្មវិធីនៅធម្មសាស្ត្រប៉ុណ្ណោះទេ (ដោយមានលោក ជាញវិទ្យ ផ្គាល់ ជាអ្នករៀបចំ) ដែលតម្រូវឲ្យនិស្សិតរៀនភាសាមួយក្នុងចំណោមភាសាអាស៊ីអាគ្នេយ៍ ក្រៅពីភាសាសៀម ។ នេះជាជំហានដ៏ធំមួយ ឆ្ពោះទៅរកការជួយជ្រោមជ្រែងលើការសិក្សាអំពីប្រទេសដទៃនៃអាស៊ីអាគ្នេយ៍ ។

ក្នុងពេលថ្មីៗនេះ «សំណាក់ការកងទុនទំនុកបម្រុងការវិច័យ» គឺ មូលនិធិទំនុកបម្រុងការស្រាវជ្រាវនៃប្រទេសថៃ (ម.ស.ថ.) ដែលជាស្ថាប័នពាក់កណ្តាលឯកជន ពាក់កណ្តាលសាធារណៈ ដើម្បីជួយជ្រោមជ្រែងការស្រាវជ្រាវនៅប្រទេសថៃ បានចាប់ផ្តើមធ្វើគម្រោងការមួយ ដែលមានទឹកប្រាក់មួយរយលានបាទ (១០០.០០០.០០០ បាទ) ។ គម្រោងនេះ មានឈ្មោះថា «ខ្រូងកានអាណាបរិវ៉េនស៊ឹក្សាហាភូមិផាក โครงการอาณาบริเวณศึกษา ๕ ภูมิภาค [គ្រោងការអាណាបរិវេណសិក្សា ៥ ភូមិភាគ]» ដើម្បីឲ្យមានសកម្មភាពឡើង និងរៀបចំមូលដ្ឋានសម្រាប់ «ភូមិភាគសិក្សា» នៅប្រទេសថៃ ។ យោងទៅតាមការប្រកាសផ្សាយគម្រោងការនេះ ប្រជាជាតិថៃចាំបាច់ត្រូវមានចំណេះដឹងអំពីពិភពលោកជាបន្ទាន់ ។ គម្រោងការនេះមានគោលបំណង ចង់អភិវឌ្ឍជំហរឯករាជនៃប្រទេសថៃ នៅក្នុងពិភពលោកយើង ដែលកំពុងឈានចូលទៅក្នុងសាកលភាវូបនីយកម្ម ហើយដែលកាន់តែស្មុគស្មាញចាប់តាំងពីសង្គ្រាមត្រជាក់បានចប់ទៅ ។ នៅក្នុងលោកថ្មីនេះ ប្រជាធិបតេយ្យូបនីយកម្ម និងសេរីនិយមថ្មីខាងសេដ្ឋកិច្ច (គឺ សេដ្ឋកិច្ចដឹកនាំលោក) សុទ្ធជាបាតុភូតដែលកំពុងគ្របដណ្តប់ពិភពលោកទាំងមូល ។ នៅក្នុងចំណោមភូមិភាគទាំង ៥ គឺ អាស៊ីអាគ្នេយ៍ ១ មជ្ឈិមបូព៌ាប្រទេស ១ អាហ្វ្រិក ១ អាមេរិកឡាទីន ១ និងអាស៊ីទក្សិណ ១ ភូមិភាគអាស៊ីអាគ្នេយ៍ជាអាទិភាពចម្បងសម្រាប់ប្រទេសថៃ ។ ក៏ប៉ុន្តែ នៅប្រទេសថៃ ចំណេះដឹងនិងគ្រឹះ ដែលមានស្រាប់ ដើម្បីអាចឲ្យឈានទៅចាប់យកនូវចំណេះដឹងផ្សេងទៀត អំពីដែនដីដទៃទៀតនៅក្នុង

---

**(៣)** កំណត់អ្នកបកប្រែ៖ ភាសាសៀមហៅថា «อาณาบริเวณศึกษา **អាណាបរិវេណសិក្សា**» ភាសាអង់គ្លេសហៅថា "Area Studies" ។

*លោក ក៏នៅមានការខ្វះខាតដែរ ទោះជាទំនាក់ទំនងរវាងរដ្ឋក្តី ទំនាក់ទំនងរវាងប្រជាជនក្តី ការប្តូរផ្លោះផ្នែកវប្បធម៌និងបញ្ញាក្តី សហប្រតិបត្តិការក្តី ។ ដូច្នេះ គ្រោងការនេះ សំដៅទៅលើការអភិវឌ្ឍអ្នកប្រាជ្ញនិងធនធានក្នុងស្រុក (គឺមានន័យថា ចង់បណ្តុះបណ្តាលអ្នកឯកទេសនៅប្រទេសថៃ ល្អជាងបញ្ជូនទៅរៀននៅអាមេរិក) ។ គ្រោងការនេះ ក៏សំដៅទៅលើការពង្រីកចំណេះដឹងរបស់មហាជនអំពីដែនដីឯទៀតនៅក្នុងពិភពលោកយើងដែរ*[៤] ។

## តើប្រទេសថៃខ្វះចំណេះដឹងអំពីអាស៊ីអាគ្នេយ៍ មែនឬទេ?

*ក្នុងឆ្នាំ ១៩៨៨ ដើម្បីជាចំណែកមួយ ក្នុងការរៀបចំ «គ្រោងការអាណាបរិវេណសិក្សា ៥ ភូមិភាគ» នេះ មូលនិធិទំនុកបម្រុងការស្រាវជ្រាវនៃប្រទេសថៃ (ម.ស.ថ.) បានឧបត្ថម្ភការសិក្សាស្រាវជ្រាវផ្នែកបណ្ណានុក្រម (គន្ថនិទ្ទេស) អំពីអត្ថបទនិពន្ធទាំងអស់ ដែលសរសេរជាភាសាសៀម ស្តីពីភូមិភាគអាស៊ីអាគ្នេយ៍ និងស្តីពីប្រទេសនីមួយៗ ក្នុងភូមិភាគនេះ ។ បណ្ណានុក្រមដែលគេបានធ្វើ ហើយដែលមានលោក ជាញវិទ្យ ជាអ្នកពិនិត្យផ្ទៀងផ្ទាត់ មានបញ្ជីដែលមានឯកលេខនា*[៥] *បោះពុម្ពផ្សាយ ៤០០ ក្បាល និក្ខេបបទថ្នាក់អនុបណ្ឌិត ឬ ថ្នាក់បណ្ឌិត ១៥០ ក្បាល ហើយនិងអត្ថបទសិក្សា ឬ អត្ថបទសារព័ត៌មានប្រហែល ១៧០០ អត្ថបទ*[៦] *។ ចំនួនទាំងនេះ ពិតជាអស្ចារ្យមែន ចុះហេតុអ្វីបានជាគេនិយាយថា ប្រទេសថៃខ្វះចំណេះដឹងអំពីអាស៊ីអាគ្នេយ៍?*

*លោក ជាញវិទ្យ បានពន្យល់មូលហេតុនៃគុណវិបត្តិរបស់ការនិពន្ធជាភាសាសៀមអំពីប្រទេសជិតខាង ។ មុនដំបូង ការនិពន្ធទាំងនេះ មានលក្ខណៈលម្អៀងជា «ថៃនិយម» ពេក ពោលគឺ សឹងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើប្រធានបទ ដែលទាក់ទងនឹងប្រទេសថៃ, គិតដល់ផលប្រយោជន៍ថៃ និងយោគយល់ទស្សនៈថៃ ។ គេកម្រឃើញណាស់នូវការសិក្សាមធ្យ័តអំពីប្រទេសជិតខាង ដែលមិនគិតដល់ទំនាក់ទំនងជាមួយនឹងប្រទេសថៃ ។ ម្យ៉ាងទៀត ទស្សនៈថៃនិយមនេះ ផ្អែកលើទស្សនៈបច្ចុប្បន្នរបស់ប្រទេសជាតិទំនើប ដោយខ្វះនូវចំណេះដឹងយ៉ាងជ្រៅជ្រះខាងប្រវត្តិសាស្ត្រ ។ ទោះជានៅពេលដដែកពីរឿងប្រវត្តិសាស្ត្រក៏ដោយ គេក៏អាចសម្គាល់យ៉ាងជាក់ច្បាស់ថា នៅមានការខ្វះខាតខាងការសិក្សា អំពីសម័យដែលប្រទេសជិតខាង ជាប្រទេសអាណានិគម ហើយថៃក៏មានចិត្តព្រងើយកន្តើយ ចំពោះនគរតូចតាចមុនពេលកើតឡើងនៃប្រទេសជាតិទាំងឡាយក្នុងបច្ចុប្បន្ន ។ សរុបទៅ ការនិពន្ធថៃនៅក្នុងបណ្ណានុក្រមនេះ សុទ្ធសឹងជាការសិក្សាដែលស្តីអំពីទំនាក់ទំនងថ្នាក់អន្តរជាតិរបស់ប្រទេសថៃ ។ ម្យ៉ាងទៀត នៅប្រទេសថៃ គេចាប់អារម្មណ៍ទៅលើតែវង្វង់ប្រធានបទដ៏ចង្អៀតមួយគត់ គឺ សន្តិសុខ ការទូត ហើយនិងទំនាក់ទំនងសេដ្ឋកិច្ចនិងធុរកិច្ច ។ ក្នុងសម័យសង្គ្រាមត្រជាក់ គេបានសរសេរអំពីឥណ្ឌូចិនយ៉ាងច្រើនលើសលប់ ។ លោក ជាញវិទ្យ បាននិយាយដោយពាក្យចំអកថា អ្នកនិពន្ធទាំងនេះ សរសេរដូចជា*

---

**(៤)** *โครงการอาณาบริเวณศึกษา ๕ ภูมิภาค* [**គ្រោងការអាណាបរិវេណសិក្សា ៥ ភូមិភាគ**] កូនសៀវភៅនេះ ផ្សព្វផ្សាយជាភាសាសៀមនិងអង់គ្លេស តាមការប្រកាសរបស់មូលនិធិទំនុកបម្រុងការស្រាវជ្រាវនៃប្រទេសថៃ នៅ គ.ស. ២០០០ ។

**(៥)** ឯកលេខនា គឺជាការសិក្សាអំពីប្រការ ឬ ចំណុចមួយយ៉ាងល្អិតល្អន់ ។

**(៦)** ការដឹងនូវភាពខុសប្លែកគ្នារវាងអត្ថបទសារព័ត៌មាននិងអត្ថបទសិក្សា មិនងាយប៉ុន្មានទេ ។ នៅក្នុងបណ្ណានុក្រម គេមិនបានធ្វើការបែងចែក ហើយនៅក្នុងចំនួន ១៧០០ អត្ថបទ មានអត្ថបទទាំង ២ ប្រភេទ ។

*ទុកខ្លួនថា ជាមេដឹកនាំប្រទេស ដែលទទួលខុសត្រូវខាងសន្តិសុខនិងកិច្ចការខាងផ្លូវទូត*[៧] *។ លោក ដាញវិទ្យ បានឲ្យយោបល់ថា ស្នាដៃនិពន្ធទាំងនេះ មិនមានលក្ខណៈគ្រប់គ្រាន់ សម្រាប់សិក្សាអំពីអាស៊ីអាគ្នេយ៍ឡើយ ។*

*ក៏ប៉ុន្តែ យើងអាចចោទសួរថា ៖ តើស្នាដៃនិពន្ធទាំងនេះ ពុំអាចមានលក្ខណៈល្មមគ្រប់គ្រាន់ ដើម្បីទុកជាចំណែកមួយនៃចំណេះដឹងអំពីអាស៊ីអាគ្នេយ៍នៅប្រទេសថៃ បានទេឬ? តើស្នាដៃនិពន្ធទាំងនេះ មិនអាចជួយកសាងការសិក្សាអំពីអាស៊ីអាគ្នេយ៍ ឲ្យក្លាយជាមូលដ្ឋាននៃចំណេះវិជ្ជា នៅក្នុងប្រទេសថៃទេឬ? ឬមួយ មានន័យថា ស្នាដៃនិពន្ធទាំងនេះ មិនសមនឹងគំរូរបស់លោក ដាញវិទ្យ និងរបស់យើង ដែលមានយោបល់រួចស្រាប់ហើយទៅលើការសិក្សា ដែលស្តីអំពីអាស៊ីអាគ្នេយ៍នោះ? ប្រហែលជាភាគច្រើននៃស្នាដៃនិពន្ធទាំងនេះ មិនមានសុក្រឹតភាព ចំពោះកម្រិតប្រក្រតីរបស់យើង ដែលជាអ្នកស្រាវជ្រាវបែបវិទ្យាសាស្ត្រក្នុង «ភូមិភាគសិក្សា» ទេ ។ ការនិពន្ធទាំងនេះធ្វើតាមប្រពៃណីទំនៀមទម្លាប់នៃផលិតកម្មចំណេះ ដូចជារបាយការណ៍ការិយាធិបតេយ្យ គឺតាមរបៀបចាត់ការរដ្ឋ ។ល។ សូម្បីតែយោបល់របស់លោក ដាញវិទ្យ ត្រឹមត្រូវក៏ដោយ ក៏យោបល់នេះនៅតែមិនដាច់ស្រេច ដោយសារក្នុងវិស័យសិក្សា លោក ដាញវិទ្យ និងយើង ស្គាល់ច្បាស់ និងមានបទពិសោធន៍ អំពីភូមិភាគសិក្សាតាមបែបអាមេរិកាំង ។ ចំណេះដឹងអំពីអាស៊ីអាគ្នេយ៍ទាំងឡាយ ដែលមាននៅប្រទេសថៃ ហាក់ដូចជាតិចផង ទ្រុឌទ្រោមផង ដោយហេតុថា យើងបានយកលក្ខណវិនិច្ឆ័យពីបរទេស ធ្វើការវាយតម្លៃទៅលើបទនិពន្ធទាំងនេះ ។*

*វិស័យចំណេះដឹងមួយណា ពឹងផ្អែកទៅលើប្រព័ន្ធសេដ្ឋកិច្ចនិងនយោបាយដោយឡែកក្នុងវិស័យសិក្សា គឺទៅតាមលក្ខណៈសង្គមនៃផលិតកម្ម លក្ខណៈសង្គមនៃការផ្គត់ផ្គង់និងតម្រូវការ ការចែកផ្សាយនិងពាណិជ្ជកម្ម ។ ឧទាហរណ៍ ចំណេះដឹងអំពីអាស៊ីនាសម័យអាណានិគមនិយម មានឥទ្ធិពលមកពីការសិក្សាអំពីបូព៌ាប្រទេស ដែលធ្លាប់មាននៅលោកខាងលិច ដែលផ្តល់សារៈសំខាន់ទៅលើវិស័យអក្សរសាស្ត្រ ដូចជា និរុត្តិវិទ្យា ភាសា និងបុរាណវិទ្យា ជាដើម ។ រីឯវិស័យភូមិភាគសិក្សារបៀបអាមេរិកាំង ដែលបានកើតឡើងនៅសម័យសង្គ្រាមត្រជាក់ ចាប់អារម្មណ៍ជាពិសេសទៅលើវិទ្យាសាស្ត្រសង្គម ។ ម្ល៉ោះហើយ របៀបរៀបរៀងរបស់អ្នកប្រាជ្ញនិងវិជ្ជាផ្សេងៗ ក៏ខុសគ្នាទៅតាមលក្ខណៈនេះដែរ*[៨] *។ ចំណេះដឹងនៃប្រជាជាតិថៃ អំពីភូមិភាគអាស៊ីអាគ្នេយ៍ ក៏មានទំនៀមទម្លាប់ដោយឡែក ដែលប្លែកពីគំរូភូមិភាគសិក្សា ដែលគេស្គាល់នៅអាមេរិក ។*

*បើដូច្នេះ តើបែបបទ ឬ ទំនៀមទម្លាប់នៃចំណេះដឹងអំពីអាស៊ីអាគ្នេយ៍នៅប្រទេសថៃ មានលក្ខណៈយ៉ាងដូចម្តេច ? តើឯកសារដែលបានពីការសិក្សាអំពីបណ្ណានុក្រម បង្ហាញនូវអ្វីៗ លើការសិក្សារបៀបថៃអំពីអាស៊ីអាគ្នេយ៍ឬទេ ? អត្ថបទរបស់ខ្ញុំបាទនេះ អះអាង ថា ថ្វីដ្បិតតែបញ្ញត្តិអំពីភូមិភាគអាស៊ីអាគ្នេយ៍ ជាគំនិតថ្មីដែលពុំមានឫសគល់ក្នុងការគិតរបស់ថៃក៏ដោយ ក៏ចំណេះដឹងអំពីប្រទេសនីមួយៗ នៅក្នុងភូមិភាគនេះ សម្បូរណាស់ដែរ ។ ការណ៍នេះ ធ្វើឲ្យគេនឹកឃើញនូវការយោគយល់មួយធំជាងគេអំពីប្រទេសជិតខាង ដែលមាននៅក្នុងវិជ្ជាថៃបច្ចុប្បន្ន ដូចដែលការសិក្សាអំពីបណ្ណានុក្រមបានបង្ហាញ ។ ការយោគយល់នេះ ផ្អែកទៅលើបែបបទនិងទម្លាប់*

---

**(៧)** អម្ពរ [**ការសិក្សាអំពីអាស៊ីខាងកើតឆៀងខាងត្បូង ៖ ឃើញពេលហើយឬនៅ ?**] គ.ស. ២០០០ សេចក្តីផ្តើម (គ្មានលេខទំព័រ) ។

**(៨)** សូមមើល បេន អាន់ដឺរសុន (Ben Anderson) "The Changing Ecology of Southeast Asian Studies in the United States, 1950-1990" « [បរិដ្ឋានវិជ្ជាដ៏ប្រែប្រួលនៃការសិក្សាអំពីអាស៊ីអាគ្នេយ៍នៅសហរដ្ឋអាមេរិក ឆ្នាំ ១៩៥០–១៩៩០] » (ជាភាសាអង់គ្លេស) ក្នុង *Southeast Asian Studies in the Balance: reflections from America* [**ការសិក្សាអំពីអាស៊ីអាគ្នេយ៍ក្នុងការប្រថុយ ៖ ការពិចារណាមកពីអាមេរិក**] ឆាល្ស ហ៊ីរស្មាន (Charles Hirschman), ឆាល្ស អិហ្វ. ខៃស៍ (Charles F. Keyes) និង ខាល ហឺត្តឺរ័រ (Karl Hutterer) ជាបណ្ណាធិការ ក្រុងអានអារប័រ សមាគមការសិក្សាអំពីអាស៊ី គ.ស. ១៩៩២ ទ. ២៥–៤០ ។

*នៃចំណេះដឹង ១ យ៉ាង ដែលធ្លាប់មានជាយូរអង្វែងមកហើយនៅប្រទេសសៀម នោះគឺការយោគយល់បែបចក្រពត្តិនិយមរបស់ស្យាមរដ្ឋ ពោលគឺចំណេះដឹងខាងប្រវត្តិសាស្ត្រ ជាពិសេសចំណេះដឹង ដែលបានតំណាងនិងផ្សាយមនោគមវិជ្ជាបែបចក្រពត្តិនិយមនេះ ។ តាមទស្សនៈនេះ ថៃកម្រចាត់ទុកប្រទេសជិតខាងរបស់គេថា ជាមិត្តណាស់ តែផ្ទុយទៅវិញ គេច្រើនទុកថាជាសត្រូវ ឬ ស្រុកចំណុះរបស់សៀម ។ ក៏ប៉ុន្តែ ទន្ទឹមនឹងទស្សនៈចក្រពត្តិនិយមនេះ មានបែបបទ ឬ ទម្លាប់ផ្សេងៗ ទៀត ដែលគេពុំសូវទទួលស្គាល់ប៉ុន្មានទេ ដូចជាចំណេះដឹងនៅថ្នាក់តំបន់ ដែលមានទីតាំងនៅផ្ទៃក្រៅ (បរិមណ្ឌល) នៃស្យាមរដ្ឋ ។ ទាំងចំណេះដឹងបែបចក្រពត្តិនិយម ទាំងចំណេះដឹងរបស់អ្នកស្រុក ឬក្នុងបរិមណ្ឌល សុទ្ធតែខុសពីចំណេះដឹង ដែលកើតមកពីរបៀបភូមិភាគសិក្សា ក៏ប៉ុន្តែ កម្មវិធីសិក្សាអំពីអាស៊ីអាគ្នេយ៍ទាំងឡាយ ដែលនឹងធ្វើទៅក្នុងអនាគត នឹងពុំអាចជៀសផុតពីចំណេះដឹងបែបចក្រពត្តិនិយមនិងបរិមណ្ឌលបានឡើយ ។*

## ពួកសត្រូវ និង ពួកកន្ទៀតជាបតូច (ពួកបរិវារ)

*ពាក្យថា «អាស៊ី» និង «អាស៊ីអាគ្នេយ៍» នេះ ជាបញ្ញត្តិបរទេស ដែលមិនសូវចាស់ប៉ុន្មានទេ[៩] ។ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ គេពុំធ្លាប់ចាត់ទុកវប្បធម៌ក្នុងស្រុកទាំងឡាយ ជាចំណែករបស់អាស៊ី និងអាស៊ីអាគ្នេយ៍ឡើយ ។ អត្តសញ្ញាណកម្មផ្នែកភូមិភាគ ដែលយើងស្គាល់ច្រើនជាងគេនៅអាស៊ីអាគ្នេយ៍ដីគោក គឺ «សុវណ្ណភូមិ» (ដីមាស) ហើយនាមនេះ គឺអ្នកក្រៅ ដែលមកពីអាស៊ីទក្សិណ និងអាស៊ីបស្ចិម ដែលនិយមប្រើ ។ នាម សុវណ្ណភូមិ នេះ មិនសម្គាល់ទៅលើ «ភូមិភាគ» មួយ ជាក់ច្បាស់ប៉ុន្មាននោះទេ តែសំដៅទៅលើកន្លែងមួយទៀតនៅក្នុងភូមិភាគ ដែលសម្បូរសប្បាយ (ហើយប្រហែលជាយើងត្រូវយល់ថា សម្បូរក្នុងវិស័យសាសនា ពុំមែនសម្បូរខាងសេដ្ឋកិច្ចទេដឹង?) ។ ការបកស្រាយថា «សុវណ្ណភូមិ» ជា «ជ្រោយ» បានកើតឡើងនៅសម័យក្រោយៗ ក្នុងទស្សនៈ «ភូមិភាគ»[១០] ។*

*ម្យ៉ាងទៀត នៅក្នុងអតីតកាល ធ្លាប់មានអាណាចក្រច្រើន ដែលមានស្តេចគ្រប់គ្រងនោះ ជា «ព្រះរាជាណាចក្រ», «ចក្រភព» ឬ «រាជមណ្ឌល»[១១] នៅក្នុងតំបន់ដែលជាអាស៊ីអាគ្នេយ៍ដីគោកសព្វថ្ងៃ ។ ក្រៅពីករណីមួយចំនួនតូច ស្តេចទាំងអស់នោះ ប្រកួតគ្នា ច្បាំងគ្នា ហើយបង្ក្រាបគ្នា ទៅវិញទៅមក ដើម្បីដណ្តើម*

---

**(៩)** កំណត់អ្នកបកប្រែ ៖ ដែលខ្មែរហៅថា «អាស៊ីអាគ្នេយ៍» ភាសាសៀមហៅបាន ៣ យ៉ាង ។ រាជបណ្ឌិតស្ថានថៃបានបង្កើតបញ្ញត្តិជាពាក្យក្នុងភាសាសៀមថា «เอเชียตะวันออกเฉียงใต้ អេឈៀតៈវ៉ាន់អកឆៀងតាយ» គឺ «អាស៊ីខាងកើតឆៀងខាងត្បូង» តែក្នុងកាសែតនិងក្នុងរង្វង់សិល្បៈនិងវប្បធម៌ គេបែរជាហៅថា «อุษาคเนย์ ឧមាគ្នេយ៍» ដែលជាសមាសនាមធ្វើដោយពាក្យថា «ឧសា» (សំស្ក្រឹត «ឧមា» (ម គឺព្យញ្ជនៈសំស្ក្រឹតមួយ ដែលខ្មែរជំនាន់មុនៗ ហៅថា «ស–ប») មានន័យថា «ពន្លឺបំព្រាងជិតព្រឹក») និងពាក្យថា «អាគ្នេយ៍» ហើយមានអ្នកខ្លះហៅ «เอเชียอาคเนย์ អេឈៀអាគ្នេយ៍» វិញ គឺ «អាស៊ីអាគ្នេយ៍» ។

**(១០)** ឆាល្ស អិហ្វ. ខៃស៍ (Charles F. Keyes) *The Golden Peninsula: Culture and Adaptation in Mainland Southeast Asia* [**ជ្រោយមាស ៖ វប្បធម៌និងការសម្រុំនៅអាស៊ីអាគ្នេយ៍ដីគោក**] (ជាភាសាអង់គ្លេស) ក្រុងហូណូលូលូ គ្រឹះស្ថានបោះពុម្ពផ្សាយនៃសាកលវិទ្យាល័យហាវ៉ៃ គ.ស. ១៩៩៥ ។

**(១១)** អូ. ដាប់បឺលយូ. វ៉ុល្ទ័រ្ស (O.W. Wolters) *History, Culture, and Region in Southeast Asian Perspectives* [**ប្រវត្តិសាស្ត្រ វប្បធម៌ និងភូមិភាគ ក្នុងទស្សនវិស័យអាស៊ីអាគ្នេយ៍**] (ជាភាសាអង់គ្លេស) ការបោះពុម្ពកែប្រែ ក្រុងអ៊ីថាកា ការបោះពុម្ពរបស់កម្មវិធីអាស៊ីអាគ្នេយ៍ សាកលវិទ្យាល័យយ៉េនែល្ល គ.ស. ១៩៩៩ ទ. ២៧–៤០ និង ១២៦–១៥៤ ។ ហេរម៉ាន្ទ គុល្កិ៍ (Hermann Kulke) “The Early and Imperial Kingdoms in Southeast Asian History” « [អាណាចក្រដើមនិងចក្រពត្តិក្នុងប្រវត្តិសាស្ត្រ →

យកឧត្តមភាព ហើយមានសង្ឃឹមថា បានបរមានុភាពលើស្តេចតូចតាច ឬស្តេចសាមន្តរាជ ទៅតាមលំដាប់សក្តិរបស់ស្តេច ។ ស្តេចចក្រពត្តិ ដែលមិនអាចបង្រ្កាបគ្នា ក៏ក្លាយទៅជា «គូប្រជែងធំ» នឹងគ្នា ទោះជាព្រះអង្គទ្រង់មានឧត្តមភាពលើស្តេចចំណុះដូចគ្នាក្តី ឬ ទោះជាមានជំនឿសាសនាដូចគ្នាក្តី ដូចជាស្តេចសៀម និងស្តេចភូមា ដែលកាន់ព្រះពុទ្ធសាសនាថេរវាទដូចគ្នា ។ នេះ គឺជាស្តេច «អាត្មានិយម» ដែលមានគំនិត «អញជាធំ» គឺគិតថា ព្រះអង្គឯងជាកំពូលក្នុងលោក ជារាជាធិរាជ គឺជាព្រះរាជាដែលធំជាងស្តេចឯទៀត ។

សៀមគិតអំពីប្រទេសជិតខាង និងអំពីទំនាក់ទំនងជាមួយប្រទេសទាំងនេះ ដោយផ្អែកទៅលើទស្សនៈស្តេចអាត្មានិយមនេះ ។ ដោយហេតុថា ជាចមចក្រពត្តិ (ស្តេចចក្រពត្តិកំពូល) ជាច្រើនសតវត្សរ៍មកហើយនោះ អាណាចក្រសៀមទាំងឡាយ គឺចាប់ពីអាណាចក្រស្រីអយុធ្យា ដល់អាណាចក្រទេពបុរី (បាងកក) ស្ថិតនៅក្នុងស្ថានភាពដែលចាត់ទុកប្រទេសជិតខាង ជាគូប្រកួត និងគូប្រជែងខាងបរមានុភាព ឬមួយទុកថា ជាសាមន្តរាជ, ស្រុកចំណុះ ឬ អាណាចក្រតូចតាច ។ ក្រៅពីអាណាចក្រដែលស្ថិតនៅអាស៊ីអាគ្នេយ៍ដីគោក ហើយដែលសៀមមានទំនាក់ទំនងផ្ទាល់ អាណាចក្រភាគច្រើនឯទៀត ដែលនៅក្នុងប្រជុំកោះនៃអាស៊ីអាគ្នេយ៍ មិនសូវស្ថិតក្នុងរង្វង់នៃការចាប់អារម្មណ៍របស់សៀមប៉ុន្មានទេ ។

## ប្រទេសជិតខាងក្នុងប្រវត្តិសាស្ត្រថៃ

ទស្សនៈអាត្មានិយមរបស់ថៃ អំពីប្រទេសនីមួយៗ នៅអាស៊ីអាគ្នេយ៍ដីគោក បានសម្តែងចេញច្បាស់ណាស់ក្នុងសាវតារសៀម ។ នៅត្រង់នេះ ខ្ញុំបាទសូមយកប្រវត្តិសាស្ត្រសៀមមកជាតំណាងរបស់ចំណេះដឹងសៀមអំពីប្រទេសជិតខាង ។ ប្រវត្តិសាស្ត្របង្ហាញឲ្យដឹងនូវបទពិសោធន៍របស់ថៃក្នុងបច្ចុប្បន្ន ជាមួយប្រទេសជិតខាង ។ ទន្ទឹមនឹងនេះ ប្រវត្តិសាស្ត្រក៏មានឥទ្ធិពលទៅលើបទពិសោធន៍របស់ថៃក្នុងបច្ចុប្បន្ន និងក៏អាចផ្តល់នូវខ្លឹមសារដល់បទពិសោធន៍ទាំងនេះ ។ នៅត្រង់នេះ ពាក្យថា «ប្រវត្តិសាស្ត្រ» សំដៅជាពិសេសចំពោះការរាយរាប់ ដែលចាក់ឫសទៅក្នុងការយល់ឃើញអំពីប្រទេសជិតខាង តាមរយៈទស្សនៈរបស់ស្តេចចក្រពត្តិ រួចហើយចាប់ពីដើមសតវត្សរ៍ទី ២០ ក៏បានរៀបចំក្នុងសតិសម្បជញ្ញៈទំនើបខាងប្រវត្តិសាស្ត្រ ដោយមានការប្រយុទ្ធរវាងបារាំងសែសនិងសៀម ក្នុងឆ្នាំ ១៨៩៣ ដែលធ្វើឲ្យសៀមមានការឈឺចិត្តយ៉ាងខ្លាំង⁽¹²⁾ ។ ប្រវត្តិសាស្ត្រនេះ មានពណ៌នាអំពីប្រទេសក្សេមក្សាន្តមួយ គឺប្រទេសសៀមនេះឯង ដែលត្រូវពួកសត្រូវបរទេសមកបៀតបៀនជារឿយៗ តែទោះជាយ៉ាងណាក៏ដោយ ប្រទេសសៀមក៏បានរួចពីស្លាប់ ថែមទាំងបានការពារឯករាជភាព ហើយបានចម្រុងចម្រើនពេញទំហឹងទៀតផង ។ កិត្តិយសបានមានទៅដល់មេដឹកនាំសៀមធំៗ ជាពិសេសព្រះចៅសៀម ដែលគេហៅថា ស្តេចទសពិធរាជធម៌ ក្នុងតំណរាជវង្សចក្រី ដែលនៅតែសោយរាជ្យសព្វថ្ងៃនេះ ។ បទពិសោធន៍ធំៗ ជាមួយប្រទេសជិតខាង ដែលមានចែងក្នុងព្រះរាជពង្សាវតារ គេបានបកស្រាយនិងយល់ទៅតាមរបៀបរាយ

---

↵ អាស៊ីអាគ្នេយ៍] » (ជាភាសាអង់គ្លេស) ក្នុង *Southeast Asia in the 9th to the 14th Centuries* [**អាស៊ីអាគ្នេយ៍ពីសតវត្សរ៍ទី ៩ ដល់ ១៤**] (ជាភាសាអង់គ្លេស) ដាវិឌ ម៉ារ្រ (David Marr) និង អា.សេ. មិល្ន័រ (A.C. Milner) ជាបណ្ណាធិការ សិង្ហបុរី វិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍ គ.ស. ១៩៨៦ ទ. ១–២២ ។

**(១២)** ខ្ញុំបាទបានអភិប្រាយវែកញែកអំពីដំណើរការនេះ ក្នុង *Siam Mapped: a history of the geo-body of a nation* [**ការគូរផែនទីប្រទេសសៀម ៖ ប្រវត្តិមួយអំពីរូបតួមិសាស្ត្ររបស់ប្រទេសជាតិមួយ**] (ជាភាសាអង់គ្លេស) ហូណូលូលូ គ្រឹះស្ថានបោះពុម្ពផ្សាយនៃសាកលវិទ្យាល័យហាវ៉ៃ ជំពូកទី ៨ ។

រាប់នេះ ដែលកើតឡើងនៅ ស.វ. ទី ២០ នេះ ។ ម្យ៉ាងទៀត បទពិសោធន៍នេះ ក្លាយជា «និយមន័យគោល» របស់ទស្សនៈដែលថៃយល់ពីប្រទេសជិតខាង ពោលគឺគំនិតអត្តបដិរូប (ប្រៀបធៀប) ដែលបង្កើតន័យនិងការយល់ ដែលទាក់ទងនឹងប្រទេសជិតខាង កាលណាប្រទេសថៃមានទំនាក់ទំនងនឹងប្រទេសជិតខាងសព្វថ្ងៃនេះ ឬ ក្នុងពេលក្រោយ ។ យើងក៏អាចនិយាយបានដែរថា មានហេតុការណ៍ខ្លះៗ ក្នុងប្រវត្តិសាស្ត្រថៃ តាមការបកស្រាយក្នុងសម័យនេះ បង្ហាញឲ្យដឹងនូវរបៀបដែលថៃសាងសង់ការយល់ឃើញរបស់ខ្លួន អំពីប្រទេសជិតខាង ។

តាមនិយមន័យគោលនេះ ភូមាជាខ្មាំងសត្រូវដ៏មានឫទ្ធិផង ដ៏កាចសាហាវផង ដែលបានច្បាំងឈ្នះពានយកប្រទេសសៀមពីរដង ។ ថ្វីដ្បិតតែសៀមបានឯករាជ្យឡើងវិញទាំងពីរដងនោះក៏ដោយ ក៏បរាជ័យបានធ្វើឲ្យចិត្តគំនិតរបស់សៀមមានស្នាមរបួស ដែលមិនអាចលុបបានទេ ជាពិសេសបរាជ័យនៅឆ្នាំ ១៧៦៧ ធំជាងបរាជ័យនៅឆ្នាំ ១៥៦៩ ។ លោក សុនេត្រ បានបំភ្លឺថា ការវាយបំផ្លាញទីក្រុងស្រីអយុធ្យា នាឆ្នាំ ១៧៦៧ មុនដំបូងគេយល់ថា ជាការចុះអាប់ឱន និងការធ្លាក់ចុះរបស់នគរប្រកបដោយគុណធម៌មួយ ក្នុងដៃរបស់កងកម្លាំងកាចសាហាវ ដែលប្រកបដោយពុទ្ធានុភាព ហើយដែលគេបានប្រៀបដូចក្រុងមារក្នុងពុទ្ធសាសនា ។ ទស្សនៈខាងសាសនានេះ គេបានលើកយកមកផលិតជាបញ្ញត្តិម្តងវិញទៀត នៅក្នុងការសិក្សាប្រវត្តិសាស្ត្រទំនើប គឺរវាងចុង ស.វ. ទី ១៩ និងដើម ស.វ. ទី ២០ ដោយចាត់ទុកភូមាជាសត្រូវដ៏ឃោរឃៅរបស់ជាតិសៀម(១៣) ។ អំពីបរាជ័យលើកដំបូងនៅឆ្នាំ ១៥៦៩ សូម្បីតែអ្នកដែលតែងសាវតារអំពីសម័យក្រុងស្រីអយុធ្យា នាដើម ស.វ. ទី ១៩ ក៏បានយល់ថា ជាជ័យជំនះរបស់ស្តេចចក្រពត្តិភូមា ព្រះនាម បាយិណ្ណោង(១៤) លើស្តេចក្រុងស្រីអយុធ្យា ដែលគ្មានសីលធម៌ ហើយដែលលែងជាស្តេចទសពិធរាជធម៌(១៥) ។ តែការបកស្រាយទំនើប ប្រកបដោយជាតិនិយមនេះ បានយល់ទៅវិញថា ជាសង្គ្រាមមួយទៀត រវាងជាតិទាំង ២ ។ ការរៀបរាប់អំពីបរាជ័យទាំងពីរដោយសារពួកភូមានេះ ដែលគេទុកជារឿងស្នូលពូជ ក្នុងសង្គ្រាមប្រឆាំងនឹងខ្មាំងសត្រូវ ជាគ្រឹះនៃការរៀបរាប់ទំនើប ក្នុងប្រវត្តិសាស្ត្រថៃនៅដើម ស.វ. ទី ២០(១៦) ។

---

**(១៣)** សុនេត្រ ជុតិន្ទរានន្ទ "The Image of the Burmese Enemy in Thai Perceptions and Historical Writings" «[រូបប្រៀបរបស់សត្រូវភូមាក្នុងទស្សនវិស័យសៀម និងក្នុងអត្ថបទប្រវត្តិសាស្ត្រ]» (ជាភាសាអង់គ្លេស) ក្នុង *Journal of the Siam Society* *วารสารสยามสมาคม* **ວ៉ារៈសានសៈយ៉ាមសៈម៉ាខុំ** [ទស្សនាវដ្តីសៀមសមាគម] លេខ ៨០ ភាគទី ១ (គ.ស. ១៩៩២) ទ. ៨៩–១០៣ ។

**(១៤)** កំណត់អ្នកបកប្រែ ៖ ក្នុងភាសាភូមា សរសេរថា «ဘုရင့်နောင်» អានថា បាយិណ្ណោង មានន័យថា ស្តេចរៀម ជាព្រះបរមនាមរបស់ព្រះរាជាភូមាមួយអង្គ ដែលបានសោយរាជ្យពី គ.ស. ១៥៥១ ដល់ គ.ស. ១៥៨១ ហើយបានច្បាំងឈ្នះបណ្តាអាណាចក្រថៃធំទាំងឡាយ, អាណាចក្រឈៀងម៉ៃ និងប្រទេសសៀម ។ ស្តេចនេះ មានព្រះនាមថា «បុរេងនង» ក្នុងពង្សាវតារសៀម ។

**(១៥)** សូមមើល ទង់ជ័យ វិនិច្ចកូល "A Villain in Thai History Who Was Framed by the Plot of Historians" [មនុស្សអាក្រក់មួយនាក់ ដែលត្រូវដាក់ស៊ុំដោយសារការឃុបឃិតរបស់ប្រវត្តិវិទូទាំងឡាយ]» (ជាភាសាអង់គ្លេស) ក្នុង *ไทยคดีศึกษา* **ថៃខៈឌីស៊ឹក្សា** [ថៃគតសិក្សា] កាញ្ចនី លួងស្រី (กาญจนี ละอองศรี កាញ្ចនី ឡះអងស៊ី) និងអ្នកដទៃ ជាបណ្ណាធិការ (គ.ស. ១៩៩០) ទ. ១៧៣–១៩៦ ។

**(១៦)** សូមមើលការអត្ថាធិប្បាយក្នុងវិចារណកថារបស់សម្តេចចៅហ្វាក្រុមព្រះយ៉ា តម្រង់ រាជានុភាព អំពី *พระราชพงศาวดารพระราชหัตถเลขา* [ព្រះរាជពង្សាវតារច្បាប់ព្រះរាជហត្ថលេខា] (ជាភាសាសៀម) ដែលបាននិពន្ធក្នុងឆ្នាំ ១៩១៤ ហើយនិងសុន្ទរកថារបស់ព្រះអង្គ «แสดงบรรยายพงศาวดารสยาม [សម្តែងបរិយាយពង្សាវតារស្យាម]» ជាភាសាសៀម ដែលបានថ្លែងក្នុងឆ្នាំ ១៩២៦ នៅសាកលវិទ្យាល័យចុឡាលង្ករណ៍ ។

តាមទស្សនៈថៃ ការណ៍ដែលប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងកណ្ដាប់ដៃពួកអង់គ្លេស ជាភស្តុតាងបញ្ជាក់ថា ភូមា ចោលម្សៀត ជាពួកកេងប្រវ័ញ្ច ដែលធ្លាក់ក្នុងកណ្ដាប់ដៃពួកកេងប្រវ័ញ្ចមួយពួកទៀត ដែលខ្លាំងជាង ដោយសារ រឿងព្រេងកម្ម ។ ផ្ទុយទៅវិញ នេះជាការណ៍សឲ្យឃើញថា សៀមបានរួចពីកណ្ដាប់ដៃរបស់ពួកអាណានិគមនិយម ដោយសារព្រះចៅសៀមដ៏ឆ្លាតវាងវៃ ដែលយកព្រះទ័យទុកដាក់លើជាតិជាគោលធំបំផុត ។ គេបាននិទានអំពី ចិត្តខិលខូចរបស់ភូមា ជាបែបផ្សេងៗ ដែលចូលក្នុងការអត្ថាធិប្បាយជាតិនិយមច្រើនបែបយ៉ាង នៅក្នុងអំឡុង ស.វ. ទី ២០ ។ ជារឿយៗ សៀមបានយកភូមាជាតំណាងសត្រូវរបស់ខ្លួន សូម្បីតែនៅក្នុងពេលខ្លះ សត្រូវពិត ប្រាកដ គឺមកពីប្រទេសមួយទៀត ពុំមែនជាប្រទេសភូមាក៏ដោយ ។ ឧទាហរណ៍ រឿងល្ខោនជាតិនិយមភាគ ច្រើនក្នុងអំឡុងសង្គ្រាមលោកលើកទី ២ និងក្នុងអំឡុងសង្គ្រាមត្រជាក់ ជារឿងល្ខោននិយាយអំពីសៀមច្បាំងនឹង ភូមា ។ យោងទៅតាមនិយមន័យគោល ភូមាជាសត្រូវស្ទួពូជ ដែលមហាជនថៃត្រូវដឹង និងយល់ថា បញ្ហាផ្សេងៗ ដែលប្រទេសថៃមានជាមួយនឹងប្រទេសភូមា នៅក្នុងទសវត្សរ៍ទាំងប៉ុន្មាននៅចុង ស.វ. ទី ២០ កន្លងមកនេះ ជា រឿងដែលកើតឡើងជារឿយៗ គឺស្ថានភាពតានតឹងនិងប្រយុទ្ធជាមួយនឹងគូប្រកួតស្ទួជាតិ ។

ភស្តុតាងដែលបញ្ជាក់ឲ្យឃើញថា ភូមាខិលខូច នោះ មានច្រើនណាស់នៅក្នុងបច្ចុប្បន្នកាល ដូចជាឧប្បត្តិហេតុ ដែលកើតឡើងជាញឹកញាប់រវាងទាហានថៃនិងទាហានភូមាតាមព្រំដែន, ព្រឹត្តិការណ៍ចាប់ចំណាប់ខ្មាំងនៅប្រទេស ថៃ នាឆ្នាំ ១៩៩៩–២០០០ គឺថា ក្នុងព្រឹត្តការណ៍មួយ មកពីពួកឧទ្ទាមភូមាប្រឆាំងនឹងរដ្ឋាភិបាលភូមា ហើយក្នុង ព្រឹត្តិការណ៍មួយទៀត គឺមកពីសមាជិកនៃជនជាតិភាគតិចនៅភូមា (ដែលប្រឆាំងនឹងរបបរដ្ឋធានីយ៉ាងគុង) ។ ឧទាហរណ៍មួយទៀត ការយល់ឃើញរបស់មហាជនថៃ គឺថា របបភូមានៅយ៉ាងគុងនេះឯង ដែលនៅក្រោយ ផែនការខិលខូចនៃផលិតកម្មម៉េតំហ្វេតាមីន និងការយកទៅចែកចាយនៅប្រទេសថៃ ដើម្បីធ្វើឲ្យអន្តរាយដល់ ប្រទេសថៃ ។ នៅមានឧទាហរណ៍មួយទៀតដែរ គឺការជជែកតវ៉ា ដែលកើតឡើងនៅឆ្នាំ ២០០១ អំពីមេរៀន ក្នុងសៀវភៅសិក្សានៅប្រទេសភូមា ដែលមាក់ងាយជាតិសៀម ហើយនិងរិះគន់ព្រះចៅសៀមទាំងឡាយ ។ ដោយមូលហេតុទាំងអស់នេះ យូរៗ ម្ដង មានបន្ទុះជាតិនិយមថៃប្រឆាំងនឹងភូមា និងជាមូលហេតុដែលមហាជន ថៃមិនចូលចិត្តពួកឧទ្ទាមភូមានិងជនអន្តោប្រវេសន៍ភូមា ។

ក្នុងគំនិតរបស់ខ្លួន សៀមទុកលាវដូចជាប្អូនអន់បំផុត ជាប្រទេសនៅក្នុងចិត្តបុណ្យនិងការឧបត្ថម្ភរបស់សៀម តែមិនចេះដឹងគុណសៀមដែលមានចិត្តល្អ ។ តាមកាលសម័យប្រវត្តិសាស្ត្រទាំងអស់ និងតាមទស្សនៈរបស់សៀម អាណាចក្រលាវទាំងឡាយ ជាស្រុកចំណុះ ដែលធ្លាប់មានទំនាក់ទំនងល្អៗ ជាមួយស្យាមរដ្ឋ ។ តែនៅ គ.ស. ១៨២៦ ដល់ ១៨២៩ មានឧប្បត្តិហេតុចម្លែកមួយ ដែលបានកើតឡើង ហើយដែលជិតជាប់ក្នុងផ្នត់គំនិតនិងអារម្មណ៍របស់ សៀម អំពីការយល់ឃើញលើលាវ ។ ឧប្បត្តិហេតុនេះ គឺកោលាហលដែល «ចៅអនុ» (គឺ ព្រះបាទ អនុវង្ស) របស់នគរវៀងច័ន្ទន៍ បានបង្កើតឡើង ។ តាមការសិក្សាអំពីពង្សាវតារសៀម ដោយផ្អែកលើព្រះរាជពង្សាវតារ ក្រុងទេពបុរី ព្រះបាទ អនុវង្ស របស់នគរលានជាង គង់នៅក្រុងវៀងច័ន្ទន៍ ទ្រង់ធ្លាប់មានភក្ដីភាពដ៏ល្អចំពោះ ព្រះចៅសៀមនៃរាជវង្សចក្រី នៅក្រុងធនបុរី និងក្រុងទេពបុរី(១៧) ។ ក៏ប៉ុន្តែ ថ្ងៃមួយ ព្រះបាទ អនុវង្ស កើត

---

**(១៧)** កំណត់អ្នកបកប្រែ ៖ គឺ បាងកក ។ កាលពីមុន ទីក្រុងនេះឈ្មោះក្រុងធនបុរីស្រីអយុធ្យា ហើយបានផ្លាស់ឈ្មោះនៅ គ.ស. ១៧៨២ ជា ក្រុងទេពបុរីស្រីអយុធ្យា វិញ ដែលសព្វថ្ងៃ ថៃហៅថា ក្រុងទេព ខ្មែរហៅថា ក្រុងបាងកក ។

រឿងជំទាស់ជាមួយនឹងព្រះចៅព្រះរាម ទី ៣ (ព្រះណាំងក្លាវ) ដ្បិតព្រះរាម ទី ៣ ទ្រង់មិនបានទទួលយកសំណូមពររបស់ព្រះបាទ អនុវង្ស ដែលសូមឲ្យជនជាតិលាវ ដែលសៀមបានកៀរឲ្យទៅតាំងទីលំនៅនៅប្រទេសរបស់ខ្លួនក្នុងពេលកើតសង្គ្រាមមុនៗ អាចត្រឡប់ទៅប្រទេសគេវិញ ។ ព្រះបាទ អនុវង្ស ទ្រង់អន់ព្រះទ័យពន់ពេកដល់កម្រិតទ្រង់ព្រះចិន្តារាតត្បាតភូមិភាគឦសាននៃប្រទេសសៀម ដែលជាភូមិភាគមួយមានប្រជាជនជាតិលាវដែរ ។ ចៅអនុក៏បានច្បាំងដណ្តើមយកនគរ (ទីក្រុង) ធំៗ នៅក្នុងភូមិភាគឦសាន មុននឹងសៀមវាយតប ។ ចៅអនុ ក៏ត្រូវថយចេញ ហើយនៅទីបញ្ចប់ ក៏កៀសព្រះអង្គទៅគង់នៅប្រទេសយួន ក្នុងពេលដែលទ័ពសៀមចូលដល់ក្រុងវៀងច័ន្ទន៍ និងបំផ្លាញក្រុងនេះ ។ សឹកសង្គ្រាម ក៏នៅតែមានតទៅទៀត ដល់ គ.ស. ១៨២៩ ជាឆ្នាំដែលព្រះបាទ អនុវង្ស ត្រូវបរាជ័យពេលព្រះអង្គសាកល្បងច្បាំងដណ្តើមក្រុងវៀងច័ន្ទន៍វិញ ហើយក៏ត្រូវសៀមចាប់ព្រះអង្គ ។ ព្រះអង្គត្រូវគេបញ្ជូនទៅក្រុងទេពបុរី ហើយត្រូវគេពិឃាតយ៉ាងឃោរឃៅនៅចំពោះមុខមហាជន[១៨] ។ ក្រោយមក រឿងនេះ ក៏ល្បីរន្ទឺនៅក្នុងប្រវត្តិសាស្ត្រថៃ ពីព្រោះមានវីរនារី ១ រូប ដែលមានឈ្មោះថា សុរនារី បានចេញមុខចេញមាត់នៅក្នុងចម្បាំងនេះ បន្ទាប់មកគេបានយកនាងធ្វើជាសំណាកដែលត្រូវគោរពបូជាទូទាំងប្រទេស ព្រោះនាងបានសង្គ្រោះប្រទេសជាតិ ហើយសព្វថ្ងៃនេះ នាងជាយាយទេពរក្សាទីក្រុងគោរាជ[១៩] (នគររាជសីមា)[២០] ។ ប៉ុន្តែ គ្មានអ្វីគួរឲ្យងឿងឆ្ងល់នោះទេ ក្នុងការខុសប្លែកគ្នាស្រឡះរវាងប្រវត្តិសឹកសង្គ្រាមខាងលើនេះ និងប្រវត្តិសាស្ត្រជាផ្លូវការរបស់លាវ ព្រមទាំងរឿងតំណាល (រឿងបរម្បរា) ក្នុងស្រុកដែលប្រជាជនតាមដងទន្លេមេគង្គ រ៉ាយរ៉ាប់តៗគ្នា ។ យោងទៅតាមប្រភពទាំងនេះ ពួកនាម៉ឺនសៀមតែងធ្វើបាបបណ្តារាស្ត្រលាវដែលរស់នៅក្នុងភូមិភាគនោះ ។ គេបានបង្ខំរាស្ត្រលាវឲ្យសាក់ខ្លួនជាសញ្ញាថា ជាទាសាទាសីដែលគេកែនទៅដើម្បីធ្វើការធ្ងន់ៗ ។ ចៅអនុ ក៏ទ្រង់ប្តឹងដល់ក្រុងទេពបុរី ជាច្រើនលើកច្រើនសា តែដោយ

---

**(១៨)** មានប្រភពនិងរបាយការណ៍ជាច្រើនសរសេរជាភាសាសៀមអំពី « ការបះបោររបស់ចៅអនុ» ហើយនៅក្នុងនេះ មានការរាយការណ៍ជាផ្លូវការ ក្នុងព្រះរាជពង្សាវតាររាជ្យព្រះរាម ទី ៣ ដែលចៅព្រះយ៉ា ទិពាករវង្ស បានតែង *พระราชพงศาวดารกรุงรตนโกสินทร์ รัชกาลที่ ๓* [**ព្រះរាជពង្សាវតារក្រុងរតនកោសិន្ទ្រ រជ្ជកាលទី ៣**] (ជាភាសាសៀម) ក្បាលទី ១ បាងកក ការបោះពុម្ពរបស់គុរុសភា គ.ស. ១៩៦១ ។ សូមមើលទំព័រទី ៤៥–៤៨ អំពីចម្បាំងនៅគោរាជ ហើយនិង ទ. ៩០–៩៣ អំពីការរាយការណ៍ល្អិតល្អន់ស្តីពីការដាក់ទណ្ឌកម្មនៅមុខសាធារណជន ។

**(១៩)** កំណត់អ្នកបកប្រែ ៖ ខេត្តនគររាជសីមា និងទីរួមខេត្ត មានឈ្មោះសាមញ្ញក្នុងភាសាខ្មែរសុរិន្ទ ថា គោរាជ ។ ក្នុងភាសាសៀម ក៏ហៅដូច្នេះដែរ តែបញ្ចេញសម្លេងតាមភាសាគេថា ខូរ៉ាត ។ ខ្មែរស្រុកខ្មែរ ដោយពុំស្គាល់ឈ្មោះដែលអ្នកស្រុកដាក់ ក៏ហៅច្រឡំថា កូរ៉ាត តាមរយៈអត្ថបទជាភាសាបារាំងសែសនិងអង់គ្លេស ។

**(២០)** អ្នកស្រី សាយពិណ កែវង៉ាមប្រសើដ្ឋ បានពន្យល់ថា ពុំមានចែងអំពីវីរនារីនេះនៅក្នុងកំណត់ត្រានៅកាលសម័យនោះឡើយ តែកេរ្តិ៍ឈ្មោះរបស់នាងជាវីរនារីជាតិនោះ បានលេចពុះក្នុងជំនាន់ក្រោយ ៗ គឺនៅក្នុងទសវត្សរ៍ឆ្នាំ ១៩២០ ឬ ១៩៣០ ហើយគេបានចាត់ទុកនាងជាយាយទេពរក្សាស្រុកក្នុងពេលថ្មីៗនេះប៉ុណ្ណោះទេ ។ សូមមើល សាយពិណ កែវង៉ាមប្រសើដ្ឋ (สายพิณ แก้วงามประเสริฐ) *การเมืองในอนุสาวรีย์ท้าวสุรนารี* [**នយោបាយក្នុងវិមានអនុស្សាវរីយ៍ថាវសុរនារី**] (ជាភាសាសៀម) (បាងកក ការបោះពុម្ពរបស់មតិជន គ.ស. ១៩៩៥) ។ សៀវភៅនេះ ធ្វើឲ្យកើតរឿងជជែកប្រកែក ព្រោះអ្នកស្រុកយល់ថា ជាការប្រមាថមើលងាយសហគមន៍និងជាតិ ។ លោក ឆាល្ស ខៃស៍ (Charles Keyes) បានអភិប្រាយពីការជជែកប្រកែកអំពីការចងចាំ ក្នុង "National Heroine or Local Spirit? The Struggle over Memory in the Case of Thao Suranaree of Nakhon Rachasima" « [វីរនារីជាតិ ឬ អ្នកជូនរក្សាស្រុក? ការប្រយុទ្ធអំពីការចងចាំ ក្នុងករណីថាវសុរនារីពីនគររាជសីមា] » (ជាភាសាអង់គ្លេស) ក្នុង *Social Memory and Cultural Crisis: modernity and identity in Thailand and Laos* [**ការចងចាំនៃសង្គម និងវិបត្តិវប្បធម៌ ៖ ភាពទំនើបនិងអត្តសញ្ញាណនៅប្រទេសថៃនិងប្រទេសលាវ**] ក្រុងឡុងដ្រ៍ រូតឡិដហ្ស៍ / ខឺរហ្សុន គ.ស. ២០០២ ទ. ១១៣–១៣៦ ។

គ្មានលទ្ធផលអ្វីសោះ ទ្រង់ព្រះចិន្តាថា ត្រូវតែមានប្រតិកម្ម ។ តាមប្រវត្តិសាស្ត្រផ្លូវការរបស់លាវ ព្រមទាំងតាមរឿងតំណាលក្នុងស្រុក ចម្បាំងដែលកើតឡើងពីឆ្នាំ ១៨២៦ ដល់ ១៨២៩ ប្រៀបដូចជាសង្គ្រាមប្រឆាំងនឹងអំពើឃោរឃៅរបស់សៀម និងជាការបះបោរប្រឆាំងនឹងអំពើជិះជាន់របស់សៀម ច្រើនជាងការរំលោភឯករាជភាពរបស់សៀម ខុសពីការពិពណ៌នាជាផ្លូវការរបស់សៀម(២១) ។

ទាក់ទិននឹងប្រទេសកម្ពុជា មានប្រយោគក្លាយជាពាក្យស្លោកមួយចំនួន ចែងអំពីខ្មែរ មានខ្លឹមសារថា ខ្មែរជាមនុស្សគួចតាចថោកទាប ដែលប្រជាជាតិសៀមពុំគប្បីមានទំនុកទុកចិត្តទាល់តែសោះ ។ នៅក្នុងពាក្យស្លោកទាំងនេះ មាន «ខមដាំឌិន ขอมดำดิน [ខ្មែរមុជដី]» និង «ខៈម៉ែនប្រែផាក់ เขมรแปรพักตร์ [ខ្មែរប្រែក្បត់]» ជាដើម ។ រឿងទី ១ គឺជារឿងល្បីមួយអំពីព្រះរាជាសៀម ១ ព្រះអង្គនៅសម័យក្រុងសុខោទ័យ ព្រះនាម ព្រះរួង(២២) ដែលបានប្រឆាំងនឹងអំណាចរបស់ស្តេចចក្រពត្តិខ្មែរកាលពីព្រេងនាយ ។ ព្រះរាជាខ្មែរបានបញ្ជូនពញាតេជោដាំឌិន(២៣) ដើម្បីទៅឃ្លាំមើលព្រះរួង ។ ពញាតេជោដាំឌិនចេះធ្វើដំណើរជ្រែកដី ហើយបានលេចចេញពីដីត្រង់ទីដែលនាយរួងកំពុងបោសដី នៅក្នុងវត្តអារាម ១(២៤) ។ តែនាយរួង ដែលកំពុងរង់ចាំតេជោដាំឌិននោះ បានសូត្រមន្តអាគម ធ្វើឲ្យពញាតេជោដាំឌិនក្លាយជាថ្ម(២៥) ។

រីឯរឿង «ខ្មែរប្រែក្បត់» គេធ្លាប់ប្រើចំពោះព្រឹត្តិការណ៍ផ្សេងៗ នៅពេលដែលទំនាក់ទំនងរវាងក្រុងកម្ពុជាធិបតីនិងក្រុងស្រីអយុធ្យា តានតឹងខ្លាំង ចាប់តាំងពី ស.វ. ទី ១៤ ។ តាមមតិរបស់ប្រវត្តិវិទូថៃបច្ចុប្បន្ន ព្រះមហាក្សត្រខ្មែរទាំងឡាយមិនស្មោះត្រង់ចំពោះព្រះមហាក្សត្រក្រុងស្រីអយុធ្យាដែលមានចិត្តបុណ្យ ហើយព្រះមហាក្សត្រខ្មែរឧស្សាហ៍រត់ទៅម្ខាងទៀត ឬក៏វាយប្រទេសសៀម ក្នុងពេលដែលសៀមមានបញ្ហា(២៦) ។ រឿងនិទាន

---

**(២១)** សូមមើល មយូរី និង ផឺយផាន់ ង៉ាវសីវ៉ាត់ “Lao Historiography and Historians: case study of the war between Bangkok and the Lao in 1827” « [ពង្សាវតារវិទ្យា និងប្រវត្តិវិទូលាវ ៖ ការសិក្សាករណីសង្គ្រាមរវាងក្រុងទេពបុរីនិងប្រទេសលាវក្នុងឆ្នាំ ១៨២៧] » (ជាភាសាអង់គ្លេស) ក្នុង *Journal of Southeast Asian Studies* [**ទស្សនាវដ្ដីសិក្សាអំពីអាស៊ីអាគ្នេយ៍**] (ជាភាសាអង់គ្លេស) លេខ ២០.១ (គ.ស. ១៩៨៩) ទ. ៥៥–៦៩ ហើយនិងសៀវភៅមួយទៀតរបស់អ្នកនិពន្ធដដែល អំពីប្រធានបទដដែល *Paths to Conflagration* [**ផ្លូវឆ្ពោះទៅរកមហាអគ្គិភ័យ**] ក្រុងអ៊ីថាកា ការបោះពុម្ពរបស់កម្មវិធីយ៉េលអំពីអាស៊ីអាគ្នេយ៍ គ.ស. ១៩៩៨ ទ. ១៦៣–២២២ ។

**(២២)** កំណត់អ្នកបកប្រែ ៖ ក្នុងពង្សាវតារខ្មែរខ្លះ ហៅព្រះអង្គថា ពញារោង ។

**(២៣)** កំណត់អ្នកបកប្រែ ៖ ក្នុងអត្ថបទខ្មែរខ្លះ សរសេរថា តេជោដំឌិន ។ ដាំឌិន ជាពាក្យសៀម ដាំ មានន័យថា « បោះពួយ, មុជ » ហើយនិង ឌិន មានន័យថា « ដី » ។

**(២៤)** កំណត់អ្នកបកប្រែ ៖ តាមពង្សាវតារខ្មែរ កាលនោះ ព្រះរួងមិនទាន់ឡើងគ្រងរាជសម្បត្តិ លោកជានេន ឬ លោកសង្ឃ ។ មានពង្សាវតារខ្មែរមួយចំនួនហៅលោកថា នាយរួង មួយចំនួនទៀត ហៅលោកថា នាយរោង ។

**(២៥)** សូមមើល ចៅហ្វា (ព្រះអង្គម្ចាស់) វជិរាវុធ (ព្រះរាម ទី ៦) *บทละครพูด เรื่องพระร่วง* [**បទល្ខោននិយាយ រឿងព្រះរួង**] (ជាភាសាសៀម) បាងកក បណ្ណកិច្ច គ.ស. ១៩៧៧ ទ. ៧ ។

**(២៦)** សូមមើល វិន័យ ពង្សស្រីពៀរ “Ayotchapura-Sriyasothon” « [អយោជ្ឈបុរៈ–ស្រីយសោធរ] » (ជាភាសាអង់គ្លេស) ក្នុង *ความยอกย้อนของประวัติศาสตร์ไทย* [**សេចក្ដីស្មុគស្មាញនៃប្រវត្តិសាស្ត្រសៀម**] (ជាភាសាសៀម) វិន័យ ពង្សស្រីពៀរ (วินัย พงศ์ศรีเพียร វិណៃ ផុងស៊ីផៀន) ជាបណ្ណាធិការ ការតែងសេចក្ដីដើម្បីបង្ហាញការគោរពស្រឡាញ់ចំពោះសម្ដេចចៅហ្វាក្រុមព្រះយ៉ាសុភ័ទ្រតិស តិសកុល ក្នុងឱកាសបុណ្យខួបកំណើត ៧២ វស្សា (បាងកក គណៈកម្មការប្រវត្តិសាស្ត្រ សំណាក់នាយករដ្ឋមន្ត្រី គ.ស. ១៩៩៦) ។ នៅក្នុងអត្ថបទនេះ លោក វិន័យ បានសរសេរថា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុង ស.វ. ទី ១៤ និង ១៥ ដែលជា→

*ល្បីមួយ អំពីខ្មែរដែលមិនស្មោះត្រង់នោះ ហើយដែលដកស្រង់ពីព្រះរាជពង្សាវតារក្រុងស្រីអយុធ្យា បានរៀបរាប់អំពីគុណវិបត្តិមួយទៀតរបស់ខ្មែរ គឺការមានចិត្តកំសាក ។ ក្រោយពីពេលក្រុងស្រីអយុធ្យាត្រូវភូមាវាយឈ្នះ នៅឆ្នាំ ១៥៦៩ ព្រះរាជាខ្មែរគង់នៅទីក្រុងលង្វែក ឆ្លៀតឱកាសដើម្បីទៅវាយប្ញន់នគរតូចៗ នៅតាមព្រំដែនដែលជាស្រុកចំណុះរបស់សៀម ។ ព្រះរាជពង្សាវតារក្រុងស្រីអយុធ្យាតំណាលថា ព្រះចៅនរេសូរ[២៧] ដែលជាវីរបុរសសៀម ១ រូប ដែលបានដណ្តើមយក «ឯករាជ្យ» ពីភូមាវិញ ព្រះអង្គទ្រង់ខ្វាល់ជាពន់ពេកនឹងអំពើវាយប្ញន់របស់ព្រះមហាក្សត្រខ្មែរ ដែលបានវាយប្រហារប្រទេសសៀមពីក្រោយខ្នងយ៉ាងកំសាក ក្នុងគ្រាដែលសៀមរវល់ច្បាំងនឹងភូមា ។ នាឆ្នាំ ១៥៩៤ ព្រះចៅនរេសូរលើកទ័ពទៅវាយក្រុងលង្វែក ហើយចាប់ព្រះរាជាខ្មែរ ។ តាមពង្សាវតារក្រុងស្រីអយុធ្យា ព្រះរាជាខ្មែរត្រូវផ្តន្ទាទោសតាមពិធីដ៏ចម្លែកមួយ ហៅថា «បឋមកម្ម» ដ្បិតជាពិធីបំបាក់មុខយ៉ាងខ្លាំងបំផុត ដែលពុំធ្លាប់មានពីមុនមក ហើយមិនឲ្យធ្វើតទៅទៀតឡើយនៅពេលក្រោយៗមក ។ នៅពេលដែលគេប្រហារជីវិតព្រះរាជាខ្មែរ គេដាក់ព្រះលោហិតក្នុងថាសមួយ យកទៅលាងព្រះបាទារបស់ព្រះនរេសូរ ។ ក៏ប៉ុន្តែ ព្រឹត្តិការណ៍នេះ មិនដែលបានបញ្ជាក់ក្នុងពង្សាវតារខ្មែរមួយណាឡើយ ។ ផ្ទុយទៅវិញ បើយោងទៅតាមប្រភពបច្ចុប្បន្នមួយទៀត តាមពិត ព្រះរាជាខ្មែរបានទៅភៀសព្រះអង្គនៅក្រុងមួយ ឈ្មោះក្រុងវៃង ហើយសោយទិវង្គតនៅទីនោះ[២៨] ។ យើងអាចឆ្ងល់ថា តើស្តេចចក្រពត្តិសៀមមួយអង្គណា នឹងទ្រង់អនុញ្ញាតឲ្យត្រាំព្រះបាទាក្នុងឈាមសត្រូវរបស់ព្រះអង្គ ? ព្រឹត្តិការណ៍គួរឲ្យខ្ពើមរអើនេះ ប្រហែលជាចេញមកពីគំនិតស្រមើស្រមៃរបស់សៀម ដែលចង់សម្តែងថា ព្រះលោហិតរបស់ស្តេចខ្មែរ ទោះជាព្រះលោហិតនោះហូរមកពីព្រះសិរសាក៏ដោយ ក៏គ្មានតម្លៃអ្វីលើសពីការប្រើប្រាស់សម្រាប់លាងព្រះបាទារបស់ស្តេចសៀមតែប៉ុណ្ណោះទេ ។ ទោះពិតក្តី មិនពិតក្តី និមិត្តរូបរបស់រឿងនេះ បានជាប់ជិតក្នុងគំនិតអារម្មណ៍ ដែលថៃមានទៅលើខ្មែររហូតដល់សព្វថ្ងៃនេះរួចទៅហើយ ។*

*ទំនាស់រវាងប្រទេសសៀមនិងប្រទេសយួន បានចាប់ផ្តើមមានតែក្នុងពេលក្រោយៗ គឺនៅចុង ស.វ. ទី ១៨ តែប៉ុណ្ណោះ ។ ក្រោយពេលដែលមានការបះបោររបស់ពួកតៃសឺន នៅក្នុងទសវត្សរ៍ឆ្នាំ ១៧៨០ នៅប្រទេសយួន មានតែស្តេច ង្វៀន អាញ់[២៩] ប៉ុណ្ណោះ ដែលបានរួចជីវិតនៅក្នុងព្រះរាជវង្សានុវង្ស ង្វៀន ។ ស្តេចធៀងទឺ បានភៀសព្រះអង្គទៅគង់នៅទីក្រុងទេពបុរី ពីឆ្នាំ ១៧៨៥ ដល់ ១៧៨៧ ដោយបានជ្រកក្រោមម្លប់*

---

↲ មូលដ្ឋាននៃទស្សនៈជាគំរូនេះ គេបានយល់ខុសស្រឡះ ដោយពឹងផ្អែកលើប្រភពដែលពុំអាចទុកចិត្តបានទេ និងដោយការអានមិនត្រឹមត្រូវ ។ លោក វិន័យ ក៏ហ៊ានដល់ទៅអះអាងថា តាមការពិត គឺ « ទស្សនៈទូទៅ » អំពី « ខ្មែរប្រែភក្ត្រ » នេះឯង ដែលបានជម្រាបនិងផ្តល់រូបរាង ដល់ការបកស្រាយ ជាជាងការផ្ទុយទៅវិញ ។

**(២៧)** កំណត់អ្នកបកប្រែ ៖ នៅក្នុងព្រះរាជពង្សាវតារខ្មែរ មានព្រះនាមថា ព្រះចៅនរេសូរ ឬ ព្រះចៅនរេន្ទ្រសូរ ។

**(២៨)** មានិច ជុំសាយ (มานิจ ชุมสาย ម៉ានិត ឈុំសាយ) « *พระนเรศวรและกรุงละแวก จากบันทึกของชาวฝรั่งเศส และบันทึกของบาทหลวงชาวโปรตุเกส* « [ព្រះនរេសូរនិងក្រុងលង្វែក ពីកំណត់ចំណាំរបស់ជនបារាំងសែស និងកំណត់ចំណាំរបស់អ្នកផ្សាយសាសនាកាតូលិកជាតិព័រទុយគេ] » (ជាភាសាសៀម) ក្នុង [**សម្តេចព្រះនរេសូរមហារាជ ៖ ៤០០ ឆ្នាំនៃការគ្រងរាជ្យ**] (ជាភាសាសៀម) វុឌ្ឍិជ័យ មុលសិន ជាបណ្ណាធិការ (បាងកក គណៈកម្មការប្រវត្តិសាស្ត្រ សំណាក់នាយករដ្ឋមន្ត្រី គ.ស. ១៩៩០) ទ. ១៦០–១៦៤ ។

**(២៩)** នៅក្នុងពង្សាវតារសៀម ហៅ អុងឈៀងស៊ឺ ហើយនៅក្នុងពង្សាវតារខ្មែរ ហៅថា ស្តេច ធៀងទឺ ឬ ស្តេច យ៉ាឡុង ឬ ស្តេច យ៉ាឡុង់ ។

ពោធិសម្ភារនៃព្រះរាម ទី ១ នៃរាជវង្សចក្រី (គឺ ព្រះពុទ្ធយ៉តហ្វាចូឡាលោក) ។ ថ្ងៃមួយ ស្តេចឆៀងទី ទ្រង់ព្រះចិន្តាចាកចេញពីក្រុងទេពបុរី ត្រឡប់ទៅស្រុកយួនដើម្បីទៅដណ្តើមរាជសម្បត្តិវិញ តែស្តេចឆៀងទីបានលបរត់ដោយពុំបានក្រាបបង្គំទូលព្រះចៅសៀមឲ្យជ្រាបតាមការគួរ ។ នៅខាងរាំងសៀម គេអន់ចិត្តយ៉ាងក្រៃលែង តែតាមស្តេចយួនពុំទាន់[(៣០)] ។ ទោះជាយ៉ាងណាក៏ដោយ ព្រះចៅសៀមបានបញ្ជូនទ័ពជើងទឹក ទៅជួយស្តេចយួនរហូតដល់ពេលស្តេចឆៀងទី បានជ័យជំនះ ហើយបានតាំងចក្រកពងឯកភាពមួយ ។ ដោយហេតុថា ព្រះបាទយ៉ាឡុង ទ្រង់ដឹងគុណព្រះចៅសៀម ក៏បានរក្សាសម្ព័ន្ធមេត្រីល្អៗ ជាមួយព្រះរាម ទី ១ ។ ក៏ប៉ុន្តែ មានការតានតឹងនិងការស្អប់ឈ្នានីសគ្នា ដែលបានកើតឡើង រវាងស្តេចយួននិងស្តេចសៀមក្នុងសម័យក្រោយៗ មក គឺក្នុងពាក់កណ្តាលទី ១ នៃ ស.វ. ទី ១៩ ជាពិសេសដោយសារបញ្ហាអធិបតេយ្យភាពទៅលើស្រុកលាវនិងស្រុកខ្មែរ ។ នៅទីបំផុត មានសឹកសង្គ្រាមកើតឡើងរវាងប្រទេសទាំងពីរ ដោយការទាមទារនគរលាវមួយចំនួន ជាស្រុកចំណុះ ។ សង្គ្រាមនោះ មានរយៈពេល ១៤ ឆ្នាំ (១៨៣៣–១៨៤៧) ហើយត្រូវបញ្ចប់ដោយគ្មានលទ្ធផលជាក់ស្តែង[(៣១)] ។

តាមទស្សនៈថៃ សៀមបានជួយប្រទេសយួនឲ្យគង់វង្ស តែនៅទីបំផុតយួនមិនដឹងគុណហើយក្លាយជាគូប្រជែងធំ ១ ។ ម្យ៉ាងទៀត ការណ៍ដែលយួនទាមទារអធិបតេយ្យភាពលើប្រទេសលាវនិងប្រទេសខ្មែរ ក្រោយៗ មកបារាំងសែសយកជាលេស ដើម្បីទាមទារបណ្តាដែនដីនោះ ហើយការណ៍នេះបណ្តាលឲ្យកើតការប្រយុទ្ធរវាងប្រទេសសៀមនិងប្រទេសបារាំងសែស នៅចុងទសវត្សរ៍ឆ្នាំ ១៨៨០ ដល់ដើមទសវត្សរ៍ឆ្នាំ ១៨៩០ ហើយបណ្តាលឲ្យសៀម «បាត់ដែនដីរបស់ថៃមួយចំនួន» ទៅជារបស់បារាំងសែសវិញ ។ ហេតុនេះហើយបានជាថៃយល់ឃើញថា ប្រទេសយួនជាអំណាចឈ្លានពាននិងរាតទីនិយមមួយ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ។ រូបភាពនេះបានវិវត្តនិងចម្រើនឡើង នៅជំនាន់សង្គ្រាមត្រជាក់ ដោយថៃយល់ថា ប្រទេសវៀតណាមកុម្មុយនិស្ត ជាស្នូលរបស់ឥទ្ធិពលកុម្មុយនិស្តនៅក្នុងអាស៊ីអាគ្នេយ៍ ដោយទំនុកបម្រុងចលនាឧទ្ទាម ដែលខំរាយបំផ្លាញប្រទេសថៃ ហើយជាប្រទេសដែលគាំទ្ររបបនៅស្រុកលាវនិងស្រុកខ្មែរ ក្រោយពីប្រទេសទាំងពីរនោះ បានធ្វើបដិវត្តន៍ ។

នៅក្នុងពង្សាវតារក្រុងស្រីអយុធ្យានិងក្រុងធនបុរី–ទេពបុរី ពុំសូវមានចែងអំពីប្រទេសនានា ដែលនៅខាងត្បូងប្រទេសសៀមទេ ។ បណ្តារដ្ឋមឡាយូទាំងឡាយ ដែលនៅប៉ែកខាងជើងនៃជ្រោយមឡាយូ ស្ថិតនៅក្រោមអំណាចរបស់នគរស្រីធម្មរាជជាញឹកញាប់ (នៅក្នុងអត្ថបទបារាំង គេច្រើនហៅនគរស្រីធម្មរាជថា ណៈខន ឞ្រីលីហ្គ័រ) ។ នគរស្រីធម្មរាជធ្វើអ្វីៗសម្រាប់គុណប្រយោជន៍ផ្ទាល់ខ្លួន តែធ្វើក្នុងនាមប្រទេសសៀមជាដរាប ។ ក៏ប៉ុន្តែ រឿងអំណាចរបស់ប្រទេសសៀមទៅលើបណ្តានគរមឡាយូ តាមរយៈនគរស្រីធម្មរាជ ក្នុងពង្សាវតារ ពុំសូវជាក់ស្តែងប៉ុន្មានទេ ។ ពង្សាវតារសៀមបានកត់ត្រាឧប្បត្តិហេតុដែលកើតឡើងជាមួយនគរមឡាយូនានា តែ

---

(៣០) *พระราชพงศาวดารกรุงรัตนโกสินทร์ ฉบับหอสมุดแห่งชาติ รัชกาลที่ ๑* [**ព្រះរាជពង្សាវតារក្រុងរតនកោសិន្ទ្រ ច្បាប់បណ្ណាល័យជាតិ រជ្ជកាលទី ១**] (ជាភាសាសៀម) បាងកក ឃ្លាំងវិទ្យា គ.ស. ១៩៦២ ។ តាមព្រះរាជពង្សាវតារ សម្តេចព្រះមហាឧបរាជសៀម មានមាត់ទិព្វ ព្រោះព្រះអង្គបានថ្លែងអំពីការព្រួយបារម្ភរបស់ព្រះអង្គ ថា ស្តេច ង្វៀន អាញ់ ស្គាល់ក្រុងទេពបុរីយ៉ាងច្បាស់ល្អពេក យួនជំនាន់ក្រោយ ៗ អាចបង្ករឿងដល់ប្រទេសសៀមបាន ។

(៣១) ចៅព្រះយ៉ា ទិពាករវង្ស បានតែង *พระราชพงศาวดารกรุงรัตนโกสินทร์ รัชกาลที่ ๓* [**ព្រះរាជពង្សាវតារក្រុងរតនកោសិន្ទ្រ រជ្ជកាលទី ៣**] (ជាភាសាសៀម) ក្បាលទី ១ និងទី ២ បាងកក ការបោះពុម្ពរបស់គុរុសភា គ.ស. ១៩៦១ ។ សូមមើលខ្ទង់មេពាក្យពី ព.ស. ២៣៧៦ ដល់ ព.ស. ២៣៩០ ។

នៅពេលណាដែលនគរស្រីធម្មរាជគ្រប់គ្រងបញ្ហាលែងបាន ហើយត្រូវការអន្តរាគមន៍ពីសំណាក់ប្រទេសសៀម ។ ឧទាហរណ៍មានដូចជា៖ ទី ១ ការប្រយុទ្ធរវាងបណ្ដាស្ដេចមឡាយូ ដែលបណ្ដាលឲ្យបក្សខ្លះសុំពឹងសៀម; ទី ២ ការយឺតយ៉ាវក្នុងការថ្វាយ «ប៊ុង៉ាម៉ាស» (គឺ ផ្កាមាស ដែលជាបណ្ណាការដែលសម្គាល់ថា ជាស្ដេចស្រុកចំណុះ) ឬការមិនព្រមថ្វាយផ្កាមាសទៅព្រះចៅនៅបាងកក, ទី ៣ ការប្រឆាំងជាចំហនឹងសៀមក្នុងទម្រង់ផ្សេងៗទៀត ហើយជួនកាល ក៏មានការវាយទីក្រុងនានានៅប្រទេសសៀម (ជួនកាលក៏មានដល់ការវាយទីក្រុងស្រីអយុធ្យាដែរ) ។ ក្រៅពីនោះ សៀមទុកបណ្ដានគរមឡាយូ ជាស្រុកចំណុះ ដែលនៅឆ្ងាយ ហើយដែលចូលចិត្តរុកកួន ។ នៅឆ្នាំ ១៩០៩ សៀមយល់ព្រមឲ្យផ្នែកខ្លះៗនៃនគរមឡាយូមួយចំនួន ដែលនៅខាងជើងជ្រោយមឡាយូ ទៅពួកអង់គ្លេស ជាថ្នូរនឹងការផ្ដត់ផ្គង់ប្រាក់សម្រាប់គ្រោងការសង់ផ្លូវរទេះភ្លើង ។ នៅខាងរាំងសៀម គេក៏បាននិយាយដែរថា ទោះបីយ៉ាងណា ក៏មិនអាចមើលថៃស្រុកចំណុះនៅខាងត្បូងនោះ ដែលច្រើនបក្ខពួកផ្ទើងរ៉ាវបានដែរ ។

## ចំណេះដឹងបែបចក្រពត្តិនិយមសៀមអំពីអាស៊ីអាគ្នេយ៍ ទៅតាមកាលសម័យ

ទស្សនៈអាត្មានិយមរបស់ស្យាមរដ្ឋ បានបណ្ដាលឲ្យកើតចំណេះដឹងរបៀបចក្រពត្តិនិយមអំពីភូមិភាគអាស៊ីអាគ្នេយ៍ ហើយតាមចំណេះនេះ ប្រទេសជិតខាង ឬមួយជាខ្មាំងសត្រូវ (គូប្រជែង) ឬមួយជាស្រុកចំណុះ (ដែលគេច្រើននិយាយថា ជាដែនដីរបស់ថៃ ដែលពួកអាណានិគមនិយមបារាំង បានលេបយកដោយមិនសមហេតុផល) ។ រដ្ឋថៃទំនើប បានទទួលទស្សនៈចក្រពត្តិនិយមនេះ ។ ចំណេះបែបចក្រពត្តិនិយម បានផ្ដល់នូវការផុសគំនិត និងមូលដ្ឋានខាងបញ្ញត្តិ សម្រាប់កសាងអត្តសញ្ញាណជាតិថៃ ហើយដំណើរការនេះ បានចាប់ផ្ដើមក្នុងចន្លោះដំណាក់កាលដែលរដ្ឋសម្បូណ៌ាជ្ញានិយមសៀមខ្លាំងបំផុត[៣២] និងដំណាក់កាលខ្លាំងបំផុតនៃលទ្ធិជាតិនិយមហ្វាស៊ីស នៅពេលសង្គ្រាមលោកលើកទី ២ ។ ចំណេះបែបចក្រពត្តិនិយមនេះ ពិតជាសមនឹងលទ្ធិជាតិនិយមទំនើប និងរបៀបដែលលទ្ធិជាតិនិយមនេះយល់ពីប្រវត្តិសាស្ត្រ ។ ចំណេះបែបចក្រពត្តិនិយមនេះ ធ្វើឲ្យការយល់ឃើញពីប្រវត្តិសាស្ត្របែបរាជានិយមផង ជាតិនិយមផង មានឥទ្ធិពលគ្របលើចំណេះដឹងរបស់សង្គមថៃអំពីអាស៊ីអាគ្នេយ៍ ដូចដែលបានបញ្ជាក់ក្នុងការសិក្សាអំពីបណ្ណានុក្រម ដែលបានរៀបរាប់នៅដើមអត្ថបទនេះ ។ ជោគជ័យនេះ បានមកពីការគ្រប់គ្រងយ៉ាងខ្លាំងរបស់រដ្ឋ ទៅលើការអប់រំ និងផលិតផលវប្បធម៌ ហើយក៏មកពី «ថៃយូបនីយកម្ម» (ដំណើរការដើម្បីធ្វើឲ្យជនជាតិផ្សេងៗនៅប្រទេសថៃ ទុកខ្លួនថា ជាជនជាតិថៃ) ដែលធ្វើនៅ ស.វ. ទី ២០ ផងដែរ ដែលមានជោគជ័យសមល្មម ។ ចំណេះបែបចក្រពត្តិនិយម ក៏ត្រូវនឹងជំនាន់សង្គ្រាមត្រជាក់ ក្នុងពេលដែលការសិក្សាអំពីប្រទេសជិតខាង ភាគច្រើនជារបាយការណ៍ការិយាធិបតេយ្យ អំពីសន្តិសុខនិងកិច្ចការទូត ដូចលោកជាញវិទ្យ មានប្រសាសន៍ ។ ការសិក្សាទាំងនោះ ដែលសម្រាប់ប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត បានទុកប្រទេសថៃជាសសរកន្ទោងនៃពិភពលោកសេរី ដែលមានខ្មាំងសត្រូវកុម្មុយនិស្ត ចោមរោម និងខំជ្រៀតចូលប្រទេសថៃ ។ ផលិតកររបស់ចំណេះបែបនេះ គឺជាអ្នកស្រាវជ្រាវក្នុងស្ថាប័នថ្នាក់ឧត្តមសិក្សា ចារកិច្ចយោធា (ក្រុមលបយកការណ៍ទាហាន) ភ្នាក់ងារខាងសន្តិសុខ ទូត និងទីភ្នាក់ងារខាង «សង្គ្រាមចិត្តសាស្ត្រ» ។

កេរដំណែលនៃចំណេះបែបចក្រពត្តិនិយម អំពីការយល់ឃើញទៅលើប្រទេសជិតខាងនីមួយៗ នៅតែខ្លាំងនៅឡើយ ។ ដូចដែលបានថ្លែងមុននេះ ភាពឃោរឃៅ និងភាពមិនអាចទៅជាស៊ីវិល្បៃនៃភូមា បានផុសចេញ

---

**(៣២)** កំណត់អ្នកបកប្រែ៖ ក្នុងរដ្ឋ ឬ របបសម្បូណ៌ាជ្ញានិយម ព្រះរាជាទ្រង់មានអំណាចផ្ដាច់ការ ។

ឡើងវិញក្នុងគំនិតថៃ ក្នុងឱកាសជាច្រើន ។ នៅក្នុងចំណោមរឿងភាពយន្តនិងរឿងល្ខោនល្បីៗ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៤០ មានភាពយន្តមួយរឿង ដែលប្រជាជននិយមយ៉ាងខ្លាំង ឈ្មោះ «បាងរចាន់»(៣៣) ហើយរឿងជាច្រើនដែលជាទីគាប់ចិត្តរបស់មហាជន គឺសោកនាដកម្មប្រវត្តិសាស្ត្រ អំពីសៀមដែលច្បាំងនឹងប្រទេសជិតខាង ជាពិសេសប្រទេសភូមា ហើយនេះ ទោះជាប្រទេសបច្ចាមិត្ត ដែលលទ្ធិថៃនិយមដៅទុកនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៣០–១៩៤០ ហើយនិងការប្រឆាំងនឹងសាកលភាវូបនីយកម្មប៉ុន្មានឆ្នាំមុន ពុំមានអ្វីទាក់ទងទៅនឹងប្រទេសភូមាក៏ដោយ ។ ប៉ុន្តែ ក្នុងគំនិតថៃ ប្រទេសភូមានៅតែជានិមិត្តរូបនៃសត្រូវបរទេសនៅឡើយ ។

រីឯប្រទេសលាវ ក៏នៅតែជាប្អូនដ៏កម្សោយ ដូចនៅសម័យមុនៗដដែល ។ សេដ្ឋកិច្ចប្រទេសលាវ នៅតែពឹងផ្អែកប្រទេសថៃ ។ ហើយមានគេចូលចិត្តនិយាយថា បើគ្មានថៃដែលមានចិត្តអធ្យាស្រ័យអាណិតប្រទេសលាវ ដោយយល់ព្រមទិញអគ្គិសនី ដែលប្រទេសលាវផលិត ហើយដែលនៅតែទិញក្រោយពីបដិវត្តន៍កុម្មុយនិស្តលាវកាលពីឆ្នាំ ១៩៧៥ សេដ្ឋកិច្ចលាវប្រហែលជារលំយូរណាស់មកហើយ ។ ក៏ប៉ុន្តែ តាំងពីសង្គ្រាមវៀតណាម ថៃទុកប្រទេសលាវជាបរិវាររបស់វៀតណាមកុម្មុយនិស្ត ហើយជាការគំរាមកំហែងដល់សន្តិសុខរបស់ប្រទេសថៃ ដែលថៃត្រូវតែប្រយ័ត្នប្រយែង ។ ការខ្វះទំនុកទុកចិត្តនៅតែខ្លាំង ថ្វីដ្បិតតែថៃទុកលាវជាបងប្អូននឹងគ្នា ហើយថ្វីដ្បិតតែសង្គ្រាមត្រជាក់បានរលត់ហើយក្តី ។ តាមការពិត ការប្រយុទ្ធដោយមានប្រើសស្ត្រាវុធ ដែលផ្ទុះខ្លាំងជាងគេក្នុងពេលក្រោយៗនេះ គឺការដណ្តើមគ្នានូវភូនភ្នំមួយគ្មានប្រជាជននៅ ចន្លោះប្រទេសថៃនិងប្រទេសលាវ ដែលមានការវាយគ្នានៅឆ្នាំ ១៩៨៨ ។ ជម្លោះតូចតាចតាមព្រំដែនលាវ–ថៃ នៅតែមានជារឿយៗ ដោយរបបលាវឧស្សាហ៍ចោទថៃថា ជួយគាំទ្រពួកឧទ្ទាមជាតិហ្មុង និងពួកឧទ្ទាមលាវស (លាវរាជានិយម) តែរដ្ឋាភិបាលថៃព្រមទាំងប្រជាជនថៃ បដិសេធការចោទនេះ ដោយថា ថៃខំអាណិតស្រឡាញ់លាវ តែបែរជាលាវមិនចេះដឹងគុណ និងមានអាកប្បកិរិយាគឃ្លើន ។ ក្រៅពីភាពតានតឹងរវាងរដ្ឋទាំងពីរ ពេលខ្លះការណ៍ដែលថៃមិនចូលចិត្តលាវ បានក្លាយទៅជារឿងជជែកតវ៉ាជាសាធារណៈ ។ ឧទាហរណ៍ មានកើតឧប្បត្តិហេតុក្នុងពេលថ្មីៗនេះ គឺនៅឆ្នាំ ២០០១ ដោយមានអ្នកចម្រៀងប្រជាប្រិយថៃខ្លះ បានជេរជាតិលាវនៅមុខមហាជនថៃ ។ រដ្ឋាភិបាលព្រមទាំងប្រជាជនលាវបានបញ្ចេញប្រតិកម្មយ៉ាងខ្លាំង ពីព្រោះលាវអាចយល់ពាក្យសម្តីសៀមបានគ្រប់ម៉ាត់ ។ រឿងរ៉ាវមួយទៀតដែលអាចផ្ទុះយ៉ាងខ្លាំង គឺគ្រោងការផលិតខ្សែភាពយន្តមួយ ដែលសរសើរនាងសុរនារី ដែលបានឈ្នះព្រះបាទ អនុវង្ស ក្នុងសឹកសង្គ្រាមឆ្នាំ ១៨២៦–១៨២៩ ដូចដែលបានរៀបរាប់មុននេះ ។ ពិតមែនហើយ ខ្សែភាពយន្តនេះ យល់ស្របទាំងស្រុងនឹងទស្សនៈថៃអំពីព្រឹត្តិការណ៍នោះ គឺយកប្រវត្តិសាស្ត្រចក្រពត្តិសៀមជាប្រវត្តិសាស្ត្រពិតៗ តែមួយគត់(៣៤) ។

ដោយសារសង្គ្រាមត្រជាក់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ បានអន់ចុះបន្តិចម្តងៗ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ សហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច (និងសហវិបុលភាពមួយយ៉ាង) ក៏ក្លាយជាគោលដៅធំមួយ ។ រដ្ឋថៃ ក៏ចាប់ផ្តើមចាត់ទុកប្រទេសជិតខាង ជាកាលានុវត្តភាពល្អខាងសេដ្ឋកិច្ច សម្រាប់មូលធននិយមថៃ ។ រំពេចនោះ អតីតសត្រូវ

---

**(៣៣)** កំណត់អ្នកបកប្រែ៖ គឺឈ្មោះភូមិមួយស្ថិតនៅជិតទីក្រុងអយុធ្យា ដែលបានតស៊ូនឹងកងពលភូមា ។

**(៣៤)** សូមមើលកាសែតប្រចាំថ្ងៃនិងប្រចាំសប្តាហ៍ ពីសប្តាហ៍ចុងក្រោយនៃខែមិថុនា ដល់ខែកក្កដា ២០០១ ជាពិសេស *នេឆ័ន់សុត ស័បដាហ៍* **ឈោឆាន់ស៊ុតសប្ដាហ៍** [**ឈោឆាន់ចុទសប្ដាហ៍**] (ជាភាសាសៀម) លេខ ១០,៤៧៣ (២៥ មិថុនា–១ កក្កដា) និង លេខ ១០,៤៧៧ (២៣ កក្កដា–២៩ កក្កដា ២០០១) ។

និងអតីតស្រុកចំណុះ បែរជាមានគុណតម្លៃផ្នែកសេដ្ឋកិច្ចវិញ ហើយក្លាយជាចំណែកមួយក្នុងការអធិប្បាយអំពី «សុវណ្ណភូមិ» ថ្មីមួយ គឺបែរជាមណ្ឌលសេដ្ឋកិច្ច ដែលនៅក្នុងនេះ អតីតសមរភូមិអាចទៅជាទីផ្សារវិញ ដូចដែលនាយករដ្ឋមន្ត្រីថៃជំនាន់នោះ គឺលោក ឆាតឆាយ ឈុន្ហះវ៉ាន់ (ជាតិជាយ ជុណ្ហាវ័ណ្ណ) មានប្រសាសន៍[៣៥] ។ នៅក្នុងទស្សនៈនេះ ប្រទេសថៃ នៅតែជាចំណុចកណ្ដាលដដែល ។ នៅក្នុងកំណើនសេដ្ឋកិច្ចដ៏ខ្លាំងនេះ មានឧស្សាហកម្មថ្មីមួយ គឺទេសចរណ៍ដែលកើតឡើង ដោយសារថៃមានការនឹកស្រណោះអតីតកាល ហើយចាត់ទុកប្រទេសជិតខាងជាតំណាងនៃប្រទេសសៀមសម័យបុរាណ ផ្ទុយពីប្រទេសថៃបច្ចុប្បន្នដែលមានភាពសម្បូរនិងចូលក្នុងសាកលភាវូបនីយកម្ម ។ របាយការណ៍របស់អ្នកកាសែត ឯកសារទូរទស្សន៍ និងក្រុមហ៊ុនទេសចរណ៍ថៃពិពណ៌នាប្រទេសជិតខាងថា ជាដែនដីពីអតីតកាល ដែលជួនកាលបានរក្សាព្រៃពណីស្រស់បំព្រង ហើយដែលពួកទេសចរថៃអាចទៅលេងបាន ដើម្បីបានស្បើយពីជីវភាពដ៏មមាញឹករបស់ប្រទេសថៃទំនើប ។ នៅក្នុងចំណោមឯកសារទូរទស្សន៍ដែលជាទីគាប់ចិត្តរបស់ទស្សនិកជនក្នុងប៉ុន្មានឆ្នាំមុន មានផលិតកម្មដែលបង្ហាញប្រទេសនានានិងទីក្រុងបុរាណនៅអាស៊ីអាគ្នេយ៍ ថា ជាកន្លែងប្រកបដោយភាពរមណីយ៍ ។ ប្រទេសជិតខាងបានក្លាយទៅជា «ទំនិញ» សម្រាប់ពាណិជ្ជកម្មទេសចរណ៍ថៃដែលមានប្រទេសថៃជាចំណុចកណ្ដាល ។

ម៉្លោះហើយ វិនិយោគនិងទេសចរណ៍ បានដឹកនាំកាលសម័យថ្មីមួយ ក្នុងទំនាក់ទំនងរបស់ប្រទេសថៃជាមួយប្រទេសជិតខាង ។ អ្នកដែលបានផលិតចំណេះបែបថ្មីនេះ ក្រៅពីសាកលវិទ្យាល័យ គឺជា អ្នកកាសែតមជ្ឈមណ្ឌលស្រាវជ្រាវរបស់សារព័ត៌មានធុរកិច្ច អ្នកយកព័ត៌មានខាងធុរកិច្ចនៅតាមខេត្តនានាតាមព្រំប្រទល់ អ្នកនិពន្ធអត្ថបទសម្រាប់ភាពយន្ត អ្នកនិពន្ធអំពីការធ្វើដំណើរ នាយកក្រុមហ៊ុនដំណើរទស្សនកិច្ច ជាដើម ។ ចំណេះបែបចក្រពត្តិនិយមបានប្រែប្រួល ក៏ប៉ុន្តែកេរដំណែលរបស់ចំណេះនេះ យើងអាចប្រទះឃើញក្នុងទស្សនៈបែបវណ្ណៈគហបតី យ៉ាងងាយស្រួល ។

## ចំណេះដឹងរបស់អ្នកស្រុកអំពីប្រទេសជិតខាង

ទោះបីជាមានការគ្របសង្កត់របស់ចំណេះបែបចក្រពត្តិនិយម និងកេររបស់ចំណេះនេះក៏ដោយ ក៏ទស្សនៈចក្រពត្តិនិយមនេះដែលមកពីមជ្ឈមណ្ឌល ពុំដែលកម្ចាត់ឲ្យអស់នូវចំណេះអំពីប្រទេសជិតខាងឯទៀតទេ ។ ឧទាហរណ៍មួយ គឺទស្សនៈរបស់លោក ប្រីឌី ភ្នំយង្គ (ព្រីឌី ផៈណុំយ៉ុង) ដែលជាមេដឹកនាំនយោបាយដ៏ល្បីឈ្មោះក្នុងទសវត្សរ៍ឆ្នាំ ១៩៣០–១៩៤០ ហើយដែលជាអ្នកមនោគមវិជ្ជារបស់បដិវត្តន៍ឆ្នាំ ១៩៣២ បានទម្លាក់របបសម្បូណ៌ាញាសិទ្ធិរាជនៅប្រទេសសៀម ហើយលោកក៏ជាមេដឹកនាំនៃចលនាអាថ៌កំបាំងប្រឆាំងនឹងពួកជប៉ុន ក្នុងសង្គ្រាមលោកលើកទី ២ ដែរ ។ វិភាគទានមួយរបស់លោក ប្រីឌី ដល់សហប្រតិបត្តិការភូមិភាគសម្រាប់អាស៊ីអាគ្នេយ៍ គឺ ការគាំទ្ររបស់លោក ដល់ចលនាជាតិនិយមនៅឥណ្ឌូចិន ហើយនៅក្នុងនោះ មានពួកយៀកមិញ

---

**(៣៥)** គំនិតដំបូងអំពី « សុវណ្ណភូមិសេដ្ឋកិច្ច » នេះ មកពីរដ្ឋាភិបាលរបស់លោក ជាតិជាយ ជុណ្ហាវ័ណ្ណ (ឆាតឆាយ ឈុនហះវ៉ាន់) (ឆ្នាំ ១៩៨៨–១៩៩១) ។ សូមមើល ផាសុក ពង្សពៃចិត្រ (ผาสุก พงศ์ไพจิตร์ ផាស៊ុក ផុងផៃជិត) និង គ្រីស បេគ័រ (Chris Baker) *Thailand: Economy and Politic* [**ប្រទេសថៃ ៖ សេដ្ឋកិច្ចនិងនយោបាយ**] (ជាភាសាអង់គ្លេស) គ្រឹះស្ថានបោះពុម្ពផ្សាយនៃសាកលវិទ្យាល័យអុក្សហ្វដ៍ គ.ស. ១៩៩៥ ទ. ៣៥០–៣៥១ ។

*ដែរ*[៣៦] *។ ក្នុងពេលសង្គ្រាមលោកលើកទី ២ លោក ប្រីតី ក៏បានផលិតរឿងភាពយន្តមួយ ដែលពុំសូវមានអ្នកណាស្គាល់ ក្រោមចំណងជើងថា «ផ្រះចៅឆាងផឿក* พระเจ้าช้างเผือก *[ព្រះចៅដំរីស]» ។ នៅក្នុងរឿងនេះ ព្រះរាជាសៀម ដែលមានមុខមាត់ដូចសៀម និងសត្រូវរបស់ព្រះអង្គ ដែលមានមុខមាត់ដូចភូមា ព្រមព្រៀងជានឹងគ្នា និងធ្វើការជាមួយគ្នា ហើយរឿងនេះផ្ទុយពីសោកនាដកម្មប្រជាប្រិយធម្មតានាជំនាន់នោះ*[៣៧] *។*

*តែខ្ញុំបាទសូមអភិប្រាយពីចំណេះដឹងមួយយ៉ាងទៀត អំពីភូមិភាគនិងជនជាតិជិតខាង ដែលយើងច្រើនមើលស្រាល គឺ ចំណេះ «ខាងស្រុកទេស» របស់អ្នកស្រុក ។ អំពីពាក្យថា «ស្រុកទេស» នៅត្រង់នេះ ខ្ញុំបាទមិនចង់និយាយថា ជាប្រទេសថៃ ផ្ទុយពី«សាកលលោក» ឬ បស្ចិមប្រទេសទេ ។ «ស្រុកទេស» សំដៅទៅលើសហគមន៍តូចៗទូទាំងប្រទេសថៃ ផ្ទុយពីប្រទេសជាតិ ឬ ខេត្ត ។ ប្រជាជនបានលាយឡំនិងសេពគប់គ្នា តាមព្រំប្រទល់របស់ប្រទេសសៀមនិងប្រទេសជិតខាង តាំងពីរាប់រយឆ្នាំមកហើយ ព្រោះជាសមាជិករបស់ជនជាតិភាគតិចផ្សេងៗ ហើយគេបានក្លាយជា «ជាតិថៃ» តែនៅក្នុងពេលថ្មីៗនេះប៉ុណ្ណោះទេ ។ មានជនជាតិជាច្រើនដែលរស់នៅតាមព្រំដែន ដូចជាមឡាយូនៅតាមជាយដែនខាងត្បូង, ជនជាតិមន ការៀង កាឈិន ថៃធំ ។ល។ នៅតាមព្រំដែនថៃ–ភូមា, ជនជាតិលាវនៅត្រើយទាំងសងខាងនៃទន្លេមេគង្គ, ហើយនិងជនជាតិខ្មែរនៅក្នុងតំបន់ខាងត្បូងនៃខ្ពង់រាបគោរាជ ។ ជនជាតិទាំងអស់នេះ បានទទួលចំណេះក្នុងស្រុក អំពី «មាតុភូមិ» ខ្លួន នៅទាំងសងខាងនៃព្រំដែន ហើយអំពីនគររបស់ខ្លួនក្នុងអតីតកាល ។ ជនជាតិទាំងនេះ មានរឿងព្រេង ប្រពៃណី និងចំណេះដឹងដូចតែគ្នានឹងបងប្អូនរួមឈាមដែរ ដែលសព្វថ្ងៃនេះរស់នៅប្រទេសជិតខាងតាមព្រំដែន ។ ជាការណ៍ជាក់ច្បាស់ ដែលចំណេះដឹងប្រពៃណីទាំងនេះ មិនបានបែងចែកពិភពលោកជារដ្ឋនិងតំបន់ ដែលមានព្រំប្រទល់គូសលើផែនទី ផ្ទុយពីការនិយមរបស់ «ភូមិភាគសិក្សា» បែបផែនបស្ចិមប្រទេស ។*

*គួរឲ្យស្តាយណាស់ ក្នុងពេលថ្មីៗនេះ គេមិនបានយកចិត្តទុកដាក់នឹងជំពូកនានាក្នុងរឿងព្រេងបរមបុរាណទាំងនេះ ចំពោះវិស័យឧត្តមសិក្សា ។ រដ្ឋបានជួយជ្រោមជ្រែងចំណេះដឹងបែបចក្រពត្តិនិយមដែលមកពីមជ្ឈមណ្ឌល ហើយបានទាត់ចោលចំណេះដឹងរបស់អ្នកស្រុក ។ រដ្ឋថៃ ក៏បារម្ភផងដែរ អំពីការពង្រឹងការអះអាងអត្តសញ្ញាណនិងប្រពៃណីរបស់អ្នកស្រុក ហាក់ដូចជាការព្រួយបារម្ភខ្លាំងបំផុតមួយរបស់ស្យាមរដ្ឋ ចាប់តាំងពីពេលរដ្ឋសម័យថ្មីកើតមានឡើង ចាប់ពីចុង ស.វ. ទី ១៩ គឺការបាត់បង់ឯកភាព ហើយរដ្ឋក៏ចង់ពង្រឹងសន្តិសុខរបស់ជាតិថៃឲ្យមានឯកភាព ។ លុះពេលដែលការគំរាមកំហែងដល់សន្តិសុខជាតិ បានចុះអន់ថយក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ទើបរដ្ឋបានទទួលស្គាល់ចំណេះដឹងរបស់អ្នកស្រុកថា ជាប្រពៃណី ឬ ចំណេះដឹងមួយយ៉ាង ដែលមានគុណតម្លៃ ។ តាមពិត គេបានលើកកម្រិតចំណេះដឹងក្នុងតំបន់ខ្លះៗ ដើម្បីបង្កើនសក្តានុភាពរបស់សហគមន៍ថ្នាក់តំបន់ សម្រាប់ផលិតកម្មសេដ្ឋកិច្ច ហើយដោយសារមានគុណតម្លៃជា «ទំនិញ» សម្រាប់ទេសចរណ៍ ។ គេត្រូវរង់ចាំពេលវេលាយូរអង្វែង ដើម្បីឲ្យចំណេះដឹងរបស់អ្នកស្រុក មានគេទទួលស្គាល់ ហើយមានភាពថ្លៃថ្នូរវិញ ដែលជាតម្រូវ*

---

**(៣៦)** គ្រីស្តូហ្វ័រ អឺ. ហ្គូស្ហា (Christopher E. Goscha) *Thailand and the Southeast Asian networks of the Vietnamese revolution, 1885-1954* [**ប្រទេសថៃនិងបណ្តាញអាស៊ីអាគ្នេយ៍នាំឲឡាយរបស់បដិវត្តន៍យួនឆ្នាំ ១៨៨៥–១៩៥៤**] (ជាភាសាអង់គ្លេស) ក្រុងរិចម៉ុន្ត គ្រឹះស្ថានបោះពុម្ពផ្សាយខឺរហ្សុន គ.ស. ១៩៩៩ ។

**(៣៧)** គេបានបោះពុម្ពផ្សាយអត្ថបទនិពន្ធរបស់ខ្សែភាពយន្តនេះ ដូចតទៅ៖ ប្រីតី ភ្នំយង្គ *The King of the White Elephant* [**ព្រះរាជានៃដំរីស**] (ជាភាសាអង់គ្លេស) បាងកក គ.ស. ១៩៤០ ។

ការដើម្បីចូលក្នុងការអប់រំជាផ្លូវការ ។ ទន្ទឹមនឹងនេះ ភាពសម្បូរសប្បាយខាងសេដ្ឋកិច្ច បានផ្តល់ឱកាសឲ្យមានការវិនិយោគនិងទេសចរណ៍នៅក្នុងប្រទេសជិតខាង ហើយបាននាំមកនូវការចង់ដឹងចង់ស្គាល់អំពីប្រទេសជិតខាង ។ ក្នុងកម្រិតខ្លះ ចំណេះដឹងរបស់អ្នកស្រុកក្លាយជា «ទំនិញ» ដែលស្ថាប័នថ្នាក់ស្រុក ឬថ្នាក់ខេត្ត អាចផ្តល់ ឲ្យច្រើនជាងស្ថាប័នធំៗ នៅបាងកកអាចផ្តល់បាន ។ ចំណេះដឹងអំពីតំបន់នានាដែលមកពីស្ថាប័នថ្នាក់តំបន់ បានលូតលាស់នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ក្នុងទម្រង់គ្រោងការស្តីពីប្រវត្តិសាស្ត្រក្នុងស្រុក, ការបង្កើតមជ្ឈមណ្ឌលថ្នាក់តំបន់ ថ្នាក់ខេត្ត ឬ ថ្នាក់ភូមិភាគ ។ល។[(៣៨)] ។

ការលើកតម្លៃអត្តសញ្ញាណក្នុងស្រុកនិងចំណេះដឹងរបស់អ្នកស្រុកឡើងវិញ បានធ្វើឲ្យប្រទេសជិតខាងមានចំណាប់អារម្មណ៍ ដោយមានទស្សនៈខុសពីមជ្ឈមណ្ឌល (គឺ ក្រុងបាងកក) ។ ការលូតលាស់ខាងចំណេះដឹងថ្នាក់តំបន់ និងសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសថៃ ដែលមានទំនាក់ទំនងជាមួយប្រទេសជិតខាង ហើយដែលចេះតែកើនឡើង បាននាំឲ្យមានការស្រាវជ្រាវ, សកម្មភាព, គម្រោងការ និងទំនាក់ទំនងទៅវិញទៅមក រវាងស្ថាប័នថ្នាក់ភូមិភាគ ឬថ្នាក់តំបន់ ជាមួយនឹងស្ថាប័នដូចគ្នានេះដែរនៅប្រទេសជិតខាងតាមព្រំដែន ។ ការចង់ដឹងយ៉ាងខ្លាំងអំពីបងប្អូនជនជាតិតៃនិងថៃទាំងឡាយ ដែលនៅក្រៅប្រទេសថៃ បាននាំឲ្យមូលនិធិក្នុងសាកលវិទ្យាល័យធំៗ ស្ទើរតែទាំងអស់នៅប្រទេសថៃ ខិតខំចំណាយប្រាក់រាប់លានបាទ ។ ឧទាហរណ៍ នៅក្នុងស្ថាប័នជាច្រើននៅប៉ែកខាងជើងនៃប្រទេសថៃ មានគម្រោងការអំពីជនជាតិថៃធំ ថៃលឺ ថៃស៊ិបសងប៉ាន់ណា និងជនជាតិថៃទាំងឡាយនៅប្រទេសលាវ ។ ក្នុងប៉ែកឦសាននៃប្រទេសថៃ គឺនៅក្នុងខេត្តខនកែន អ៊ុប៊ុន (ឧប្បលរាជធានី) និង មហាសារខាម មានគម្រោងការអំពីប្រទេសលាវ ប្រទេសវៀតណាម និងឥណ្ឌូចិន ។ រីឯនៅខេត្តប៊ុរីរ៉ុំ (បុរីរម្យ) មានការសិក្សាអំពីជនជាតិខ្មែរ ដែលរស់នៅតាមជាយដែនថៃ–ខ្មែរ ។ នៅប៉ែកខាងត្បូង មានកម្មវិធីអំពីការសិក្សាថ្នាក់ភូមិភាគ ហើយមានការស្រាវជ្រាវអំពីជនជាតិមឡាយូ ។

## សេចក្តីសន្និដ្ឋាន

